**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងកាកសំណល់រឹងនៅក្នុងរាជធានីភ្នំពេញ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០


| ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ |
|---|---|
| និស្សិតឈ្មោះ៖**ក. សេង សុខតី** | **បណ្ឌិត អ៊ុន សកក្កដា** |
| **ក. គង់ ដារី** | |


| | | | |
|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** | | ឆ្នាំចូលរៀន | ២០១៧ |
| ជំនាន់ទី១៤ | | ឆ្នាំសរសេរសារណា | ២០២១ |

## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងកាកសំណល់រឹងនៅក្នុងរាជធានីភ្នំពេញ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ**ក. សេង សុខគី**

**ក. គង់ ដារី**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៤

ឆ្នាំចូលរៀន ២០១៧

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

ជាបឋមនាងខ្ញុំឈ្មោះ **ក. សេខ សុខតី** និងនាងខ្ញុំឈ្មោះ **ក. គង់ ដារី** ជាសិស្សនិស្សិតបានសិក្សានៅក្នុងជំនាន់ទី១៤ថ្នាក់បរិញ្ញាបត្រផ្នែករដ្ឋបាលសាធារណៈ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំសិក្សា ២០២០-២០២១។ នៅថ្ងៃនេះកូនសូមធ្វើការថ្លែងអំណរគុណចំពោះ៖

លោកឪពុកឈ្មោះ **លក គុណា** លោកឪពុកឈ្មោះ **គង់ ចាន់កុមារ**

អ្នកម្តាយឈ្មោះ **ស៊ុន តឿខ** អ្នកម្តាយឈ្មោះ **អៀ អ៊ីសុវណ្ណារ័ត្ន**

កូនសូមគោរពនូវមហាកត្តញ្ញូតាធម៌ជាអនេកប្បការ ជូនចំពោះលោកអ្នកមានគុណទាំងពីរដែលបានផ្តល់កំណើត និងខិតខំថែរក្សាចិញ្ចឹមបំបាច់រូបកូនចាប់តាំងតែពីក្នុងផ្ទៃ ៩ខែ១០ថ្ងៃរហូតដល់កូនបានក្លាយ ជាយុវត្តីធំធាត់ពេញរូបពេញរាងព្រមទាំងបានទទួលនូវការអប់រំទូន្មានប្រៀនប្រដៅតាំងពីសិក្សា នៅបឋមសិក្សារហូតដល់ឧត្តមសិក្សានេះ។ កូនពិតជាអរគុណចំពោះក្តីស្រលាញ់ដ៏ធំមហិមានេះ ហើយកូននឹងចងចាំទុកនិងគ្មានថ្ងៃបំភ្លេចបានឡើយកូនសូមលើកប្រណម្យគោរពប្រណិបតន៍ចំពោះស្នាដៃមួយនេះជូនទៅដល់លោកអ្នកមានគុណទាំងពីរជាទីគោរពដ៏ខ្ពង់ខ្ពស់។

នាងខ្ញុំ សូមគោរពថ្លែងអំណរគុណចំពោះ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ **លុយ ចន្ណា** និងព្រមទាំងមានការគោរពចំពោះលោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រមទាំងសាស្ត្រាចារ្យទាំងអស់នៃក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានសមត្ថភាពខ្ពង់ខ្ពស់ក្នុងការជួយតម្រង់ទិសដៅដល់រូបយើងខ្ញុំតាំងពីឆ្នាំថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់បញ្ចប់បរិញ្ញាបត្រនេះប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

ជាពិសេស សូមគោរពថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យ **បណ្ឌិត អ៊ុន សកក្កដា** ដែលបានខិតខំចំណាយពេលវេលាដ៏មានតម្លៃទាំងកម្លាំងកាយ និងកម្លាំងចិត្តក្នុងការផ្តល់នូវជាគំនិតល្អៗនូវយោបល់សម្រាប់ធ្វើការតាក់តែងរៀបរៀងអត្ថបទសារណានេះចាប់តាំងពីពេលចាប់ផ្តើមរហូតដល់បានសម្រេចជាស្ថាពរ។

ជាកិច្ចបញ្ចប់ យើងខ្ញុំទាំងពីរនាក់សូមធ្វើការប្រសិទ្ធិពរជ័យសិរីមង្គលបវរមហាប្រសើរកើតមានចំពោះលោកអ្នកមានគុណ លោកគ្រូអ្នកគ្រូសាស្ត្រាចារ្យ ព្រមទាំងបងប្អូនសាចញាត្តិទាំងអស់ជួបតែសេចក្តីសុខ សេចក្តីចម្រើនជារៀងរហូត។

# អារម្ភកថា

បន្ទាប់ពីនាងខ្ញុំទាំងពីរនាក់បានតាក់តែងនៅសារណាឡើង គឺដើម្បីជាជំនួយក្នុងការសិក្សាសម្រាប់ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ គឺជាលទ្ធផលដែលកើតចេញពីការខិតខំប្រឹងប្រែងបន្ទាប់ពីបានឆ្លងកាត់អស់រយៈពេល៤ ឆ្នាំកន្លងមកនៅសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។ យើងខ្ញុំទាំងពីរនាក់ក៏បានធ្វើការសម្រេចចិត្តថា និងជ្រើសរើសយកនៅប្រធានមួយដែលប្រធានបទនោះស្តីអំពី"ការគ្រប់គ្រងកាកសំណល់រឹងនៅក្នុងរាជធានីភ្នំពេញ" ដើម្បីជាការបន្សល់ទុកជាឯកសារស្រាវជ្រាវសម្រាប់សិស្ស និស្សិត ជំនាន់ក្រោយដែលមានបំណងក្នុងការសិក្សាស្វែងយល់បន្ថែម។ ដើម្បីបញ្ចប់ការសិក្សានេះគឺនាងខ្ញុំបានទទួលនូវការដឹកនាំដោយលោកសាស្រ្តាចារ្យបណ្ឌិត **អ៊ុន សតភក្ដា** ព្រមទាំងមានការទទួលបាននូវការសហការផ្តល់ជាឯកសារនានា ជាពិសេសការផ្តល់នៅគំនិតមតិយោបល់ល្អៗពីសំណាក់លោកសាស្រ្តចារ្យដោយផ្ទាល់។

នៅក្នុងការសម្រេចចិត្តជ្រើសរើសយកនូវប្រធានបទខាងលើនេះ ដើម្បីមកចងក្រងជាសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ គឺដោយសារតែនាងខ្ញុំមានយល់ឃើញថា ការគ្រប់គ្រងកាកសំណល់នៅក្នុងនៅរាជធានីភ្នំពេញគឺពិតជាមានការសំខាន់បំផុតសម្រាប់បរិស្ថាន និងសោភ័ណភាពនៅក្នុងទីក្រុង មួយវិញទៀតនាងខ្ញុំចង់បង្ហាញនូវ ចំណេះដឹងមួយចំនួនក្នុងការកាត់បន្ថយកាកសំណល់ឱ្យមានភាពប្រសើរឡើង។

ជាចុងក្រោយបើទោះបីជានាងខ្ញុំទាំងពីរនាក់មានការខិតខំសិក្សាស្រាវជ្រាវ និងធ្វើការត្រួតពិនិត្យយ៉ាងម៉ត់ចត់យ៉ាងណាក៏ដោយក៏ការសេរសេសារណាមួយនេះនៅតែមាននូវចំណុចចន្លោះខ្វះខាត ដូច្នេះនាងខ្ញុំទាំងពីរនាក់ សូមធ្វើការអភ័យទោសទុកជាមុននូវរាល់បញ្ហាកំហុសខុសឆ្គងដោយអចេតនាទាំងឡាយណាដែលមានកើតឡើងក្នុងការសរសេសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈនេះ ហើយនាងខ្ញុំទាំងពីរនិងមានការត្រៀមខ្លួនជានិច្ចក្នុងការរង់ចាំទទួលនូវមតិរិះគន់ដើម្បីកែលំអក្នុងន័យស្ថាបនាយ៉ាងខ្ពង់ខ្ពស់ពីសំណាក់សិស្ស និស្សិត អ្នកស្រាវជ្រាវ និងមិត្តអ្នកអានទាំងអស់ ដើម្បីធ្វើការជួយផ្តល់ជាមតិនិងគំនិតល្អៗបន្ថែមទៀត សម្រាប់ការកែលំអនៅសារណានេះឱ្យកាន់តែមានលក្ខណៈល្អប្រសើរថែមទៀត។ ដោយហេតុនេះក្រោយពីបានសិក្សាស្រាវជ្រាវបញ្ចប់នាងខ្ញុំទាំងពីរនាក់មានការសង្ឃឹមថាសារណាមួយនេះ និងក្លាយជាឯកសារមួយដែលមានការរួមចំណែកនៅក្នុងការជំរុញឱ្យមានការថែទាំបរិស្ថានកាន់តែមានភាពល្អប្រសើរឡើង។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ................................................ ១

**ជំពូកទី១**

**កាកសំណល់រឹងនៅក្នុងរាជធានីភ្នំពេញ**

**១.សញ្ញាណទូទៅនៃបរិស្ថាន** ................................................ ៣

១.១.១ និយមន័យនៃបរិស្ថាន ................................................ ៣

១.១.២. ប្រភេទនៃបរិស្ថាន ................................................ ៤

១.១.២.១.បរិស្ថានធម្មជាតិ ................................................ ៤

១.១.២.២. បរិស្ថានសង្គម-វប្បធម៌ ឬ ( បរិស្ថានបង្កើតឡើងដោយមនុស្ស) ................................................ ៤

**១.២. ស្ថានភាពកាកសំណល់នៅរាជធានីភ្នំពេញ** ................................................ ៥

១.២.១.ប្រភេទសំរាម និងកាកសំណល់ ................................................ ៥

១.២.២. ប្រភពនៃកាកសំណល់ ................................................ ៥

១.២.២.១. កាកសំណល់ឧស្សាហកម្ម ................................................ ៦

១ .២.២.២.កាកសំណល់វេជ្ជសាស្ត្រ ................................................ ៧

១.២.២.៣.កាកសំណល់លំនៅដ្ឋាន ................................................ ៧

១. ២.២.៤ កាកសំណល់សំណង ................................................ ៨

១ .២.២.៥.កាកសំណល់អេឡិចត្រូនិច ................................................ ៨

១ .២.៣.ផលប៉ះពាល់នៃសំរាម ................................................ ៩

១.២.៤ កាកសំណល់រាវ ................................................ ១១

១ .២.៤.ផលប៉ះពាល់នៃសំណល់រាវ ................................................ ១២

**១.៣.បរិបថដែលនាំឱ្យមានការគ្រប់គ្រងកាកសំណល់រឹងនៅក្នុងរាជធានីភ្នំពេញ** ................................................ ១៣

១ .៣.១.បញ្ហាដែលបណ្តាលឱ្យមានផលប៉ះពាល់ ................................................ ១៣

១ .៣.២.ការគ្រប់គ្រង និងការដាក់កាកសំណល់រួមគ្នាមិនបានល្អ ................................................ ១៤

១.៣.៣.ការចោលសំរាមមិនបានត្រឹម ................................................ ១៥

១.៣.៤.ផលប៉ះពាល់នៃការដុតសំរាម ................................................ ១៧

## ជំពូកទី២

## ដំណោះស្រាយ និងវិធានការណ៍នៃការគ្រប់គ្រងកាកសំណល់រឹងនៅរាជធានីភ្នំពេញ


**២ .១.វិធានការណ៍នៃការគ្រប់គ្រងសំណល់រឹង** ..... ១៩

២ .១.១.ការធ្វើឱ្យប្រសើរឡើងនូវសេវាប្រមូលសំណល់ និងការសម្អាត ..... ១៩

២.១.២.ការកែប្រែឥរិយាបថការបញ្ចេញសំណល់និងកន្លែងទុកដាក់សំណល់ ..... ២០

២.១.៣.ការទទួលខុសត្រូវរបស់ក្រុមហ៊ុនឯកជន ..... ២១

**២.២.វិធានការណ៍នៃការដោះស្រាយកាកសំណល់រឹង** ..... ២២

២.២.១.ការគ្រប់គ្រងសំណល់រឹង ..... ២២

២.២.១.១.ការញែកកាកសំណល់ ..... ២២

២ .២.១.២.ការរស្តុកទុកបណ្តោះអាសន្ន ..... ២៣

២.២.១.៣. ការប្រមូល និងការដឹកជញ្ជូន ..... ២៣

២ .២.១.៤.ការកែច្នៃសំណល់ ..... ២៥

**២.៣.វិធានការណ៍កាត់បន្ថយសំណល់រឹង.** ..... ២៧

២.៣.១.ការកែលម្អច្បាប់ទំលាប់ ..... ២៧

២.៣.២.លើកកម្ពស់ការអប់រំផ្នែកបរិស្ថាន ..... ២៧

២.៣.៣.បង្កើតសកម្មភាពគ្រប់គ្រងផ្សេងៗលើកាកសំណល់ ..... ២៨

២.៣.៤. កាត់បន្ថយបរិមាណសំណល់ ..... ២៨

២ .៣.៥.ការរប្រើប្រាស់ឡើងវិញតាមដែលអាចធ្វើបាន ..... ២៩

**២.៤.ការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល.** ..... ៣០

២.៤.១.រដ្ឋបាលថ្នាក់ជាតិ ..... ៣០

២.៤.២.រដ្ឋបាលថ្នាក់ក្រោមជាតិ ..... ៣១

២.៤.៣. ការផាកពិន័យ. ..... ៣៥

**សេចក្តីសន្និដ្ឋាន** ..... ៣៧

**អនុសាសន៍** ..... ៣៨

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជា គឺជាប្រទេសដ៏ចំណាស់មួយក្នុងតំបន់អាស៊ីអាគ្នេយ៍ និងជាប្រទេសមួយដែលជាប្រទេសកំពុងអភិវឌ្ឍន៍ផងដែរ។ ក្រោយពីសង្រ្គាមនៅក្នុងប្រទេសបានបញ្ចប់ ប្រទេសកម្ពុជាបានចាប់ផ្តើមស្តារស្ថេរភាពប្រទេស ឱ្យមានសន្តិសុខស្ថេរភាព ព្រមទាំងមានការរីកចម្រើនស្ទើរគ្រប់វិស័យ។ នៅពេលដែលវិស័យសេដ្ឋកិច្ច និងទេសចរណ៍កំពុង់មានការរីកចម្រើនយ៉ាងជាបន្តបន្ទាប់ហើយការគ្រប់គ្រងសំរាម គឺជាបញ្ហាប្រឈមដ៏សំខាន់មួយដល់បរិស្ថាន។ នៅរាជធានីភ្នំពេញសំរាមបានកើនឡើងពីរង្វង់២៦០០តោនក្នុងមួយថ្ងៃនៅឆ្នាំ២០១៨ ដល់រង្វង់២៩០០តោនក្នុងមួយថ្ងៃនៅក្នុងឆ្នាំ២០១៩កន្លងទៅ។ សាលារាជធានីភ្នំពេញធ្លាប់បានឱ្យដឹងថាទីលានចាក់សំរាមដែលមានទំហំជាង៣០ហិកតានៅបឹងជើងឯក ក្នុងខណ្ឌដង្កោនឹងត្រូវពេញហៀរ មិនអាចទទួលយកសំរាមបានទៀតឡើយនៅឆ្នាំ២០២១។នេះគឺជាបញ្ហាប្រឈមដែលទាមទារឱ្យមានដំណោះស្រាយ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

រាជធានីភ្នំពេញនាពេលបច្ចុប្បន្ននេះ បញ្ហាសំរាមគឺជាបញ្ហាមួយដែលមានលក្ខណៈស្មុគស្មាញ។ ក្នុងការដោះស្រាយបញ្ហា អាជ្ញាធរមានការណែនាំប្រជាពលរដ្ឋឱ្យមានយល់ដឹងនូវមូលដ្ឋាននៃវេចខ្ចប់ទុកដាក់សំរាមឱ្យបានត្រឹមត្រូវតាមប្រភេទរបស់វានីមួយៗ និងមានរបៀបរៀបរយពីព្រោះ វាជាភាពចាំបាច់បំផុតដែលត្រូវផ្តើមចេញពីប្រជាពលរដ្ឋតែម្តង។ ដោយមើលឃើញពីស្ថានភាពបែបនេះហើយទើបមានចំណោទមួយបានលើកឡើងថាតើគួរមានដំណោះស្រាយបែបណាខ្លះទៅលើបញ្ហាះទាំងអស់នោះ?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

តាមរយៈការស្រាវជ្រាវនេះ យើងខ្ញុំមានគោលបំណងដើម្បីស្វែងយល់អំពីរបៀបនៃការរៀបចំក្នុងការគ្រប់គ្រងនូវកាកសំណល់រឹងនៅរាជធានីភ្នំពេញ និងមានយន្តការក្នុងការដោះស្រាយបញ្ហាកាកសំណល់ដោយរួមបញ្ចូលទាំងការកែច្នៃកាកសំណល់ ដើម្បីជាឯកសារជំនួយបន្ថែមទៅដល់អ្នកដែលមានបំណងចង់ធ្វើការសិក្សានូវលើបញ្ហានេះ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទនៃការស្រាវជ្រាវនេះ គឺយើងមានការធ្វើឡើងនៅតែក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ ហើយចំពោះនៅក្នុងខ្លឹមសារក្នុងការចងក្រងសារណានេះផងដែរគឺនាងខ្ញុំសូមលើកយកតែពី ផលប៉ះពាល់កាសំណល់ទៅលើបរិស្ថាន និងការគ្រប់គ្រងកាកសំណល់របស់ប្រជាពលរដ្ឋ ដំណោះស្រាយរបស់រាជរដ្ឋាភិបាល និងវិធានការណ៍នៃការគ្រប់គ្រងទៅលើបញ្ហាទាំងនេះ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

តាមការស្រាវជ្រាវនៅប្រធានបទនេះពិតជា មានសារៈសំខាន់ណាស់សំរាប់នាងខ្ញុំទាំងពីរនាក់និងសម្រាប់អ្នកសិក្សាដ៏ទៃទៀត ក្នុងការបំពេញនៅចំណេះដឹងបន្ថែមទៀតដើម្បីធ្វើការដាស់តឿនស្មារតីដល់យុវជនជំនាន់ក្រោយឱ្យមានការយល់ដឹងកាន់តែច្បាស់អំពី បញ្ហាកាកសំណល់ ផលប៉ះពាល់ និងការកាត់បន្ថយការថែរក្សាបរិស្ថានឱ្យបានស្អាតល្អនិងមានសណ្តាប់ធ្នាប់។ ម៉្យាងទៀតប្រធានបទនេះបានចូលរួមចំនែកយ៉ាងសំខាន់ក្នុងដំណើរការនៃការគ្រប់គ្រងកាកសំណល់រឹងនៅក្នុងរាជធានីភ្នំពេញ ឱ្យកាន់តែមានប្រសិទ្ធភាព ជាពិសេសគឺជាជំនួយជួយដល់អ្នកជំនាន់ក្រោយអាចទទួលបានឯកសារ និងបានស្វែងយល់កាន់តែច្រើនដើម្បីបំពេញសេចក្តីត្រូវការ ឬអាចជាការជួយបាននូវអ្វីដែលខ្វះខាតនានា នៅពេលបច្ចុប្បន្ននេះ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

នៅក្នុងការចងក្រងសារណានេះ នាងខ្ញុំបានបានមានការស្រាវជ្រាវទៅលើការគ្រប់គ្រងឯកសារមួយចំនួនដែលមានការពាក់ព័ន្ធដូចជា ច្បាប់ អនុក្រឹត្យ សារាចរណែនាំ សៀវភៅណែនាំនានាដែលមានការទាក់ទងទៅ និងការគ្រប់គ្រងកាកសំណល់ ការថែរក្សាបរិស្ថាន និងតាមរយៈការស្រាវជ្រាវនៅក្នុងប្រព័ន្ធអ៊ិនធើណេតផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សារបស់នាងខ្ញុំទាំងពីរនាក់ត្រូវបានបែងចែកជា ២ជំពូកគឺៈ ជំពូកទី១ "កាកសំណល់រឹងនៅក្នុងរាជធានីភ្នំពេញ" ដែលនៅក្នុងជំពូកនេះ បែងចែកជាពីរចំណុចបន្ថែមទៀតគឺ ចំណុចទី១ និយាយអំពីសញ្ញាណទូទៅនៃបរិស្ថាន ចំណុចទី២ ស្ថានភាពកាកសំណល់នៅរាជធានីភ្នំពេញ និងចំណុចទី៣ បង្ហាញអំពីបរិបថដែលនាំឱ្យមានការគ្រប់គ្រងកាកសំណល់នៅក្នុងទីក្រុង។ ចំណែកឯ ជំពូកទី២ "ដំណោះស្រាយ និងវិធានការណ៍នៃការគ្រប់គ្រងកាកសំណល់រឹងនៅរាជានីភ្នំពេញ" ដោយនៅក្នុងជំពូកនេះក៏បាន បែងចែកជាបួនចំនុចបន្ថែមទៀតដែរគឺ ចំណុចទី១ និយាយអំពីការដាក់វិធានការណ៍នៃការគ្រប់គ្រងកាកសំណល់រឹង និងចំណុចទី២ និយាយអំពីវិធានការណ៍នៃការដោះស្រាយកាកសំណល់រឹង ចំណុចទី៣ និយាយអំពីវិធានការណ៍កាត់បន្ថយកាកសំណល់រឹង និងចុងក្រោយចំណុចទី៤ គឺការទទួលខុសត្រូវរបស់រដ្ឋាភិបាល។

# ជំពូកទី១

# កាកសំណល់រឹងនៅក្នុងរាជធានីភ្នំពេញ

# ជំពូកទី១
# កាកសំណល់រឹងនៅក្នុងរាជធានីភ្នំពេញ

## ១.១. សញ្ញាណទូទៅនៃបរិស្ថាន

### ១.១.១. និយមន័យនៃបរិស្ថាន

បរិស្ថាន គឺមជ្ឈដ្ឋានដែលនៅជុំវិញខ្លួនយើងដែលយើងមានទំនាក់ទំនងដោយផ្ទាល់ ឬដោយប្រយោលជាមួយវាហើយជីវិតយើងគ្រប់គ្នាទាំងអស់សុទ្ធតែត្រូវការបរិស្ថានដោយមិនអាចខ្វះបាន។ នៅក្នុងនិយមន័យនៃពាក្យបរិស្ថាននេះ គឺសំដៅទៅលើអ្វីៗទាំងអស់ដែលមាននៅជុំវិញខ្លួនរបស់យើងទាំងអស់គ្នារាប់ទាំងភាវៈមានជីវិត ( មនុស្ស សត្វ រុក្ខជាតិ ) និងភាវៈគ្មានជីវិត ( ទឹក ដី ខ្យល់ ផ្ទះ សាលារៀន សួនច្បារ) ព្រមទាំងអាចប៉ះបាន ឬមិនអាចមានការប៉ះបានធ្វើការមើលដោយភ្នែកទទេឃើញ ឬមិនអាចមើលឃើញព្រមទាំងមាននូវចំណងទាក់ទងគ្នាដោយផ្ទាល់ ឬដោយប្រយោល ដោយមានការប៉ះពាល់មកលើជីវិតរបស់យើងទាំងអស់គ្នា។[1]

នៅប្រទេសកម្ពុជាកំណើនប្រជាជន និងការរីកចម្រើនសេដ្ឋកិច្ចមានសន្ទុះយ៉ាងឆាប់រហ័សបានកំពុងតែបង្កឱ្យមានការបំពុលបរិស្ថាន។ ហើយនៅក្នុងនោះផងដែរកម្ពុជា គឺជាប្រទេសមួយដែលកំពុងមានការអភិវឌ្ឍដោយស្ថិតនៅក្នុង ការអភិវឌ្ឍកម្ពុជាក៏ជួបនៅបញ្ហាបរិស្ថានជាចម្បងមួយដែលបញ្ហាអស់នោះ គឺជាបញ្ហាចោលការគ្រប់គ្រងកាកសំណល់រឹង នៅក្នុងការបញ្ចេញសំណល់មានទំនាក់ទំនងដោយផ្ទាល់ជាមួយនិងកំណើនប្រជាជនដែលនាំឱ្យវាមានការព្រួយបារម្ភពីបញ្ហាបរិស្ថាន និងសុខភាពរបស់មនុស្ស។ ហេតុដូច្នេះដោយសារតែមាននូវកង្វះខាតនៃការអនុវត្ត ការគ្រប់គ្រងសំណល់ឱ្យបានត្រឹមត្រូវ និងការយល់ដឹងជាសាធារណៈនៅមានកម្រិតទើបធ្វើឱ្យបញ្ហាសំណល់រឹង នៅតែជាសម្ពាធបរិស្ថានដ៏ធំមួយនៅកម្ពុជា។ ហេតុដូចនេះ ដើម្បីធ្វើឱ្យ បរិស្ថាននៅក្នុងទីក្រុងមានភាពស្រស់បំព្រង និងសណ្តាប់ធ្នាប់ និងមានការប្រសើរឡើងយើងគួរស្វែយល់នៅពាក្យគន្លឹះមួយចំនួនសិនដែលពាក្យទាំងអស់នោះរួមមាន៖

- ទីក្រុង សំដៅដល់ទីកន្លែងមួយដែលមិនមានសកម្មភាពកសិកម្ម។ លក្ខណៈវិនិច្ឆ័យទៀត អាចរួមបញ្ចូល ៖ ចំនួនប្រជាជន ទីធ្លាទំនេរ ដង់ស៊ីតេ ប្រជាជន និងចរន្តការនៃសេដ្ឋកិច្ច។[2]
- ក្រុង សំដៅដល់ នគរ រាជធានី បុរី។[3]

[1] គេហទំព័រhttps://www.khsearch.com/qna/4260 ដកស្រង់នៅថ្ងៃទី១០ មិថុនា ឆ្នាំ២០២១

[2] សៀវភៅ នីតិរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩ ទំព័រទី១

[3] វចនានុក្រមខ្មែរ សម្តេច ព្រះសង្ឃរាជ ជួនណាត

➢ សណ្តាប់ធ្នាប់ សំដៅដល់ធាតុ៣ គឺ សន្តិសុខ ភាពស្ងប់ស្ងៀម និងអនាម័យ។[4]

និយាយជារួមការគ្រប់គ្រងកាកសំណល់រឹងនៅក្នុងរាជធានីភ្នំពេញ គឺដើម្បីធ្វើការរៀបចំរាជធានីឱ្យមានសោភ័ណភាព និងសណ្តាប់ធ្នាប់ដែលសំដៅទៅលើការរៀបចំទីក្រុងមួយកន្លែងឱ្យកាន់តែមានភាពស្រស់ស្អាត មានសន្តិសុខ មានភាពស្រស់បំព្រងពោលពេញទៅដោយសណ្តាប់ធ្នាប់ និងមានអនាម័យល្អនៅក្នុងការរស់នៅ។

### ១.១.២. ប្រភេទនៃបរិស្ថាន

តាមការលើកឡើងរបស់អ្នកវិទ្យាសាស្ត្រដែលមានការទាក់ទងទៅ និងបរិស្ថានយើងអាចឱ្យនិយមន័យរួម គឺអ្វីៗទាំងអស់ដែលមានជីវិត ឬគ្មានជីវិតដែលនៅជុំវិញខ្លួនយើងដោយរាប់បញ្ចូលទាំងសកម្មភាពមនុស្សផងដែរ ពាក្យថាបរិស្ថានដើម្បីឱ្យវាស្របតាមការសិក្សាបរិស្ថានយើងអាចធ្វើការបែងចែកនូវនិយមន័យបរិស្ថាន ពីរ ផ្នែកធំៗគឺ បរិស្ថានធម្មជាតិ និងបរិស្ថានសង្គម។[5]

#### ១.១.២.១ បរិស្ថានធម្មជាតិ

បរិស្ថានធម្មជាតិ មានន័យថាមិនបានបង្កើតឡើងដោយមនុស្សនោះឡើយ។ ហេតុដូចនេះ បរិស្ថានគ្មានជីវិត គឺ ស្ទឹង ទន្លេ បឹង សមុទ្រ មហាសមុទ្រ ភ្នំ និងកត្តាអាកាសធាតុដែលមានការរួមបញ្ចូល (សីតុណ្ហភាព សំណើម ភ្លៀង ការធ្លាក់ព្រិល ខ្យល់ )។ ពពួកសត្វ សត្វស្លាប រុក្ខជាតិដើមឈើជាផ្នែកបរិស្ថានមានជីវិត។ លើសពីនេះទៅទៀតកត្តាដែលជះឥទ្ធិពលលើបរិស្ថានធម្មជាតិមាន ពីរធំៗ កត្តារូប ឬអាប្យូទិច(គ្មានជីវិត) និង កត្តាជីវៈសាស្ត្រ ឬប្យូទិច ( មានជីវិត) បរិស្ថានទាំងពីរនេះគឺបង្ហាញពីទិន្នភាពទូទៅនៃបរិស្ថានទាំងមូល។[6]

#### ១.១.២.២. បរិស្ថានសង្គម - វប្បធម៌ ឬ ( បរិស្ថានបង្កើតឡើងដោយមនុស្ស )

បរិស្ថានសង្គម-វប្បធម៌ គឺអ្វីៗដែលមានជារូបរាងឡើងដោយផ្ទាល់ដៃពលកម្មផលិតកម្មប្រកបដោយការប៉ិនប្រសប់ និងការច្នៃប្រឌិតរបស់មនុស្សដើម្បីបម្រើសំណូមពរនិងតម្រូវការក្នុងជីវភាពរស់នៅរបស់មនុស្ស។ ដោយសមិទ្ធផលនៃបរិស្ថានសង្គម-វប្បធម៌នេះបានញ៉ាំងឱ្យចាកផុតពីភាពចំណុះធម្មជាតិ និងដកខ្លួនឱ្យផុតជាស្ថានភាពជាសត្វ ប៉ុន្តែរាល់សមិទ្ធផលទាំងអស់នេះមនុស្សបានច្នៃបង្កើតឡើងដោយធ្វើការកែច្នៃធម្មជាតិ បើគ្មានបរិស្ថានធម្មជាតិ គឺមិនអាចមានបរិស្ថានសង្គម-វប្បធម៌បានឡើយ។ គួយ៉ាងបរិស្ថានសង្គម-វប្បធម៌មានដូចជា អាគារ ផ្លូវថ្នល់ ស្ពាន ក្រុង ភូមិ ស្រុក ប្រឡាយទឹក ឧបករណ៍ផលិតកម្ម។

---

[4] សៀវភៅ នីតិរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩ ទំព័រទី១

[5] គេហទំព័រ មេរៀនបរិស្ថាន (epizy.com)ដកស្រង់នៅថ្ងៃទី១០ មិថុនា ឆ្នាំ២០២១

[6] គេហទំព័រhttps://www.khsearch.com/qna/1371 ដកស្រង់នៅថ្ងៃទី១០ មិថុនា ឆ្នាំ២០២១

ចំណែកឯបរិស្ថានសង្គម-វប្បធម៌គឺគ្មានជីវិត គឺសកម្មភាពសង្គម ស្ថាប័ន ការគ្រប់គ្រងដឹកនាំសង្គម នយោបាយ សេដ្ឋកិច្ច ការអប់រំ សាសនា ប្រវត្តិសាស្ត្រ ការកម្សាន្ត។[7]

## ១.២ ស្ថានភាពកាកសំណល់នៅរាជធានីភ្នំពេញ

### ១.២.១. ប្រភេទសំរាម និងសំណល់រឹង

**សំរាម** គឺជាផ្នែកមួយនៃសំណល់រឹងដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ហើយត្រូវបានបញ្ចេញពីលំនៅដ្ឋាន អាគារ រោងចក្រ ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មធ្យោបាយ ដឹងជញ្ជូន កន្លែងកំសាន្ត។[8]

**សំណល់រឹង** គឺជារបស់របរ ឬក៏វត្ថុទាំងឡាយណាដែលស្ថិតនៅក្នុងភាពរូបរឹងដែលពុំមានតម្លៃសម្រាប់ការប្រើប្រាស់តទៅទៀត ហើយត្រូវបានគេបោះបង់ចោលទៅក្នុងបរិស្ថាន។ សំណល់រឹង រួមមាន ក្រដាសថង់ប្លាស្ទិក ក្រណាត់លោហៈ ផ្សេងៗ សំបកដបកំប៉ុង បន្លែ ផ្លែឈើ សំណល់ចេញពី និងសំណល់ វទ្យុសកម្ម។[9]

### ១.២.២.ប្រភពនៃកាកសំណល់

តាមការពិតយើងបានដឹងពីប្រភពនៃសំណល់រឹងដែលចេញមកពី លំនៅដ្ឋាន ទីផ្សា អាគារ ពាណិជ្ជកម្ម មជ្ឈមណ្ឌលផ្គត់ផ្គង់ស្បៀងអាហារ សណ្ឋាគារ ភោជនីយដ្ឋាន ហាងលក់ទំនិញ ផ្សារទំនើប អ្នកលក់ដូរតាមដងផ្លូវសាធារណៈ តំបន់ទេសចរណ៍ និងកន្លែងផ្សេងៗទៀត។ សំណល់រឹងទាំងនេះគេសង្កេតឃើញមានច្រើនមុខដូចជា ក្រដាស ថង់ប្លាស្ទិក សំណល់អាហារ កម្ទេចកំណាត់ សំពត់ បន្លែ ផ្លែឈើ កម្ទេចដែក សំបកកំប៉ុង សំបកដប។[10]

សំណល់រឹងមួយផ្នែកទៀតមានប្រភពមកពីរោងចក្រដូចជា រោងចក្រផលិតអាគុយ ស័ង្កសី ថ្នាំសម្លាប់សត្វល្អិត និងរោងចក្រផលិតក្រដាស។ ម្យ៉ាងទៀតសំណល់រឹងក៏មានប្រភពចេញពីមន្ទីរពេទ្យ ( សំបកថ្នាំ ម្ជុលចាក់ថ្នាំ បង់រុំរបួស) មួយផ្នែកសំណល់រឹងចេញពីប្រភពទាំងនេះ មានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរបំផុត។ ប្រភពនៃកាកសំណល់ មានការបែងចែកប្រភេទដូចជា៖

---

[7] គេហទំព័រhttps://www.khsearch.com/qna/1371 ដកស្រង់នៅថ្ងៃទី១០ មិថុនា ឆ្នាំ២០២១

[8] មាត្រា ៣ នៃអនុក្រឹត្យលេខ ៣៦ អ.ន.ក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្ដីពី ការគ្រប់គ្រងសំរាម សំណល់រឹង

[9] មាត្រា ៣ នៃអនុក្រឹត្យលេខ ៣៦ អ.ន.ក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្ដីពី ការគ្រប់គ្រងសំរាម សំណល់រឹង

[10] គេហទំព័រhttps://www.khsearch.com/qna/9023ដកស្រង់នៅថ្ងៃទី១២ មិថុនា ឆ្នាំ២០២១

### ១.២.២.១. កាកសំណល់ឧស្សាហកម្ម

កាកសំណល់ឧស្សាហកម្ម គឺជាកាកសំណល់ដែលផលិតដោយសកម្មភាពឧស្សាហកម្មដែលកាកសំណល់ទាំងនោះចេញពីរោងចក្រដាក់ស្តែងដូចជា សំលៀកបំពាក់ ស្បែក ប្លាស្ទិក និងក្រដាស។ ប្រភេទនៃកាកសំណល់ឧស្សាហកម្មរួមមាន ក្រួស, កំបោរនិងបេតុង, សំណល់អេតចាយ, ប្រេង, សារធាតុរំលាយ, សារធាតុគីមី។ កាកសំណល់ឧស្សាហកម្មអាចមានលក្ខណៈពាក់កណ្តាលរឹង ឬរាវ។ វាអាចជាកាកសំណល់ដែលមានគ្រោះថ្នាក់ (ប្រភេទខ្លះមានជាតិពុល) ឬកាកសំណល់មិនមានគ្រោះថ្នាក់។

សំណល់ឧស្សាហកម្មដទៃទៀត ក៏ត្រូវគេដឹកយកមកចាក់នៅទីលានចាក់សំរាមនេះផងដែរ មានដូចជា

- សំណល់កៅស៊ូ និងកៅស៊ូថ្មល់ ដែលមាន ប៉ូលីម័រ ប៉ុយទីលីន សំណល់ថ្នាំលាប និងសំណល់វេចខ្ចប់
- សំណល់ពាក់កណ្តាលភក់ ដែលយកចេញពីអាងប្រព្រឹត្តកម្មទឹកសំអុយ
- ពពួកខ្សែភ្លើង និងកំទេចក្រណាត់
- សំណល់ប្លាស្ទិក ដែលមាន ប៉ូលីវីនិល ក្លរីដ
- សំណល់ថ្មពិល និងអាគុយផ្សេងៗ
- ផេះដែលសល់ពីការដុតសំណល់វេជ្ជសាស្ត្រ
- សំណល់អំពុលភ្លើង និងគ្រឿងអេឡិចត្រូនិក
- សំណល់មកពីថ្នាំកំចាត់សត្វល្អិតដែលប្រើក្នុងវិស័យកសិកម្ម និងក្នុងការវេចខ្ចប់ (ត្រូវតែដាក់ក្នុងធុងជ័រ មុនពេល កប់ចោល)
- សំណល់ដែលសល់ពីសកម្មភាពផលិតកម្ម និងការប្រើប្រាស់ទឹកថ្នាំព្រីន
- ទំនិញខូចគុណភាព ឬលើសកាលបរិច្ឆេទកំណត់ ដែលមិនស្របតាមស្តង់ដា សំណល់ពីការថតរូប
- ឱសថហួសកាលបរិច្ឆេទប្រើប្រាស់ និងសំណល់ចេញពីការផលិតឱសថ
- សំណល់ដែលមានសារធាតុអាបេស្តូស។[11]

[11] ដកស្រង់ចេញមកពី យុទ្ធសាស្ត្រ និងផែនការសកម្មភាព គ្រប់គ្រងសំណល់ សម្រាប់រាជធានីភ្នំពេញ ឆ្នាំ ២០១៨-២០៣៥ ដកស្រង់នៅថ្ងៃទី១៣ មិថុនា ឆ្នាំ២០២១

**១.២.២.២. កាកសំណល់វេជ្ជសាស្ត្រ**

កាកសំណល់វេជ្ជសាស្ត្រ គឺជាប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់។ សំណល់មន្ទីរពេទ្យចែកចេញជាប្រភេទដូចខាងក្រោម ៖

- សំណល់ដែលបង្កឱ្យមានការឆ្លង ៖ ជាប្រភេទដែលមានភ្នាក់ងារចម្លងជម្ងឺ ដូចជាសំណល់សម្ភារៈចេញពីមន្ទីរពិសោធន៍ បណ្តុះមេរោគ សំណល់ជាលិកាតាមផ្នែកផ្សេងៗ សម្ភារៈ ឬឧបករណ៍ធ្លាប់បានប៉ះពាល់ផ្ទាល់ជាមួយនឹងសំណល់របស់អ្នកជម្ងឺមាន មេរោគឆ្លង។
- សំណល់រោគសាស្ត្រ ៖ ជាលិកាមនុស្ស ឬវត្ថុរាវ។ មានដូចជា បំណែកសារពាង្គកាយ និង ឈាម។
- សំណល់ដែលបង្កឱ្យមានការមុត(ប្រួសស្នាម) ៖ ម្ជុល ប្រដាប់សម្រាប់ឆុងទឹក កាំបិតវះកាត់ ឡាម ផ្លែកាំបិត អំបែង ដប។
- សំណល់ឱសថ ៖ សំណល់ដែលមានឱសថ។ មានដូចជា ឱសថហួសកាលបរិច្ឆេទ ឬឈប់ប្រើប្រាស់ វត្ថុសម្រាប់ដាក់ឱសថ ដូចជាដប ប្រអប់របស់វាជាដើម។
- សំណល់សារធាតុគីមី ៖ សំណល់ដែលមានសារធាតុគីមី។ មានដូចជា ប្រតិករប្រើប្រាស់ក្នុងមន្ទីរពិសោធន៍ សារធាតុគីមី សារធាតុដែលប្រើសម្រាប់សម្លាប់មេរោគដែលហួសកាលបរិច្ឆេទ ឬឈប់ប្រើ និងសារធាតុរំលាយ។[12]

**១.២.២.៣. កាកសំណល់លំនៅដ្ឋាន**

កាកសំណល់លំនៅដ្ឋាន គឺជាភាគច្រើនជាប្រភេទសំណល់ចេញពីផ្ទះបាយដែលជាប្រភេទសរីរាង្គងាយពុករលួយអាចយកទៅធ្វើជាជីកំប៉ុសបានដូចជា បន្លែ, សំណល់ផ្លែឈើ, សំណល់ម្ហូបអាហារ ប្លាស្ទិក ក្រដាស ដែក ក្រណាត់ និងសម្ភារៈវេចខ្ចប់។ សំណល់លំនៅដ្ឋានក៏មានប្រភេទប្រកបដោយគ្រោះថ្នាក់ផងដែរ ដូចជា (សំណល់ថ្មពិល អាគុយ អំពូលភ្លើង ទូរទស្សន៍ ម៉ាស៊ីនត្រជាក់) ដែលខូចលែងប្រើប្រាស់កើត។[13]

[12] គេហទំព័រ ការគ្រប់គ្រងសំណល់រឹង | កំណត់ត្រាសិលា (wordpress.com) ដកស្រង់នៅថ្ងៃទី១២ មិថុនា ឆ្នាំ២០២១

[13] គេហទំព័រ ការគ្រប់គ្រងសំណល់រឹង | កំណត់ត្រាសិលា (wordpress.com) ដកស្រង់នៅថ្ងៃទី១២ មិថុនា ឆ្នាំ២០២១

### ១.២.២.៤. កាកសំណល់សំណង់

កាកសំណល់សំណង់ គឺជាសំណល់សំណង់នៅតាមការដ្ឋានមួយចំនួននៅក្នុងរាជធានីភ្នំពេញមានសមាសភាព ប្រហែល ៦០% ជាកំទេចឥដ្ឋថ្ម កំទេចស៊ីម៉ង់ និងដី រីឯ ២០% ទៀត ជាឈើ ១០% ជាលោហៈ ប្រហែល ៥% ប្លាស្ទិក និង ៥% ទៀត ជាក្រដាស និងសំណល់ផ្សេងៗទៀត។ នៅក្នុងការអនុវត្តន៍ជាក់ស្តែង សំណល់ការដ្ឋានសំណង់មិនត្រូវបានយកមកចាក់នៅទីលានឡើយ។ គេសង្កេតឃើញសំណល់សំណង់មួយចំនួនត្រូវបានគេយកមកប្រើវិញ ឬច្នៃឡើងវិញ (កម្ទេចកម្ទីថ្ម ឥដ្ឋ និងដី) ទៅតាមតម្រូវការចំណែកឯសំណល់សំណង់ដែលលាយចម្រុះគ្នាជាមួយនឹងសំរាមផ្សេងៗនិងគ្មានតម្លៃទីផ្សារ គឺត្រូវបានគេយកទៅចាក់ចោលដោយគ្មានសណ្តាប់ធ្នាប់នៅតាមប្រឡាយទឹក ដងទន្លេ ស្ទឹង បឹងបួរ ដីកសិកម្ម ឬទីវាលទំនេរ។ សមាសធាតុមួយចំនួនរបស់វា ដែលអាចបាន ត្រូវគេដុតដោយគ្មានសណ្តាប់ធ្នាប់ តែគេក៏សង្កេតឃើញការអនុវត្តបែបនេះមានការថយចុះផងដែរ។[14]

### ១.២.២.៥. កាកសំណល់អេឡិចត្រូនិច

កាកសំណល់អេឡិចត្រូនិច គឺជាការរីកចម្រើនរបស់ប្រជាពលរដ្ឋតម្រូវការបច្ចេកទេស និងឧបករណ៍អេឡិចត្រូនិកមានការកើនឡើនជាខ្លាំង គ្រឿងអេឡិចត្រូនិកដែលគេបានប្រើរួចហើយដែលមានដូចជា អេក្រង់ម៉ាស៊ីនព្រីន ក្តារចុចកុំព្យូទ័រ ធុង កុំព្យូទ័រ ម៉ាស៊ីនបញ្ចាំង LCD ទូរស័ព្ទដៃ ខ្សែភ្លើងជាដើមត្រូវបាននាំមកក្នុងប្រទេសកម្ពុជាពីបណ្តាលប្រទេសផ្សេងៗ។ ឧបករណ៍ទាំងនោះមានម៉ូលដែល និងទំហំខុសៗគ្នាបានបន្សល់ជាបំណែកគ្រឿងអេឡិចត្រូនិក ហើយផ្នែកខ្លះក៏អាចយកមកកែច្នៃលក់ប្រើប្រាស់ឡើងវិញ ឬប្រែក្លាយជាសំណង់អេឡិចត្រូនិក។ ការប្រើប្រាស់សំណល់អេឡិចត្រូនិកមានការកើនឡើង ពីមួយឆ្នាំទៅមួយឆ្នាំសម្រាប់សំណល់អេឡិចត្រូនិក ៦ប្រភេទ មានដូចជា៖ ទូរស័ព្ទ ទូរទស្សន៍ ម៉ាស៊ីនកុំព្យូទ័រ ទូទឹកកក ម៉ាស៊ីនត្រជាក់ និង ម៉ាស៊ីនបោកខោអាវ។ បើគិតចំនួនទូរស័ព្ទដៃមានបរិមាណច្រើនជាងគេ និងមានកំណើនយ៉ាងឆាប់រហ័ស។ សំណល់ប្រមាណពី ៣% ពីទីតាំងកែច្នៃ ឬបំបែកគ្រឿងអេឡិចត្រូនិកត្រូវយកមកចាក់ចោល រីឯ ៩៧% ទៀត លក់ចេញទៅដេប៉ូអេតចាយក្នុងស្រុក។ ទោះជាយ៉ាងណាក៏ដោយ តាមការសិក្សារបស់ក្រុមការងារ CEA ក្នុងឆ្នាំ ២០០៧ បានរកឃើញថាសំណល់អេឡិចត្រូនិកប្រមាណ ៨០% ត្រូវបានគេយកទៅកែច្នៃ។[15]

---

[14] ដកស្រង់ចេញមកពី យុទ្ធសាស្ត្រ និងផែនការសកម្មភាព គ្រប់គ្រងសំណល់ សម្រាប់រាជធានីភ្នំពេញ ឆ្នាំ ២០១៨-២០៣៥ ដកស្រង់នៅថ្ងៃទី១៣ មិថុនា ឆ្នាំ២០២១

[15] ដកស្រង់ចេញមកពី យុទ្ធសាស្ត្រ និងផែនការសកម្មភាព គ្រប់គ្រងសំណល់ សម្រាប់រាជធានីភ្នំពេញ ឆ្នាំ ២០១៨-២០៣៥ ដកស្រង់នៅថ្ងៃទី១៣ មិថុនា ឆ្នាំ២០២១

### ១.២.៣. ផលប៉ះពាល់នៃសំរាម

សំរាម មិនត្រឹមតែធ្វើឱ្យមានផលប៉ះពាល់ ទៅដល់ បរិស្ថាន សោភ័ណភាព និង បង្កឱ្យអាប់អួរ ដល់ បរិយាកាសជុំវិញនោះទេ តែវាថែមទាំង បណ្តាលឱ្យមាន ជំងឺផ្សេងៗទៀតបាន និង បង្កឱ្យមានគ្រោះថ្នាក់ យ៉ាងខ្លាំង ចំពោះ សុខភាពមនុស្ស តាមរយៈ ការប៉ះពាល់ ដោយផ្ទាល់ ឬ តាមការភាយក្លិនស្អុយ នៃ សំរាម ដែលរលួយ។

➢ **ផលប៉ះពាល់របស់សំរាមចំពោះសង្គម**

បើយោងទៅតាមលក្ខណៈរូប និងលក្ខណៈគីមីនៃសំរាម ឬសំណល់ប្រសិនបើយើងមិនបានធ្វើការ បែងចែក និ ងគ្រប់គ្រងឱ្យបានត្រឹមត្រូវទៅ តាមលក្ខណៈបច្ចេកទេសនោះវា និងអាចជះឥទ្ធិពលមកលើ សុខភាពមនុស្ស សត្វ និងបរិស្ថាន ជាច្រើនដូចតទៅៈ

- ធ្វើឱ្យបាត់បង់សោភ័ណភាពទីក្រុង និងលំនៅដ្ឋាន
- ជាប្រភពនិងទីជម្រកនៃពពួកមេរោគឆ្លង និងសត្វល្អិត
- អាចបង្កឱ្យមានក្លិនស្អុយ ប៉ះពាល់ដល់អ្នករស់នៅក្បែរគំនរសំរាម និងបរិស្ថាន
- ការបោះបង់ចោលសំរាមរាយប៉ាយអាចបង្កការស្ទះដល់ប្រព័ន្ធលូសាធារណៈ តាមរយៈការហូរនាំ ដោយទឹកភ្លៀងជា លទ្ធផល ខូចដល់សោភ័ណភាព និងសណ្តាប់ធ្នាប់សាធារណៈ
- បាត់បង់នូវកំណើនភ្ញៀវទេសចរណ៍។[16]

➢ **ផលប៉ះពាល់ចំពោះបរិស្ថាន**

បច្ចុប្បន្ននេះ សំរាមភាគច្រើននៅក្នុងសមុទ្ររបស់យើង គឺសំរាមប្លាស្ទិក។ ជារៀងរាល់ឆ្នាំប្លាស្ទិកប្រមាណ ៨ លានតោន ហូរចូលទៅក្នុងសមុទ្រ ស្មើនឹងឡានដឹកសំរាមធំមួយពេញ រៀងរាល់មួយនាទីម្តង។សំណល់ ប្លាស្ទិកក្នុងពិភពលោកប្រមាណ ៩០% ត្រូវហូរចូលទៅក្នុងសមុទ្រតាមរយៈទន្លេធំៗចំនួន១០។ ទន្លេចំនួន ៨ ក្នុងចំណោមទន្លេទាំង ១០ នេះ គឺឋិតនៅអាស៊ី ដែលក្នុងនោះ ទន្លេមួយ គឺទន្លេមេគង្គ។ ប្លាស្ទិកផ្លាស់ទីពីដី ទៅក្នុងទន្លេ ដោយសារការបោះចោលទៅក្នុងទន្លេ ឬតាមរយៈខ្យល់បក់ ហើយចុងក្រោយ វាធ្លាក់ចូលទៅក្នុង សមុទ្រ។ នៅតំបន់សមុទ្រ ថនិកសត្វ ត្រី និងបក្សីជាច្រើន រងផលប៉ះពាល់ ដោយសារការស៊ីប្លាស្ទិក ឬជាប់ ទាក់នឹងប្លាស្ទិក។ កន្លងមក មានសត្វសមុទ្រជាប់ទាក់នឹងសម្ភារប្លាស្ទិកចំនួនជាង ៣៤៤ករណី ដែលត្រូវ បានរាយការណ៍។ ជារៀងរាល់ឆ្នាំ មានបក្សីសមុទ្រចំនួនជាង ១ លានក្បាល និងសត្វសមុទ្រ ចំនួន ១០០.០០០ ក្បាលបាត់បង់ជីវិត ដោយសារច្រឡំស៊ីប្លាស្ទិកជាចំណី។ ប្រព័ន្ធអេកូឡូស៊ីផ្កាថ្ម ក៏រងប៉ះពាល់

[16]គេហទំព័រ សំរាម ៖ ផលប៉ះពាល់ និង ការគ្រប់គ្រង – កំណត់ត្រាសិលា (wordpress.com) ដកស្រង់នៅថ្ងៃទី ១៦ មិថុនាឆ្នាំ ២០២១

ដោយសារទទួលរងការសឹករិចរិល និងការខូចខាតបង្កឡើងដោយសារឧបករណ៍នេសាទដែលធ្វើពីប្លាស្ទិក ផងដែរ។[17]

❖ **តើសកម្មភាពរបស់យើងមានឥទ្ធិពលទៅលើបរិស្ថានយ៉ាងដូចម្តេច?**

សកម្មភាពរបស់យើងមានឥទ្ធិពលទៅលើបរិស្ថានបីយ៉ាង៖

- ទីមួយ យើង ទាញយក ធនធានពីបរិស្ថានធម្មជាតិ ដូចជា ត្រី រ៉ែ ព្រៃឈើ ទឹកស្អាត និងត្បូង។ ធនធានធម្មជាតិភាគច្រើនមានកំរិត ដូច្នេះបើយើងទាញវាពីបរិស្ថានច្រើនពេក នោះនឹងអាចបណ្តាលឱ្យធនធានទាំងនោះអស់នៅ ថ្ងៃណាមួយ ។ ប្រសិនបើយើងនេសាទត្រីច្រើនពេកពីបឹង ស្ទឹង ទន្លេ នោះត្រី នឹងនៅតិចតួចប៉ុណ្ណោះដែល អាចបង្កើតកូនចៅ ហើយទៅអនាគត នឹងមានត្រីតែតិចតួចប៉ុណ្ណោះក្នុងបឹង ស្ទឹង ទន្លេ។ ជាពិសេស ប្រើបប្រាស់ឧបករណ៍ខុសច្បាប់។
- ទីពីរ យើង បញ្ចេញចោល របស់ខ្លះទៅក្នុងបរិស្ថានវិញ ដូចជាៈ ផ្សែង ដបប្លាស្ទិក កំប៉ុងអាលុយមីញ៉ូម ថង់ប្លាស្ទិក សំណល់រាវ។ បើយើងបញ្ចេញសំណល់ច្រើនពេកទៅក្នុងបរិស្ថានធម្មជាតិ នោះទឹក ខ្យល់ និងដី ក៏ប្រែក្លាយទៅជាកខ្វក់ ពុំអាចប្រើប្រាស់កើត។ ទាក់ទងនិងចំណុចនេះ យើងទាំងអស់គ្នា គប្បីអនុវត្តតាមលក្ខណៈបច្ចេកទេសបរិស្ថាន ក្នុងការគ្រប់គ្រង សំណល់ឱ្យបានល្អ ដោយធ្វើឱ្យបរិស្ថានក្នុងគ្រួសារ និងសហគមន៍យើងស្អាត បៃតង ប្រកបដោយផាសុកភាព និងមាននិរន្តរភាព សំរាប់ខ្លួនយើងផ្ទាល់ និងមនុស្សជំនាន់ក្រោយ។ ក. បច្ចេកទេសគ្រប់គ្រងសំណល់រឹង រួមមាន ការជ្រើសរើសទីតាំងចាក់សំណល់តាមលក្ខណៈបច្ចេកទេស ការប្រមូល និងដឹកជញ្ជូន កំណែច្នៃឡើងវិញ និងការធ្វើកំប៉ុស្ត៍ ការកាត់បន្ថយបរិមាណ សំណល់ និងដុតសំណល់ក្នុងឡដែលមានលក្ខណៈបច្ចេកទេស។ ខ. បច្ចេកទេសគ្រប់គ្រងសំណល់រាវ រួមមាន ការជ្រើរើសទីតាំងអាងស្តុក ឬអាងប្រព្រឹត្តកម្មសំអាតសំណល់រាវ ការរៀបចំអាងប្រព្រឹត្តកម្មសំអាតសំណល់រាវតាមលក្ខណៈ បច្ចេកទេស ការរៀបចំប្រព័ន្ធលូបង្ហូរបង្កប់ក្នុងដី ការប្រមូល និងដឹកជញ្ជូន កំណែច្នៃឡើងវិញ ការកាត់បន្ថយបរិមាណសំណល់។
- ទីបី យើង ជំនួស បរិស្ថានធម្មជាតិដោយអ្វីមួយផ្សេងទៀត ។ ការកាប់ឆ្ការព្រៃឈើ ហើយជំនួសវិញដោយផ្លូវថ្នល់ លំនៅដ្ឋាន ឬរោងចក្រជាដើម ។ ការយកអ្វីទៀតច្រើនហួស ទៅជំនួសធនធានធម្មជាតិ ក៏អាចធ្វើឱ្យមានឥទ្ធិពល អវិជ្ជមានដែរ បរិមាណដីធ្លីដែលអាចឱ្យមនុស្សកែប្រែ និងប្រើប្រាស់មានកំរិត។

[17]គេហទំព័រ https://www.moe.gov.kh/togetherreduceplastic ដកស្រង់នៅថ្ងៃទី ១៦ មិថុនាឆ្នាំ ២០២១

ប្រសិនបើព្រៃឈើត្រូវគេកាប់ បំផ្លាញ ដើម្បីយកដីដាំដំណាំនោះ យើងត្រូវការពេលវេលារាប់រយឆ្នាំ ដើម្បីឱ្យព្រៃនោះដុះឡើងវិញ ។[18]

➢ ផលប៉ះពាល់របស់សំរាមចំពោះសុខភាព

សំរាមអាចផ្តល់ផលអាក្រក់យ៉ាងធ្ងន់ធ្ងរមកលើសុខភាពរបស់មនុស្សទូទៅមានដូចជា៖

- **សារធាតុពុលនៅក្នុងសំរាម** សារធាតុមួយចំនួននៅក្នុងសំរាមអាចធ្វើឱ្យមានការប៉ះពាល់ដល់ស្បែកដែលបណ្តាលឱ្យមនុស្ស កើតមានជំងឺសើស្បែកដែលបណ្តាលឱ្យមនុស្ស រលាកភ្នែក ជម្ងឺរលាកផ្លូវរំលាយអាហារ ជម្ងឺផ្លូវដង្ហើម រលាកសួតជាដើម។ ជួលកាលវាអាចបណ្តាលឱ្យមានការប៉ះពាល់ទៅដល់ប្រព័ន្ធប្រសាទថែមទៀតផង។ ដោយសារតែការសាយភាយក្លិន និងការចម្លងមេរោគពីសំរាម។
- **មេរោគនៅក្នុងសំរាម** នៅក្នុងសំរាមមានផ្ទុកទៅដោយមេរោគច្រើនប្រភេទ។ នៅពេលវាឆ្លងមកដល់ក្នុងខ្លួនមនុស្សវាបង្កឱ្យកើតមានជម្ងឺរាគរូស ជម្ងឺរាកមួល អាសន្នរោគ គ្រុនពោះវៀន និងជម្ងឺជាច្រើនទៀត។ ប្រសិនបើមិនបានធ្វើអនាម័យជាប្រចាំទេ ជម្ងឺទាំងនោះ និងអាចក្លាយទៅជាប្រភេទជម្ងឺរាំរ៉ៃបាន។ ម្យ៉ាងវិញទៀតសារធាតុមុតស្រួចដែលមាននៅក្នុងសំរាមអាចបង្កជារបួសស្នាមរហូតក្លាយទៅជាជំបៅរាំរ៉ៃផងដែរ។
- **សារធាតុគីមីនៅក្នុងសំរាម** សំរាមមានផ្ទុកទៅដោយសារធាតុគីមីមួយចំនួនដែលអាចបង្កឱ្យកើតជំងឺមហារីកបាន។ ម្យ៉ាងវិញទៀតវាក៏អាចធ្វើឱ្យមាន អុកស៊ីដកម្ម លើសារធាតុគីមីដទៃទៀតដែលអាចនាំគ្រោះថ្នាក់ដល់មនុស្ស រុក្ខជាតិ និង សត្វ ដែលមាននៅក្នុងបរិស្ថានទៀតផង។

### ១.២.៤. ភាគសំណល់រាវ

សំណល់រាវ សំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថានដែលបញ្ចេញពីសកម្មភាព ឬដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម។[19] ហើយសំណល់រាវនេះផងដែរ គឺជាការកើតចេញពីកម្ទេចកម្ទី កាកសំណល់ផ្ទះបាយ បន្លែ កាកម្ហូបដែលមានការវេចខ្ចប់មិនបានត្រឹមត្រូវ និងធ្វើការបោះទៅក្នុងប្រឡាយ ប្រព័ន្ធលូ ដែលមានការចោលពាសវាលពាសកាលដែលវាបានបង្កអោយមានការរាំងស្ទះប្រព័ន្ធលូ និងធ្វើឱ្យមានក្លិនមិនល្អ ព្រមទាំងមានភាពកង្វក់នៅក្នុងប្រភពទឹកដោយសារមានបំពុលផ្សេងៗ។ ហើយនៅពេល ដែលគ្រប់គ្រងសំណល់រាវមិនបានល្អ នឹងបង្កឱ្យមានការបំពុលជាច្រើនកើតឡើង ដូចជា ការបំពុល

[18] គេហទំព័រ សកម្មភាពមនុស្សលើបរិស្ថាន | មន្ទីរបរិស្ថានខេត្តតាកែវ (wordpress.com) ដកស្រង់នៅថ្ងៃទី ១៦ មិថុនាឆ្នាំ ២០២១

[19] មាត្រា ៤ នៃអនុក្រឹត្យលេខ ២៣៥ អនក្រ.បកចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ ស្តីពី ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់

ទឹក ការបំពុលដី និងការបំពុលទឹកនៅក្នុងដី ហើយក៏ធ្វើឱ្យប៉ះពាល់ដល់មនុស្ស សត្វ និង រុក្ខជាតិ ទៀតផង។ នៅពេលសំណល់រាវបានបង្ហូរចូលក្នុងទឹក និងដីនឹងធ្វើឱ្យទឹកពុល ព្រមទាំងដីអស់ជីវ ជាតិ។ ម៉្យាងទៀត នៅពេលដែលសំណល់ជ្រាបចូលក្នុងដី វាអាចនឹងប៉ះពាល់ដល់គុណភាពទឹក ដែលនៅក្នុងដីទៀតផង។ បន្ថែមពីនេះ ការធ្វើឱ្យខូចគុណភាពទឹក ដោយការបង្ហូរទឹកកង្វក់ និង ចោលសំរាមនេះចូលក្នុងទឹក ដែលជាបញ្ហាដែលធ្វើឱ្យទឹកមានលក្ខណៈកករ។ បន្ទាប់មក នៅពេល ដែលមនុស្សបានយកទឹកនោះ មកប្រើប្រាស់នឹងធ្វើឱ្យប៉ះពាល់ដល់សុខភាព ដែលនឹងងាយកើតនូវ ជំងឺនានា ដោយជាធម្មតា ទឹកកង្វក់ទាំងនោះ គឺមានក្លិន ដែលធ្វើឱ្យមនុស្សមិនឃ្លានចំណីអាហារ ធ្វើឱ្យទន់ខ្សោយក្នុងការដកដង្ហើម ក្អួតចង្អោរ និងការបង្កឱ្យមានវិបត្តិដល់ខួរក្បាលជាដើម។ ទន្ទឹមនិងនេះ ធ្វើឱ្យមានការបំផ្លាញដល់ជីវចំរុះ ដោយសារសារធាតុគីមី ឬសំណល់គ្រោះថ្នាក់ដែលមាននៅក្នុងទឹក នឹងធ្វើឱ្យជីវចំរុះមួយចំនួនក្នុងមជ្ឈដ្ឋាននោះត្រូវថយចុះ ឬក៏អាចបាត់បង់ទាំងស្រុង។

### ១.២.៤.១. ផលប៉ះពាល់នៃសំណល់រាវ

ចំពោះប៉ះពាល់នៃសំណល់រាវទៅលើបរិស្ថាន គឺវាជាផ្នែកមួយដែលបង្កឱ្យមានការបំពុលដល់បរិស្ថាន ដែលសកម្មភាពទាំងនោះបានបង្កើតជាផលវិបាកផ្នែកបរិស្ថានសំខាន់។

**ការបំពុលទឹក** គឺវាធ្វើឱ្យមានការប៉ះពាល់ដោយផ្ទាល់ដល់បរិស្ថានហើយវាក៏ប៉ះពាល់ទាំងដោយផ្ទាល់ និងដោយប្រយោលដល់មនុស្សនិងសត្វផងដែរ។ ការប្រើប្រាស់ទឹកស្អាត និងប្រកបដោយនិរន្តរភាព នៅតែជាបញ្ហាប្រឈមមួយ ជាពិសេសគ្រួសារនៅតាមជនបទ។ គួរឱ្យកត់សម្គាល់ផងដែរ ទឹកទន្លេ ដែលរងការបំពុលនៅតែជាប្រភពទឹកសំខាន់សម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាជន ដោយហេតុថា ហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខាទឹក នៅមានកម្រិតនៅឡើយ។ ទឹកកខ្វក់ ឬរងការបំពុល ជាលទ្ធផលបណ្តាលមកពី ឧស្សាហកម្មរ៉ែ និងសកម្មភាពឧស្សាហកម្មផ្សេងៗទៀត ដែលនាំឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស។[20]

[20] ដកស្រង់ចេញមកពី ប្រតិភូសហភាពអឺរ៉ុបនៅកម្ពុជា. កម្រងព័ត៌មានបរិស្ថាននៅកម្ពុជា ឆ្នាំ២០១២.ដកស្រង់នៅថ្ងៃទី១៧ មិថុនាឆ្នាំ២០២១ https://europa.eu/capacity4dev/public-environment-climate/documents/country-environmental-profile-cambodia

## ១.៣. បរិបទដែលនាំឱ្យមានការគ្រប់គ្រងកាកសំណល់រឹងនៅក្នុងរាជធានីភ្នំពេញ

### ១.៣.១. បញ្ហាដែលបណ្តាលឱ្យមានផលប៉ះពាល់

សំណល់រឹងមានឥទ្ធិពលធ្ងន់ធ្ងរទៅលើសុខភាពសាធារណៈ និងបរិស្ថានប្រសិនបើស្តុកប្រមូល និងបោះចោលមិនបានត្រឹមត្រូវ។ ផលប៉ះពាល់ខ្លាំងជាងគេគឺធ្វើឱ្យមានការបំពុលទឹកដី ខ្យល់ និងចម្លងជំងឺរាតត្បាតផ្សេងៗដល់ មនុស្ស សត្វ និងរុក្ខជាតិ។ ម្យ៉ាងទៀតកាលណាយើងចោលសំណល់ទាំងនោះគ្មានសណ្តាប់ធ្នាប់ វាធ្វើឱ្យទីក្រុង ទីប្រជុំជននានាបាត់បង់សោភ័ណភាព និងកង្វក់ដោយសារក្លិនស្អុយនៃកាកសំណល់ទាំងនោះហើយប៉ះពាល់ដល់សុខភាពមនុស្ស សត្វ រុក្ខជាតិ ព្រមទាំងមានឥទ្ធិពលដល់សេដ្ឋកិច្ចជាតិ និងមោទនភាពជាតិ។ លើសពីនេះ ទៅទៀតកាកសំណល់ គឺជាបញ្ហាដ៏សំខាន់នៅគ្រប់ទីកន្លែងទាំងអស់ដែលយើងទាំងអស់គ្នាត្រូវយល់ដឹង និងទុកដាក់វាឱ្យបានត្រឹមត្រូវ។ សំណល់ភាគច្រើនលើសលប់ត្រូវបានបង្កើតឡើងដោយសារមនុស្ស បើមនុស្សពុំបានទុកដាក់សំណល់ទាំងនោះឱ្យបានត្រឹមត្រូវទេវា និងធ្វើឱ្យមានការបំពុលបរិស្ថាន។ ប្រសិនបើមនុស្សបោះចោលទៅក្នុងប្រព័ន្ធលូបង្ហូរទឹក ឬតាមដងផ្លូវថ្នល់វាធ្វើឱ្យទឹកនោះកខ្វក់ ហើយវាអាចបង្កឱ្យមនុស្សមានជំងឺពីព្រោះកណ្តុរ ឬសត្វល្អិតមួយចំនួនដូចជាកន្លាត និងស្រមោចជាដើមអាចជាភ្នាក់ងារចម្លងមេរោគ។ នៅពេលសត្វទាំងនោះមករោម ឬស៊ីសំណល់ដែលមានមេរោគវាបាននាំទៅជាមួយនូវមេរោគទាំងនោះហើយនៅពេលដែលពួកវាបានទៅប៉ះពាល់មនុស្ស ឬចំណីដែលអ្នកលក់កំពុងតែលក់នៅតាមដងផ្លូវ ឬតាមផ្សារ អាហាររបស់មនុស្សទាំងនោះ និងបណ្តាលឱ្យមានការឆ្លងមេរោគ។ ម្យ៉ាងវិញទៀតមានមេរោគមួយចំនួន និងក្លិនមិនល្អដែលមាននៅក្នុងសំណល់ក៏អាចបក់បោកតាមខ្យល់ ហើយអាច និងចម្លងមេរោគធ្វើឱ្យប៉ះពាល់ដល់សុខភាពមនុស្សផងដែរ។ ដូចច្នេះយើងទាំងអស់គ្នាត្រូវធ្វើការទុកដាក់សំណល់ឱ្យបានត្រឹមត្រូវ និងដើម្បីការពារកុំឱ្យមានការបំពុលបរិស្ថាន ឬមានការចម្លងមេរោគផ្សេងៗ។[21]

[21] គេហទំព័រ សំរាម ៖ ផលប៉ះពាល់ និង ការគ្រប់គ្រង – កំណត់ត្រាសិលា (wordpress.com) ដកស្រង់នៅថ្ងៃទី១៣ មិថុនា ឆ្នាំ២០២១

## ១.៣.២. ការគ្រប់គ្រង និងការដាក់កាកសំណល់រួមគ្នាមិនបានល្អ

នៅពេលកាកសំណល់បានចាក់ជាគំនរ ឬរាយប៉ាយក្នុងសហគមន៍របស់យើងវាមានសភាពអាក្រក់មើលមានក្លិនមិនល្អ និងមិនល្អសម្រាប់សុខភាពកាកសំណល់ខ្លះអាចត្រូវបានប្រើប្រាស់ ឬកែច្នៃឡើងវិញបានប៉ុន្តែកាកសំណល់ប្រភេទខ្លះត្រូវការពេលវេលាយូរទើបរលួយប្រភេទខ្លះទៀតមិនរលួយឡើយ។ នៅពេលមិនបែងចែកប្រភេទកាកសំណល់បរិមាណកាកសំណល់ និងបញ្ហាដែលកើតឡើងដោយកាកសំណល់គឺមានទំហំធំធេងជាងដែលការរៀបចំកាកសំណល់ទៅទៀត។ នៅពេលកាកសំណល់បង្កគ្រោះថ្នាក់ ដូចជាថ្មពិលចាស់ និងកាកសំណល់នៃការថែទាំសុខភាពត្រូវបានដាក់រួមគ្នាជាមួយកាកសំណល់ដទៃ ដូចជាក្រដាស និងសំណល់អាហារ នោះល្បាយកាកសំណល់នេះកាន់តែមានការពិបាក និងមានគ្រោះថ្នាក់ក្នុងការដោះស្រាយ។ នៅពេលមិនបានបោះចោលត្រឹមត្រូវ កាកសំណល់បណ្តាលឱ្យមានបញ្ហាសុខភាពជាច្រើន។

- គំនរសំរាមនៅកណ្តាលវាលផ្តល់កន្លែងបង្កកំណើតដល់សត្វកណ្តុរ រុយ មូស កន្លាត និងសត្វល្អិតដទៃទៀតដែលចម្លងជំងឺ ដូចជា ជំងឺគ្រុនចាញ់ គ្រុនឈាម គ្រុនពោះវៀន និងជំងឺដទៃទៀត។
- រណ្តៅសំរាម និងគំនរសំរាម ចិញ្ចឹមមេរោគ។ មេរោគទាំងនេះអាចចម្លងទៅកុមារដែលលេងនៅទីនោះនិងអ្នករើសអេតចាយលើគំនរកាកសំណល់។ មេរោគនៅក្នុងសំរាមអាចបណ្តាលឱ្យមានបញ្ហាសុខភាពផ្សេងៗដូចជា ជំងឺរាក និងអាសន្នរោគ ក្រមរមាស់ តេតាណូស មេរោគផ្សិត និងការបង្ករោគផ្សេងៗទៀតនៅលើស្បែកនិងភ្នែក។
- សំរាមធ្វើឱ្យស្ទះផ្លូវទឹក និងលូបង្ហូរ។ បែបនេះអាចបណ្តាលឱ្យមានទឹកកង្វក់ដែលសត្វល្អិតអាចបង្កកំណើត និងធ្វើអោយជន់នៅពេលភ្លៀង ហើយក្នុងនោះមានលាមកមនុស្សឬសត្វវាបណ្តាលឱ្យឆ្លងមេរោគដល់ប្រភពទឹកផឹក និងដី។
- នៅពេលគំនរកាកសំណល់ធំៗដួលរលំ វានិងបង្កគ្រោះថ្នាក់ដល់អ្នកដែលធ្វើការជាមួយកាកសំណល់ ឬអ្នករស់នៅក្បែរៗនោះ។
- សារធាតុគីមីពុលនៅក្នុងកាកសំណល់ ជ្រាបទៅក្នុងប្រភពទឹក និងដីធ្វើឱ្យពុលដល់មនុស្សជាច្រើនឆ្នាំ ជួនកាលគំនរកាកសំណល់ដែលមានសារធាតុពុល អាចផ្ទុះឬឆេះ។

នៅពេលដុតប្លាស្ទិក និងកាកសំណល់ពុលដទៃទៀតនៅទីវាល ឬនៅក្នុងឡដុត សារធាតុគីមីត្រូវបានបញ្ចេញទៅក្នុងខ្យល់ ហើយផេះពុលបណ្តាលឱ្យមានជំងឺ ក្អក ចង្អោរ ក្អួត និងការបង្ករោគនៅភ្នែក។ ក្នុងពេលយូរអង្វែង វាបណ្តាលឱ្យមានជំងឺរ៉ាំរ៉ៃ ដូចជា មហារីក និងពិការភាពពីកំណើត។[22]

### ១.៣.៣.ការចោលសំរាមមិនបានត្រឹមត្រូវ

ការចោលសំរាមផ្តេសផ្តាស វាគឺជាប្រភពរាយប៉ាយដែលបង្កឱ្យមានការបំពុលដោយសារធាតុបំពុលដីច្រើនកន្លែងហើយមានការហូរធ្លាក់ចូលទៅក្នុងទឹកដែលបង្ក ឱ្យមានការបំពុលធ្វើឱ្យទឹកមានក្លិនមិនល្អ។ ការប្រើប្រាស់ធនធានហួសកំរិត និងការបង្កើតប្លាស្ទិកកំពុងបង្កើតឱ្យមានវិបត្តិនៃ ការចោលសំរាមទូទាំងពិភពលោក។ ប្រទេសកំពុងអភិវឌ្ឍន៍មានកេរ្តិ៍ឈ្មោះសម្រាប់ការផលិតបរិមាណសំរាមច្រើនហួសប្រមាណ និងបញ្ចេញកាកសំណល់នេះទៅក្នុងទន្លេ ការខ្វះខ្វាយកាកសំណល់វាពិតជាមានការបង្កគ្រោះថ្នាក់យ៉ាងខ្លាំងដល់សុខភាព។ ប្លាស្ទិក អាហារការវេចខ្ចប់ និងកាកសំណល់អេឡិចត្រូនិចដែលមានតំលៃថោកគំរាមកំហែងដល់សុខុមាលភាពរបស់មនុស្ស ។ សំរាមមិនត្រឹមតែធ្វើឱ្យមានផលប៉ះពាល់ទៅដល់បរិស្ថាន សោភ័ណភាព និងបង្កឱ្យអាប់អួដល់បរិយាកាសជុំវិញនោះទេ តែវាថែមទាំងបណ្តាលឱ្យមានជំងឺផ្សេងៗទៀតបាន និងបង្កឱ្យមានគ្រោះថ្នាក់យ៉ាងខ្លាំងចំពោះសុខភាពមនុស្សតាមរយៈ ការប៉ះពាល់ដោយផ្ទាល់ ឬតាមការភាយក្លិនស្អុយនៃសំរាមដែលរលួយ ការចោលកាកសំណល់ គឺជាបញ្ហាបរិស្ថានមួយដែលកំពុងប្រឈមខ្លាំងបំផុតនាពេលបច្ចុប្បន្ននេះ។[23]

➢ **ការវេចខ្ចប់ និងការទុកដាក់កាកសំណល់មិនត្រឹមត្រូវ**

ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញមួយចំនួន នៅតែមិនទាន់យល់ដឹងពីសារៈសំខាន់នៃការវេចខ្ចប់ និងទុកដាក់សំរាមរបស់ខ្លួនឱ្យបានត្រឹមត្រូវនោះទេ។ ជាធម្មតាប្រជាពលរដ្ឋវេចខ្ចប់ កាកសំណល់ គ្រប់ប្រភេទជាមួយគ្នា នៅក្នុងថង់ប្លាស្ទិកតែមួយ ដែលធ្វើឱ្យវាមាន ការលំបាកក្នុង ការញែក កាកសំណល់ចេញពីគ្នាសម្រាប់ការកែច្នៃ និងទុកដាក់។ លើសពីនេះទៅទៀត ប្រជាពលរដ្ឋមួយចំនួន បានរក្សាកាកសំណល់ របស់ខ្លួននៅមុខផ្ទះរបស់ពួកគេដោយរងចាំអ្នកប្រមូលសំរាមមកប្រមូល តាមកាលវិភាគ។ ប្រសិនបើ អ្នកប្រមូលសំរាមខកខានមិនបានមកប្រមូលតាមពេលវេលា នោះកាកសំណល់ទាំងនោះ ត្រូវទុកចោលទីនោះតែម្តង។ កាន់តែអាក្រក់ ជាងនោះទៅទៀត ប្រជាពលរដ្ឋមួយចំនួន ពុំរក្សាកាកសំណល់របស់ខ្លួននៅមុខផ្ទះរបស់ពួកគេទេ ប៉ុន្តែពួកគេបានបោះចោលនៅលើចិញ្ចើមផ្លូវ និងដីកន្លែងទំនេរតាមទីសាធារណៈផ្សេងទៀត។ នេះជា

[22] គេហទំព័រ ការគ្រប់គ្រងនិងការដាក់កាកសំណល់រួមគ្នាមិនបានល្អ - Hesperian Health Guides ដកស្រង់នៅថ្ងៃទី ១៤មិថុនា ឆ្នាំ ២០២១

[23] គេហទំព័រ ការចោលកាកសំណល់ពុលដោយគ្មានសុវត្ថិភាព - Hesperian Health Guides ដកស្រង់នៅថ្ងៃទី ១៤មិថុនា ឆ្នាំ២០២១

រឿងធម្មតាទៅហើយ គេតែងតែឃើញគំនរសំរាមធំៗ ត្រូវបានដាក់ចោលលើផ្លូវសាធារណៈនាពេលយប់។ ហើយមិនតែប៉ុណ្ណោះ នាពេលយប់ គេក៏ឃើញមានអ្នកដើររើកកាយសំរាម ដែលដើររើករកាយ រកកាកសំណល់ផ្សេងៗ ដែលអាចយកទៅកែច្នៃ សម្រាប់លក់ដូរ។ ទង្វើរទាំងនេះហើយ ដែលធ្វើឱ្យសំរាម ត្រូវបានខ្ចាត់ខ្ចាយនៅគ្រប់ទីកន្លែង ហើយវាគឺជាការងារលំបាកមួយក្នុងការប្រមូលសំរាមទាំងនោះ។[24]

➢ **វិធីសាស្ត្រនៃការកែច្នៃកាកសំណល់នៅមានកំណត់**

បច្ចុប្បន្ននេះវិធីសាស្ត្រដ៏សំខាន់ នៃការចោលសំរាមនៅក្នុងរាជធានីភ្នំពេញ គឺមានតាមរយៈការ បញ្ជូនកាកសំណល់ទៅកន្លែងចាក់សំរាមជើងឯកដែលមានចំងាយប្រមាណជា ១៥ គីឡូម៉ែតពីចំណុច កណ្តាលនៃរាជធានីភ្នំពេញ។ ទីតាំងចាក់សំរាមនេះ ជាកន្លែងដែលត្រូវបានគេប្រើប្រាស់នៅក្នុងឆ្នាំ ២០០៩ ក្នុងគោលបំណងដើម្បីជំនួសតំបន់ចាក់សំរាមស្ទឹងមានជ័យ ។ ហើយទីនោះពុំមានប្រព័ន្ធកែច្នៃ ឬ ផលិតកាកសំណល់នោះទេ។ មានដូចជា កាកសំណល់គ្រោះថ្នាក់ត្រូវបានដុតនៅទីនោះ ជាមួយ និងកាកសំណល់ជាច្រើនប្រភេទទៀត។

ជាលទ្ធផល វាបានជះផលអវិជ្ជមានប៉ះពាល់ ដល់សុខភាពរបស់មនុស្សក៏ដូចជាបរិស្ថាន។ លើសពីនេះទៀត សារធាតុដីជាច្រើនដែលនឹងមានសក្តានុពល ត្រូវបានបាត់បង់ សម្ភារៈសរីរាង្គ ដែលអាចផ្តល់ប្រយោជន៍មួយចំនួន ត្រូវបានបោះចោលជាមួយ និងកាកសំណល់ទាំងនោះ។ ដោយសារតែវិធីសាស្ត្រ ការកែច្នៃកាកសំណល់មានកំណត់ រាជធានីភ្នំពេញមិនអាច ធ្វើការប្រើប្រាស់ធនធានពីកាកសំណល់ទាំងនោះ ឱ្យមានប្រសិទ្ធិភាពនោះឡើយ។ [25]

➢ **ការទុកដាក់កាកសំណល់នៅក្រៅធុងសំរាម**

សម្រាប់នៅក្នុងរាជធានីភ្នំពេញ មិនមែនជារឿងចំឡែកនោះទេ ដោយឃើញសំរាមជាថង់ប្លាស្ទិកហោះហើរពាសវាលពាសកាលជាមួយ និងគំនរសំរាមផ្សេងៗជាច្រើនទៀតតាមទីកន្លែង សាធារណៈ ផ្សេងៗ។ មិនមែនមនុស្សគ្រប់គ្នាក្នុងរាជធានីភ្នំពេញសុទ្ធតែបានបោះសំរាម ក្នុងធុងសំរាមសំរាម ឱ្យបានត្រឹមត្រូវនោះទេ។ ជាក់ស្តែង ធុងសំរាមត្រូវបានដាក់នៅតាមកន្លែងសាធារណៈស្ទើរតែគ្រប់ទិសទីក៏ដោយ ក៏ប្រជាពលរដ្ឋនៅតែបន្តការចោលសំរាមនៅកន្លែងណាដែលពួកគេចង់ ដោយគ្មានសណ្តាប់ធ្នាប់ដដែរ។ ហើយអ្នកខ្លះទៀតបានបោះសំរាមចេញពីរថយន្ត ឬ ម៉ូតូរបស់ពួកគេខណៈពេលដែលពួកគេកំពុងបើកបរក៏មាន។ ចំណែកឯអ្នកខ្លះទៀតបានចោលសំរាមរបស់ពួកគេនៅលើស្មួនសាធារណៈក្បែរធុងសំរាម ដោយមិនបានដាក់ចូលទៅក្នុង

[24] គេហទំព័រ សំរាមកំពុងក្លាយជាបញ្ហាក្តៅ | Radio Veritas Asia (rvasia.org)ដកស្រង់នៅថ្ងៃទី១៥ មិថុនា ឆ្នាំ២០២១

[25] គេហទំព័រ កម្មវិធីកាកសំណល់រឹង ក្នុងសហគមន៍ - Hesperian Health Guidesដកស្រង់នៅថ្ងៃទី១៥ មិថុនា ឆ្នាំ២០២១

ធុងសំរាមអោយបានត្រឹមត្រូវនោះឡើយ។ ជាលទ្ធផល កាកសំណល់ ទាំងនោះមិនត្រូវបានប្រមូល និង សំអាតនោះឡើយ។ ទាំងអស់នេះហើយ ដែលធ្វើអោយរាជធានីភ្នំពេញ បាត់បង់សោភ័ណភាព និងជាសុខភាព។ វាគឺជាការពិតដែលមិនអាចប្រកែកបាននោះទេ ដែលថាបញ្ហាទាំងនេះបានកើតមានជាយូរមកហើយ ហើយយើងក៏កំពុងតែនៅរង់ចាំដំណោះស្រាយដ៏មានប្រសិទ្ធិភាពផងដែរ។[26]

### ១.៣.៤.ផលប៉ះពាល់នៃការដុតសំរាម

យើងសង្កេតឃើញថា នៅក្នុងរយៈពេលប៉ុន្មាន ឆ្នាំចុងក្រោយនេះ ការដុតសំរាមនៅទីក្រុង និងទីប្រជុំជនហាក់ដូចជាមិនអាចធ្វើទៅរួចឡើយ ពីព្រោះប្រជាពលរដ្ឋបារម្ភពីសុវត្ថិភាពអគ្គិភ័យ។ ប៉ុន្តែចំពោះទីជនបទវិញ ការដុតសំរាមនៅតែត្រូវបានអនុវត្តនៅតាមភូមិដ្ឋាន ដោយពួកគាត់គិតថា ការដុតសំរាមអាចជាវិធីដ៏ល្អមួយដើម្បីសម្អាតទីធ្លាជុំវិញខ្លួន ប៉ុន្តែផ្ទុយទៅវិញវាក៏ផ្តល់ផលអាក្រក់ចំពោះបរិស្ថាន និងសុខភាពមនុស្សផងដែរ។ តាមរយៈការសម្ភាសរបស់កាសែត ភ្នំពេញប៉ុស្តិ៍បានបញ្ជាក់ប្រាប់ថា៖ «នៅរាល់ពេលដែលមានសំណល់ឆេះ មិនថាកើតដោយការដុតរបស់មនុស្ស ឬក៏ពីធម្មជាតិទេ វានឹងភាយសារធាតុកាបូនឌីអុកស៊ីត និងអាស៊ីតក្លរ ដែលអាចបំពុលដល់បរិស្ថាន បញ្ហាប្រឈមរបស់មនុស្សយើង គឺនៅពេលដែលយើងដកដង្ហើមស្រូបយកសារធាតុពុលទាំងនោះចូលក្នុងខ្លួនដែលនាំឱ្យជំងឺផ្លូវដង្ហើមជាដើម បញ្ហាមួយទៀត គឺផ្សែងពុលទាំងនោះ ក៏រួមមានសារធាតុបារ៉ែត និងអាស៊ីតផងដែរ ទាំងអស់នេះសុទ្ធតែជាផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន និងសុខភាពមនុស្ស»។[27]

ការដុតសំរាមនៅទីវាល ឬនៅទីលានចាកសំរាមបានបញ្ចេញនូវសារធាតុបំពុលខ្យល់ និងផេះ ព្រមទាំងផ្សែងក្រាស់ជាច្រើន។ ផេះដែលបានមកពីការដុតសំរាមលាយឡំជាមួយសារធាតុគីមីដែលមានជាតិពុល ដូចជា សារធាតុពុល ឌីអុកស៊ីត សារធាតុ ហ្វារ៉ាត អ៊ីដ្រូកាបូន និងសារធាតុដែលធ្វើអោយមានជម្ងឺមហារីកផ្សេងៗ។

លើសពីនេះទៅទៀត ផ្សែងអាចមាន សារធាតុអាល់ដេហ៊ីដ ជាតិអាស៊ីត ជាតិនីត្រូសែនអុកស៊ីន ស៊ុលហ្វរអុកស៊ីត កាបូនម៉ូនូអុនស៊ីត និងសារជាតិគីមីផ្សេងៗទៀត។

---

[26] គេហទំព័រ https://www.rasmeinews.com/archives/371276ដកស្រង់នៅថ្ងៃទី ១៥ មិថុនាឆ្នាំ ២០២១

[27] គេហទំព័រ ឥទ្ធិពលនៃសារធាតុពុលចេញពីផ្សែងសំរាម ចំពោះជីវិតមនុស្ស និងបរិស្ថាន | ភ្នំពេញ ប៉ុស្តិ៍ (postkhmer.com) ដកស្រង់នៅថ្ងៃទី ១៥ មិថុនាឆ្នាំ ២០២១

➢ ផលប៉ះពាល់ចំពោះសុខភាពមនុស្ស

- វត្ថុដែលមានសារធាតុពុល អាចបណ្ដាលឲ្យមានបញ្ហារលោក ព្រមទាំងមានបញ្ហាស្បែកនិងផ្លូវដង្ហើម។ ភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ទាំងនេះនឹងអាស្រ័យទៅលើះ ចំងាយពីកន្លែងដុត រយៈពេលនៃការនៅជិតកន្លែងដុតសំរាម បរិមាណ និងប្រភេទសំរាមដែលបានដុត និងភាពរំញោច របស់មនុស្សម្នាក់។
- បុគ្គលដែលមានបញ្ហាផ្លូវដង្ហើម ដូចជាជម្ងឺហឺត ឬ មានបញ្ហាអាលែហ្សី ទំនងជាមានភាពរំញោចខ្លាំងចំពោះផ្សែងដែលបង្កឡើងដោយការដុតសំរាម។
- ឧស្ម័នពុលកាបូនម៉ូនូអុកស៊ីត ធ្វើអោយមនុស្សខ្វះគ្រាប់ ឈាមក្រហម ខ្វះអុកស៊ីសែន ដែលធ្វើអោយមនុស្សខូចសុខភាព ជាពិសេសមនុស្សចាស់ជរា និងកុមារកំពុងលូតលាស់រាងកាយ
- ផ្សែង នៅពេលមានប្រតិកម្មជាមួយទឹក បង្កទៅជាអាស៊ីត ដែល ធ្វើអោយប៉ះដល់ជីវិតមនុស្ស សត្វ និងធម្មជាតិ ។
- ផេះ ដែលក្លាយជាកាក់សំណល់មានជាតិពុលឌីអុកស៊ីត និង លោហពុល (លោហធ្ងន់) ដូចជាសំណបារ៉ត អាសេនិច ដែល ធ្វើអោយមនុស្សកើតជំងឺលើសឈាម ឈឺក្បាល អស់កំលាំង រលោក សន្លាក់ដៃជើងរាំរ៉ៃ។

# ជំពូកទី២

# ដំណោះស្រាយ និងវិធានការណ៍នៃការ
# គ្រប់គ្រងកាកសំណល់រឹងនៅរាជធានីភ្នំពេញ

# ជំពូកទី២

# ដំណោះស្រាយ និងវិធានការណ៍នៃការគ្រប់គ្រងភាគសំណល់រឹងនៅរាជធានីភ្នំពេញ

## ២.១. វិធានការណ៍នៃការគ្រប់គ្រងសំណល់រឹង

### ២.១.១. ការធ្វើឱ្យប្រសើរឡើងនូវសេវាប្រមូលសំណល់ និងការសម្អាត

សេវាប្រមូលនិង សម្អាតគឺជាសកម្មភាពដ៏សំខាន់ដើម្បីធានាបាននូវ បរិស្ថានស្អាត អនាម័យ និង សោភ័ណភាពរបស់ទីក្រុង។

- ការវាយតំលៃពីប្រសិទ្ធិភាពរបស់ក្រុមហ៊ុនប្រមូលសំណល់
- ការកែលំអឱ្យមានការសហការគ្នារវាងក្រុមហ៊ុនប្រមូល ( ក្រុមហ៊ុនស៊ីនទ្រី និងក្រុមហ៊ុនដទៃទៀត ) និង រដ្ឋបាលខណ្ឌ៖
  - ការរៀបចំកាលវិភាគប្រមូលសំរាម
  - ចាត់ចែងទីតាំងប្រមូល
  - ទីតាំងស្តុកសំរាមបណ្តោះអាសន្ន
  - រៀបចំផែនការ កាលវិភាគ បោសសំអាតតាមដងផ្លូវ និងតាមទីសាធារណៈ
  - វិសាលភាពតំបន់សំអាត
  - ការគាំទ្រពីអាជ្ញាធរមូលដ្ឋាន ក្នុងការងារអនុវត្តន៍ និងរៀបចំទីតាំង
  - ត្រួតពិនិត្យតម្លាភាពសេវា
- បង្កើតប្រសិទ្ធិភាពក្នុងការទំនាក់ទំនងល្អ រវាងអាជ្ញាធររាជធានី និងក្រុមហ៊ុនប្រមូលសំរាម ដើម្បីត្រួត ពិនិត្យការប្រមូលសំណល់ ក្រុមហ៊ុនប្រមូលសំរាម គួរប្រើប្រាស់ប្រព័ន្ធបច្ចេកទេស គ្រប់គ្រងទិន្នន័យ ដើម្បីឱ្យគេអាចតាមដាន និងវាយតម្លៃការ ធ្វើផែនការដាក់ពេលវេលាប្រមូលឱ្យបានត្រឹមត្រូវ
- ការពិនិត្យឡើងវិញ នៅថ្លៃសេវាកម្ម ដើម្បីឱ្យការប្រមូលសំរាមមានប្រសិទ្ធិភាពខ្ពស់ ថ្លៃសេវាកម្មដែល អាចធ្វើបាន ដើម្បីកំណត់ថ្លៃឈ្នួលសេវាកម្មដែលមានភាពជាក់លាក់មួយក្នុងការធានាឱ្យបាននូវនិរន្ត ភាព និងភាពពេញលេញនៃការប្រមូលសំរាមដែលផ្តល់ឱ្យអតិថិជន។
- ត្រូវធានាការប្រមូលដឹកជញ្ជូនសំរាម សំណល់រឹងទៅកាន់ទីលានទុកដាក់សំរាម សំណល់រឹង កុំឱ្យ ជ្រុះ រាយប៉ាយលើផ្លូវ កុំឱ្យហូរស្រក់ទឹកសំណល់ធ្លាក់មកលើទ្រូងផ្លូវ និងត្រូវបោសសម្អាតកន្លែង ដែលប្រមូល នោះឱ្យបានស្អាតល្អ។

➢ ត្រូវធានាបោសសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង នៅតាមដងផ្លូវនីមួយៗឱ្យបានស្អាត និងគោរពទៅតាមម៉ោងពេលនៃកម្មវិធីដែលបានកំណត់។[28]

**ចំណាំ៖** ការដាក់ឱ្យមានការដេញថ្លៃ សាលារាជធានីភ្នំពេញ និងវាយតម្លៃនូវលទ្ធភាពនៃការដាក់ឱ្យមានការដេញថ្លៃប្រកបដោយការប្រកួតប្រជែងទៅលើក្រុមហ៊ុនដែលផ្ដល់សេវាប្រមូលសំរាម។ យុទ្ធសាស្ត្រមួយនេះ រដ្ឋាភិបាលអាចបែងចែកទីតាំងនៅក្នុងរាជធានីភ្នំពេញជាច្រើនតំបន់ ( ខណ្ឌ\ សង្កាត់ ) ហើយប្រកាសឱ្យក្រុមហ៊ុននានាដាក់ពាក្យថ្លៃសម្រាប់តំបន់នីមួយៗ។ ដំណើរការនេះ និងធ្វើឱ្យរដ្ឋាភិបាលពិនិត្យមើលនូវសកម្មភាពគ្រប់ក្រុមហ៊ុនទាំងអស់និងជ្រើសរើសយកក្រុមហ៊ុនដែលល្អជាងគេ។ បន្ថែមពីនេះការដែលអនុញ្ញាតឱ្យក្រុមហ៊ុនតែមួយទទួលបានខុសត្រូវសម្រាប់តំបន់ណាមួយជាក់លាក់នោះ និងមានការជំរុញឱ្យក្រុមហ៊ុនទាំងអស់អនុវត្តន៍សេវាកម្មប្រមូលសំរាមមានប្រសិទ្ធិភាពល្អ។ ការជំរុញវិនិយោគក្នុងវិស័យនេះក៏អាចកសាង និងបង្កើតគុណភាពតម្លៃសំណល់ក្នុងទីផ្សារ។

### ២.១.២. ការកែប្រែឥរិយាបថការបញ្ចេញសំណល់និងកន្លែងទុកដាក់សំណល់

ការកែប្រែឥរិយាបថ ឬទំលាប់ ក្នុងការវេចខ្ចប់ ទុកដាក់និងបញ្ចេញឱ្យបានត្រឹមត្រូវទៅតាមកន្លែង និងពេលវេលាដែលបានកំណត់គឺជាកត្តាសំខាន់ឆ្ពោះទៅរកភាពជោគជ័យ។

➢ ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការវេចខ្ចប់ដោយថង់ ឬការដាក់នៅក្នុង ធុងសំរាមផ្ទាល់ខ្លួននូវសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងលក្ខណៈហ្មត់ចត់ មិនឱ្យលេចធ្លាយ មិនឱ្យលេចជ្រាបទឹកស្អុយ ឬមិនឱ្យមានភាយក្លិនស្អុយក្នុងរយៈពេលនៃការទុកដាក់រងចាំការបញ្ចេញទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។ [29]

➢ ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការរក្សាទុកនូវកញ្ចប់ ឬធុងផ្ទុកសំរាមសំណល់រឹងរបស់ខ្លួននៅក្នុងរបង ឬបរិវេណនៃលំនៅដ្ឋាន អគារ ឬទីតាំងរបស់ខ្លួន និងត្រូវបញ្ចេញទៅតាមពេលម៉ោងដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។
រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការណ៍ត្រួតពិនិត្យឱ្យបានម៉ឺងម៉ាត់លើការអនុវត្តការបញ្ចេញកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជនទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈរង់ចាំការប្រមូល និងដឹកជញ្ជូនទៅតាមពេលម៉ោងដែលបានកំណត់។[30]

[28] ដកស្រង់ចេញពី សេចក្តីណែនាំ ស្តីពី ការគ្រប់គ្រង កាកសំណល់រឹង នៅរាជធានីភ្នំពេញ
[29] មាត្រា ១៦ នៃអនុក្រឹត្យលេខ ១១៣ អនក្រ. ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
[30] មាត្រា ១៧ នៃអនុក្រឹត្យលេខ ១១៣ អនក្រ. ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- ការផ្សព្វផ្សាយពត៌មានស្តីពីកម្មវិធី គ្រប់គ្រងសំណល់ និងការបញ្ចេញសំណល់
  - ផ្សព្វផ្សាយពត៌មាននេះទៅដល់ប្រជាពលរដ្ឋ
  - យុទ្ធនាការបង្រៀបការយល់ដឹង និងការអនុវត្តន៍
  - យុទ្ធនាការផ្សព្វផ្សាយតាមសង្គម ហ្វេសប៊ុក
  - បញ្ចូលក្នុងកម្មវិធីអប់រំ។
- សម្ភារៈទុកដាក់សំណល់ ត្រូវរៀបចំឱ្យបានសមស្របទៅតាមវិធីសាស្ត្រនៃការប្រមូលសំណល់
  - បន្តអនុវត្តមធ្យោបាយប្រមូល ពីផ្ទះមួយទៅផ្ទះមួយនៅទីប្រជុំជនក្រុង និងធុង\គំនរសំរាមនៅតំបន់ជាយក្រុង
  - រៀបចំកាលវិភាគប្រមូលឱ្យស៊ីចង្វាក់និងការបញ្ចេញ និងទីតាំងបញ្ចេញ
  - រៀបចំកាលវិភាគប្រមូលសំណល់ផ្សេងៗពីគ្នា (សំណល់កែច្នៃ សំណល់គ្រោះថ្នាក់ និងសំណល់ធំៗ )
- ពង្រឹងវិធាន ការបោះចោលសំណល់ខុសច្បាប់
  - ការដំឡើងផ្ទាំងស្លាកសញ្ញា ហាមចោលសំរាមផ្តេសផ្តាសភ្នំពេញ
  - យន្តការដាក់ពិន័យជាសាច់ប្រាក់
  - ពង្រឹងការអនុវត្តន៍ច្បាប់
  - ដំឡើងវិដេអូ កាមេរ៉ា នៅទីសាធារណៈ។

### ២.១.៣. ការទទួលខុសត្រូវរបស់ក្រុមហ៊ុនឯកជន

ក្រុមហ៊ុនប្រមូលសំរាមឯកជន មានតួនាទីនិងភារកិច្ចដូចខាងក្រោម

- ធ្វើប្រតិបត្តិការបោសសម្អាតតាមដងមហាវិថី និងវិថីនានា និងការប្រមូលសំរាមនៅ តាមទីផ្សារ ផ្ទះភោជនីយដ្ឋាន និងតំបន់អាជីវកម្មនានា។
- ផ្សព្វផ្សាយពីកាលវិភាគប្រមូលសំរាមសម្រាប់សហគមន៍ផ្សេងៗគ្នាតាមវិធីដែលច្បាស់លាស់ និងមានតម្លាភាពមិនថា ការផ្សព្វផ្សាយនៅលើអ៊ិនធឺណិត ឬនៅការិយាល័យរដ្ឋបាល។
- អនុវត្តតាមកាលវិភាគប្រមូលសំរាម និងធ្វើបច្ចុប្បន្នភាពប្រសិនបើមានការផ្លាស់ប្តូរណាមួយត្រូវបានធ្វើឡើង។
- ប្រមូលសំរាមទាំងអស់ដែលបានទុកនៅខាងក្រៅ ដើម្បីប្រមូល និងការប្រមូលនោះប្រកបដោយស្តង់ដារ។
- ផ្តល់សេវាអតិថិជនទៅដល់ប្រជាពលរដ្ឋ។

- ត្រូវរៀបចំ និងធ្វើបច្ចុប្បន្នភាពកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ឱ្យបានច្បាស់លាស់ និងសមស្របតាមស្ថានភាពភូមិសាស្រ្ត ដោយមានការពិគ្រោះយោបល់ និងឯកភាពពីអាជ្ញាធរសង្កាត់ ខណ្ឌ និងរដ្ឋបាលរាជធានីភ្នំពេញ។
- ត្រូវផ្សព្វផ្សាយកម្មវិធី និងកាលវិភាគប្រមូលសំរាម សំណល់កែច្នៃ សំណល់គ្រោះថ្នាក់ ឱ្យដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដោយសហការជាមួយរដ្ឋបាលខណ្ឌ សង្កាត់មានសមត្ថកិច្ច
- ត្រូវរៀបចំដាក់ធុងសំរាមនៅតាមទីធ្លាសាធារណៈ សួនច្បារ និងតាមផ្លូវសាធារណៈសំខាន់ៗឱ្យទៅតាមប្រភេទសំរាម និងសំណល់រឹងនីមួយៗ ។[31]

## ២.២.វិធានការណ៍នៃការដោះស្រាយកាកសំណល់រឹង

### ២.២.១. ការគ្រប់គ្រងសំណល់រឹង

ការគ្រប់គ្រងកាកសំណល់រឹង គឺសំដៅទៅលើសកម្មភាពផ្សេងៗ ដូចជា ការញែកសំណល់ ការស្តុក បណ្តោះអាសន្ន ការប្រមូល ការដឹកជញ្ជូន ការកែច្នៃឡើងវិញ ។ ជាការពិតណាស់ជាទូទៅសំណល់រឹងត្រូវបានគេចាត់ទុកថា គឺសំណល់ចុងក្រោយដែលគ្មានតម្លៃពីការប្រើប្រាស់។ ប៉ុន្តែលោកអ្នកត្រូវយល់ថានៅក្នុងនោះសំណល់អាចត្រូវបានកែច្នៃ និងមានប្រយោជន៍ជាលើកចុងក្រោយដោយយោងទៅលើប្រភពបង្កើតសំណល់ ការចេះទុកដាក់ឱ្យមានសណ្តាប់ធ្នាប់ជាពិសេសការចេះបែងចែកសំណល់។[32]

#### ២.២.១.១.ការញែកកាកសំណល់

ការញែកសំណល់នៅតាមលំនៅដ្ឋានគឺ ដើម្បីកាត់បន្ថយនូវបរិមាណសំណល់ដែលត្រូវយកទៅចាក់ចោលនៅទីតាំងចាក់សំណល់រឹង។ មានដូចជា៖

- **ការញែកសំណល់ដែលប្រកបដោយគ្រោះថ្នាក់ចេញពីសំណល់ដែលមិនគ្រោះថ្នាក់** ៖ ទោះបីជានៅតាមលំនៅដ្ឋានរបស់ ប្រជាពលរដ្ឋ មិនមែនជាប្រភពចម្បងដែលបង្កើតឡើងនូវសំណល់គ្រោះថ្នាក់ក៏ដោយក៏ប៉ុន្តែវាក៏មានប្រភេទសំណល់មួយចំនួន ដូចជា ថ្មពិល អាគុយ សំណល់ថ្នាំពេទ្យដែលសេសសល់ពីការប្រើប្រាស់ ឬផុតកាលកំណត់នៃការប្រើប្រាស់ សំណល់ថ្នាំសម្លាប់សត្វ និងកំប៉ុង ដែលមានដាក់សារធាតុគីមីមួយចំនួនទៀតដែលមានផ្ទុកនូវសារធាតុពុល។ ដូច្នេះសំណល់វត្ថុទាំងនោះគួរតែញែកចេញឱ្យដាច់ពីគ្នារវាង សំណល់ធម្មតា។ លើសពីនេះទៅទៀតសំណល់ធម្មតាដែលអាចយកទៅប្រើក្នុងគោលបំណងផ្សេងទៀតបាន គួរតែញែកចេញពី សំណល់ដែលត្រូវបោះចោល។

[31]ដកស្រង់ចេញពី សេចក្តីណែនាំ ស្តីពី ការគ្រប់គ្រង់ កាកសំណល់រឹង នៅរាជធានីភ្នំពេញ

[32]គេហទំព័រ ការគ្រប់គ្រងសំណល់រឹង | កំណត់ត្រាសិលា (wordpress.com) ដកស្រង់នៅថ្ងៃទី១២ មិថុនា ឆ្នាំ២០២១

ដូចជាថង់ប្លាស្ទិក និងកញ្ចប់មួយចំនួន យើងអាចយកទៅលាងសម្អាតដើម្បីទុកប្រើប្រាស់ឡើងវិញ ចៀសវាងការទិញស្បោង ឬប្រអប់មកទុកប្រើប្រាស់។

- **ការញែកសំណល់សម្រាប់កែច្នៃ** ៖ គឺជាការញែកសំណល់រឹង ដូចជាក្រដាស កំប៉ុងអាលុយមីញ៉ូម អំបែងដប ឬកែវ និង សារធាតុប្លាស្ទិកចេញពីគ្នា។ រីឯប្រភពបង្កើតសំណល់រឹងដើម្បីយកទៅកែច្នៃ គឺជាមធ្យោបាយល្អ ប្រសើរមួយដើម្បីសន្សំសំចៃវត្ថុធាតុដើម មានន័យថាយើងអាចកាត់បន្ថយការទាញយកធនធានធម្មជាតិយកមកប្រើប្រាស់។ ទន្ទឹមនឹងការញែកសំណល់ទាំងនេះ បញ្ហា ដែលយើងត្រូវគិតគូរ គឺថា យើងត្រូវទុកដាក់វាបែបណា មុនពេលដែលសេវាកម្មនៃការប្រមូលសំណល់ ឬសំរាមបានមកដល់។
- **ការញែកសំណល់ដែលនៅតាមទីសាធារណៈ** រោងចក្រ សហគ្រាស និងអគារពាណិជ្ជកម្ម មានភាពលំបាក និងស្មុគស្មាញជាងតាមលំនៅដ្ឋាន ដោយទីនោះជាកន្លែង ដែលមមាញឹក និងមានទំនាក់ទំនងទៅ នឹងប្រជជនទូទៅ។ ដូច្នេះការញែកសំណល់នេះវាទាក់ទងទៅ នឹងឥរិយាបថ ការយល់ដឹងរបស់ប្រជាពលរដ្ឋ និងស្មារតីចូលរួមក្នុងសកម្មភាពនៃការញែកសំណល់នេះ។[33]

**២.២.១.២. ការស្តុកទុកបណ្តោះអាសន្ន**

ការស្តុកទុកបណ្តោះអាសន្ន គឺសំដៅទៅលើការស្តុកទុកក្នុងរយៈពេលខ្លីមួយ ដើម្បីរង់ចាំសេវានៃការប្រមូលយកទៅចាក់ចោលនៅទីតាំងចាក់សំណល់។ ការស្តុកទុកគួរតែរក្សាទុកក្នុងធុងដែលមានគម្របត្រឹមត្រូវ និង (ងាយស្រួលដល់ការលើកដាក់ចំពោះអ្នកប្រមូលសំណល់) និងអាចដាក់សំណល់គ្រប់គ្រាន់ទៅតាមរយៈពេលនៃការស្តុកទុករង់ចាំសេវាកម្មប្រមូល។ ចំណែកឯប្រភេទធុង គួរតែជ្រើសរើសធុងដែលមាំប្រើជាប់បានយូរតែមានទម្ងន់ស្រាល ដើម្បីងាយស្រួលដល់ការផ្ទេរសំណល់ពីកន្លែងមួយទៅកន្លែងមួយទៀត ឬទៅធុងផ្សេងទៀត។នៅទីតាំងផ្សេងដូចជាតាមផ្សារក៏ដូចជាតាមទីសាធារណៈដែរ ការរក្សាទុកគួរតែរៀបចំទុកដាក់ក្នុងធុងឱ្យបានត្រឹមត្រូវ ចៀសវាងការគរជាគំនរចោលនៅលើដី ពីព្រោះការគរចោលបែបនេះនឹងត្រូវធ្វើឱ្យរាយប៉ាយដោយសព្វពាហនៈ ដែលទៅកក្ទូរកកាយ រកចំណី និងមនុស្សមួយចំនួនទៅកកាយ ដើម្បីរកវត្ថុដែលអាចយកទៅកែច្នៃបាន។ លើសពីនេះទៅទៀតសំណល់ដែលមិនបានទុកដាក់ ត្រឹមត្រូវអាចប៉ើងតាមខ្យល់ និងជះក្លិនមិនល្អដល់បរិស្ថាន។ ការដាក់ធុងនៅតាមដងផ្លូវសាធារណៈ ឬសួនច្បារត្រូវដាក់ឱ្យបានគ្រប់គ្រាន់ ហើយដាក់នៅកន្លែងដែលសមរម្យមិនបង្ក ឱ្យប៉ះពាល់ដល់សុវត្ថិភាពសណ្តាប់ធ្នាប់ និងប៉ះពាល់ដល់ចរាចរ។[34]

[33]គេហទំព័រ ការគ្រប់គ្រងសំណល់រឹង | កំណត់ត្រាសិលា (wordpress.com) ដកស្រង់នៅថ្ងៃទី១២ មិថុនា ឆ្នាំ២០២១

[34] គេហទំព័រ ការគ្រប់គ្រងសំណល់រឹង | កំណត់ត្រាសិលា (wordpress.com) ដកស្រង់នៅថ្ងៃទី១២ មិថុនា ឆ្នាំ២០២១

### ២.២.១.៣.ការប្រមូល និងការដឹកជញ្ជូន

ការប្រមូល និងការដឹកជញ្ជូនសំណល់រឹងមានភាពស្មុគ្រស្មាញ និងសាំញ៉ាំដោយសារការបញ្ចេញសំណល់មាននៅគ្រប់ទីកន្លែងទាំងអស់ទាំងលំនៅដ្ឋាន ទីផ្សារ រោងចក្រ សហគ្រាស ផ្លូវថ្នល់ និងទីសាធារណៈផ្សេងៗទៀត។ ការប្រមូលសំណល់រឹង គឺផ្សារភ្ជាប់នៅនិងការដឹកជញ្ជូនផងដែរ ចំណែកឯមធ្យោបាយ និងវិធីសាស្ត្រក្នុងការប្រមូល គឺមានការប្រែប្រួលទៅតាមទីតាំង និងស្ថានភាពនៃកន្លែងបង្កើតសំណល់នោះ។ បណ្តាប្រទេសមួយចំនួននៅអាស៊ីបានអនុវត្តវិធីសាស្ត្រផ្សេងៗក្នុងការប្រមូលដូចជា ការប្រមូលនៅតាមលំនៅដ្ឋាន ការប្រមូលតាមសហគមន៍នីមួយៗរបស់ប្រជាពលរដ្ឋ។

- ➢ ការប្រមូលតាមលំនៅដ្ឋាន សេវាកម្មនៃការប្រមូលសំណល់នៅចូលទៅប្រមូលតាមផ្ទះនីមួយៗរបស់ប្រជាពលរដ្ឋ។
- ➢ ការប្រមូលតាមគមនាគមន៍ សេវាកម្មនៃការប្រមូលសំណល់ចូលទៅប្រមូលនៅតាមទីតាំងស្តុករួមនៅ តាមសហគមន៍។
- ➢ ការប្រមូលតាមដងផ្លូវ សេវាកម្មនៃការប្រមូលសំណល់ចូលទៅប្រមូលនៅទីតាំងស្តុកផ្សេងៗនៅតាមដងផ្លូវ។ លើសពីនេះទៅទៀត ដើម្បីឱ្យការប្រមូលនិងដឹកជញ្ជូនសំណល់រឹងឱ្យបានស្អាតតាមកន្លែបង្កើតសំណល់រឹង គឺត្រូវអនុវត្តតាម លក្ខណៈមួយចំនួនដូចខាងក្រោម៖

❖ តាមលំនៅដ្ឋាន

- ក្រុមហ៊ុនប្រមូល និងដឹកជញ្ជូនសំណល់ត្រូវធ្វើការប្រមូលឱ្យបានទៀតទាត់ពេលវេលា និងមានកម្មវិធីប្រមូលជាក់លាក់ព្រមទាំងផ្សព្វផ្សាយជូនប្រជាជនឱ្យបានដឹងជ្រួលជ្រាប។
- ចំនួនជើងដែលត្រូវធ្វើការប្រមូលត្រូវអនុវត្តឱ្យបានសមរម្យដែលធានាពុំឱ្យមានការកកស្ទះ ឬសេសសល់ឡើយ
- ក្រុមហ៊ុនប្រមូលត្រូវរៀបចំសេចក្តីជូនដំណឹង ឬគោលការណ៍នានាទាក់ទងទៅនិងការអនុវត្តការប្រមូលរបស់ខ្លួនដោយផ្សព្វផ្សាយដល់ប្រជាជន និងអាជ្ញាធរនៅគ្រប់តំបន់ ដែលក្រុមហ៊ុនទទួលខុសត្រូវក្នុងការប្រមូល។

❖ តាមទីសាធារណៈ និងទីផ្សារ

- ត្រូវធ្វើការប្រមូល និងបោសសម្អាតជារៀងរាល់ថ្ងៃ ដើម្បីជៀសវាងការកកស្ទះសំណល់ តាមដងផ្លូវ ទីសាធារណៈ ឬតាមសួនច្បារ។ ក្នុងករណីទីលានចាក់សំណល់នៅឆ្ងាយក៏ត្រូវធ្វើការប្រមូលយកទៅចាក់នៅកន្លែងស្តុកបណ្តោះអាសន្ន ដែលមិនធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាន។

- ក្នុងករណីសំរាមពេញធុងដែលដាក់តាមដងផ្លូវ ត្រូវប្រមូលចេញដោយប្ដូរធុងថ្មី ឬបង្វិលធុងចាស់ដែលទទេមកដាក់នៅកន្លែងដដែលវិញ។ ក្នុងនោះផងដែរ ក៏ត្រូវបំផុសប្រជាពលរដ្ឋឱ្យជួយថែរក្សាធុងសំរាមសាធារណៈ។

❖ មធ្យោបាយ និងដឹកជញ្ជូន

- ប្រើប្រាស់រថយន្តមានទ្រុងជិត ហើយពេលដឹកជញ្ជូនត្រូវគ្របពីលើការពារធ្លាក់រាយប៉ាយតាមផ្លូវ
- ផ្ទុកចំណុះសមស្រប ដោយមិនឱ្យលើសចំណុះ ការពារមានបញ្ហាផ្សេងៗកើតឡើងក្នុងពេលធ្វើការដឹកជញ្ជូន។
- មានមធ្យោបាយគ្រប់គ្រាន់ក្នុងការដឹកជញ្ជូន ដោយគិតទៅដល់ពេលមានបញ្ហាខូចគ្រឿងចក្រ
- ត្រូវធ្វើការដឹកជាសំណល់ឱ្យអស់តាមកម្មវិធីដែលបានកំណត់ប្រចាំថ្ងៃ។
- ក្នុងពេលដឹកជញ្ជូន ត្រូវរក្សាភាពស្ងប់ស្ងាត់តាមដែលធ្វើទៅបាន។[35]

### ២.២.១.៤. ការកែច្នៃសំណល់

ការកែច្នៃសំណល់ គឺសំដៅលើសកម្មភាពទាំងឡាយដែលធ្វើឱ្យកាត់បន្ថយនូវបរិមាណ ឬគុណភាពនៃសំណល់រឹង ដើម្បីសម្រាលដល់ការធ្វើប្រព្រឹត្តកម្មសម្អាត ឬការបោះចោលសំណល់រឹងនៅទីលាន។ ការកែច្នៃសំណល់មានដូចជា ៖

- ការកាត់បន្ថយបរិមាណសំណល់ ៖ គឺសកម្មភាពដែលធ្វើឱ្យសំណល់មានតិច។
- ការប្រើប្រាស់ឡើងវិញ ៖ គឺការយកសំណល់មកប្រើប្រាស់ឡើងវិញ ដោយរូបរាង និងសមាសភាគនៅដដែល គឺគ្រាន់តែធ្វើប្រព្រឹត្តកម្មសម្អាត ឬលាងសម្អាត ដូចជាដប ក្រដាស ឬប្លាស្ទិក លាងសម្អាតរួចយកមកប្រើប្រាស់ឡើងវិញ។
- ការធ្វើជីកំប៉ុស្តៈ សំណល់ចេញពីលំនៅដ្ឋានភាគច្រើនជាប្រភេទសរីរាង្គ ដែលអាចយកទៅធ្វើជាជីកំប៉ុស្ត។ ជីកំប៉ុស្តគឺជាផលិតផលនៃសមាសធាតុសរីរាង្គនៅក្នុងល័ក្ខខ័ណ្ឌលំនឹងដែលអាចជួយពង្រឹងសមត្ថភាពដី និងបន្ថែមជីដល់ដីបន្ទាប់ពីបានបញ្ចប់ការ បំបែកធាតុ ឬពុករលួយក្រោមអំពើនៃបាក់តេរី ខ្យល់ និងទឹក។ សមាសធាតុសរីរាង្គដែលអាចធ្វើជាជីកំប៉ុស្តបាន មានដូចជាសំណល់ ផ្ទះបាយ លាមកសត្វ លាមកមនុស្ស បន្លែ ឬសំណល់ដំណាំ សំណល់ស្លឹកឈើ សំណល់សាច់ ឬផលិតផលនេសាទ។ [36]

[35]គេហទំព័រ ការគ្រប់គ្រងសំណល់រឹង | កំណត់ត្រាសិលា (wordpress.com) ដកស្រង់នៅថ្ងៃទី១២ មិថុនា ឆ្នាំ២០២១

[36]គេហទំព័រ ការគ្រប់គ្រងសំណល់រឹង | កំណត់ត្រាសិលា (wordpress.com) ដកស្រង់នៅថ្ងៃទី១២ មិថុនា ឆ្នាំ២០២១

❖ សារៈប្រយោជន៍នៃការកែច្នៃកាកសំណល់

ការកែច្នៃសំណល់មានសារៈសំខាន់ជាច្រើនដូចខាងក្រោម៖

- ការជួយដល់ការអភិរក្សធនធានធម្មជាតិតាមរយៈការប្រើប្រាស់សំណល់ជាវត្ថុធាតុដើម ជំនួសវត្ថុធាតុដើមមួយចំនួនដែលទាញចេញពីធនធានធម្មជាតិក្នុងការផលិតជាផលិតផលថ្មី។
- ការប្រើប្រាស់ឡើងវិញនូវសម្ភារៈមួយចំនួនដែលទាញចេញពីសំណល់ ដោយរក្សានូវទម្រង់ដើមរបស់សំណល់ដែលនៅដដែរ ដោយគ្រាន់តែលាងសម្អាតនោះវាបានជួយសន្សំថាមពលក្នុងការផលិតនូវផលិតផលថ្មីឡើងវិញ។
- កាត់បន្ថយគ្រោះថ្នាក់នៃបំពុល ក៏ដូចជាការសន្សំនូវតម្លៃលើការចំណាយលើមធ្យោបាយត្រួតពិនិត្យការធ្វើប្រព្រឹត្តកម្មសម្អាត និងបោះបង់ចោល។
- ការកែច្នៃសំណល់ធ្វើឱ្យកាត់បន្ថយនូវតម្រូវការចំពោះមធ្យោបាយក្នុងការចាក់ចោលសំណល់ មួយផ្នែកក៏ដូចជាបានកាត់បន្ថយមាឌសំណល់ ដែលត្រូវចាក់នៅទីលានចាក់សំណល់ដែលជាកត្តាសំខាន់ក្នុងការជួយដល់ដំណើរការប្រើប្រាស់ទីលានបានរយៈពេលយូរ ជាផ្នែកដ៏សំខាន់ចំពោះតំបន់ក្នុងក្រុងឬទីប្រជុំជនមានដីចង្អៀត និងខ្វះដីសម្រាប់ធ្វើការអភិវឌ្ឍន៍ផ្សេងៗ។
- ការផលិតនូវផលិតផលដែលមានតម្លៃថោកអាចសមស្របទៅតាមកម្រិតជីវភាព។[37]

❖ ការកែច្នៃសំណល់កាកសំណល់ឱ្យទៅជាធនធាន

នៅក្នុងការកែច្នៃ គេយកផលិតផលដែលលែងមានប្រយោជន៍រួចប្រែក្លាយវាទៅជាវត្ថុធាតុដើម ដើម្បីបង្កើតផលិតផលមានប្រយោជន៍ថ្មី។ ការកែច្នៃសម្ភារៈខ្លះ ( ដូចជាលោហៈ និងកៅស៊ូ ) ត្រូវធ្វើនៅក្នុងរោងចក្រចំណែកសម្ភារៈដទៃទៀតដូចជា ក្រដាស់ និងកញ្ចក់ មិនសូវទាមទារឧបករណ៍និងទីធ្លាទេ និងអាចត្រូវបានកែច្នៃ នៅក្នុងរោងជាងតូច ឬក្នុងផ្ទះប្រជាជន។ ការកែច្នៃ គឺជាវិធីដល់សំខាន់មួយក្នុងការកាត់បន្ថយកាកសំណល់។ ការកែច្នៃត្រូវការការគាំទ្រពីរដ្ឋាភិបាលនិងឧស្សាហកម្ម ក៏ដូចជាការប្ដេជ្ញាចិត្តពីសំណាក់សហគមន៍និងប្រជាជន។ ការកែច្នៃ ៖

- កាត់បន្ថយបរិមាណនៃកាកសំណល់រឹងដែលបំពុលបរិស្ថានរបស់យើង។
- កាត់បន្ថយបរិមាណនៃកាកសំណល់រឹងដែលយើងត្រូវបោះចោល ,ទូលាយទីធ្លា, និងសន្សំសំចៃប្រាក់។
- កាត់បន្ថយការប្រើប្រាស់ធនធាន តាមរយៈការប្រើប្រាស់ធនធានលើសពីមួយដង។

---

[37]គេហទំព័រ ការគ្រប់គ្រងសំណល់រឹង | កំណត់ត្រាសិលា (wordpress.com) ដកស្រង់នៅថ្ងៃទី១២ មិថុនា ឆ្នាំ២០២១

- ជួយសេដ្ឋកិច្ចក្នុងតំបន់ឬជាតិ ព្រោះយើងត្រូវការនាំចូលវត្ថុធាតុដើមតិចជាងមុន។
- ផ្តល់ការងារសម្រាប់ប្រជាជន។

ការកែច្នៃសំណល់មួយចំនួនអាចកាត់បន្ថយបានយ៉ាងច្រើននូវសំណល់ ហើយការប្រមូលទុកដាក់សំណល់បានល្អនិងធ្វើឱ្យបរិស្ថានសហគមន៍យើងស្អាតល្អ មានខ្យល់អាកាសបរិសុទ្ធ និងមិនមានការបំពុល។ គ្មានការបំពុល សត្វក្រៀល និងសត្វស្លាបផ្សេងៗទៀតមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំហើយវាផ្តល់ផលប្រយោជន៍ដល់យើងទាំងអស់គ្នា និងកូនចៅជំនាន់ក្រោយ។ បរិស្ថានស្អាតផ្តើមចេញពីយើងគ្រប់គ្នា ដូចនេះយើងទាំងអស់គ្នាថែរក្សាបរិស្ថានសាលារៀន និងសហគមន៍យើងឱ្យមានភាពបៃតងជានិច្ច។[38]

## ២.៣.វិធានការណ៍កាត់បន្ថយសំណល់រឹង

### ២.៣.១.ការកែលម្អច្បាប់ទំលាប់

មកដល់ពេលនេះសាលារាជធានីភ្នំពេញបានចេញនូវបទប្បញ្ញត្តិ និងច្បាប់ដែលហាមប្រាមអំពី ការចោលសំរាមនៅតាមទីសាធារណៈក៏ដូចជាតាមដងផ្លូវសាធារណៈ និងផ្សារ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ពុំមានអ្វីផ្លាស់ប្តូរគួរអោយកត់សំគាល់នោះឡើយទេ ហើយប្រជាពលរដ្ឋ នៅតែបោះចោលសំរាមគ្រប់ទីកន្លែងតាមដែលពួកគេចង់ដដែរ។ បទប្បញ្ញត្តិ និងការផ្តន្ទាទោស គួរតែត្រូវបានអនុវត្តយ៉ាងតឹងរឹង ដើម្បីឱ្យប្រជាពលរដ្ឋគោរព និងប្រកាន់ខ្ជាប់នូវអ្វីដែលច្បាប់កំណត់។[39]

### ២.៣.២.លើកកម្ពស់ការអប់រំផ្នែកបរិស្ថាន

បង្កើនការយល់ដឹងពីបរិស្ថាន គឺពិតជារឿងសំខាន់ក្នុងការដោះស្រាយជាមួយនឹងបញ្ហាការដាក់សំរាមមិនត្រឹមត្រូវក្នុងធុងសំរាម និងការវេចខ្ចប់សំរាមមិនត្រឹមត្រូវ។ នៅពេលដែលប្រជាលពលរដ្ឋមានការយល់ដឹងពីផលប៉ះពាល់នៃសកម្មភាពរបស់ពួកគេនោះ ពួកគេទំនងជាធ្វើការផ្លាស់ប្តូរដោយខ្លួនគេតែម្តង។ ការយល់ដឹងដោយខ្លួនឯងបែបនេះ គឺមានប្រសិទ្ធិភាពជាងការប្រើប្រាស់ច្បាប់ និងបទប្បញ្ញត្តិទៅទៀត ពីព្រោះប្រជាជនមានឆន្ទៈ ក្នុងការផ្លាស់ប្តូរដោយខ្លួនឯងមិនមានការបង្ខំ។[40]

---

[38] គេហទំព័រ ការគ្រប់គ្រងនិងការដាក់កាកសំណល់រួមគ្នាមិនបានល្អ - Hesperian Health Guides ដកស្រង់នៅថ្ងៃទី ១៤មិថុនា ឆ្នាំ២០២១

[39] គេហទំព័រhttps://urbanvoicecambodia.net/waste-management-in-phnom-penh/ដកស្រង់នៅថ្ងៃទី ២៤ មិថុនាឆ្នាំ២០២១

[40] គេហទំព័រhttps://urbanvoicecambodia.net/waste-management-in-phnom-penh/ដកស្រង់នៅថ្ងៃទី ២៤ មិថុនាឆ្នាំ២០២១

### ២.៣.៣.បង្កើតសកម្មភាពគ្រប់គ្រងផ្សេងៗលើកាកសំណល់

វានឹងមានមានគុណសម្បត្តិច្រើន ប្រសិនបើសាលារាជធានីភ្នំពេញសាងសង់រោងចក្រមួយដើម្បីធ្វើការកែច្នៃសំរាម កន្លែងផលិតសំរាមឡើងវិញ និងកន្លែងដុតកាកសំណល់ទាំងនោះ។ នេះជារបៀបមួយដែលអាចអោយប្រជាពលរដ្ឋអាចធ្វើការប្រើប្រាស់ផលិតផលកែច្នៃឡើងវិញបាន។ កសិករនឹងអាចប្រើជីសរីរាង្គ ដែលផលិតបានពីកាកសំណល់ ហើយការបំពុលបរិស្ថាន នឹងត្រូវបានកាត់បន្ថយច្រើន។ ពុំចាំបាច់មានការសង្ស័យអ្វីនោះឡើយ មិនថាបញ្ហាធំយ៉ាងណាក៏ដោយក៏គង់តែមានដំណោះស្រាយ ជានិច្ច។ ការវេចខ្ចប់កាកសំណល់ និងការទុកដាក់មិនបានត្រឹមត្រូវ វិធីសាស្ត្រក្នុងការកែច្នៃសំរាមនៅមានកម្រិត និងទម្លាប់អាក្រក់ក្នុងការចោលសំរាម អាចត្រូវបានដោះស្រាយ ប្រសិនបើមានការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការដោះស្រាយ។ បន្ទាប់ពីបានពិចារណាគ្រប់ជ្រុងជ្រោយនៃបញ្ហា គេអាចមើលឃើញថា គេត្រូវការជាចាំបាច់នូវបទប្បញ្ញត្តិល្អប្រសើរ និងការរឹតបន្តឹងតឹងរឹង រួមជាមួយ នឹងការបង្កើនការយល់ដឹងបន្ថែមទៀត អំពីបរិស្ថាន និងការគ្រប់គ្រងកាកសំណល់ ដល់សារធារណៈជន ក្នុងគោលបំណងដើម្បីដោះស្រាយ បញ្ហានាពេលបច្ចុប្បន្នស្របតាមការរីកចំរើននៃទីក្រុង។[41]

### ២.៣.៤. ការកាត់បន្ថយបរិមាណសំណល់

ចំពោះការកាត់បន្ថយបរិមាណសំណល់ឱ្យនៅមានចំនួនតិច គឺយើងអាចធ្វើទៅបានគ្រប់គ្នា ទាំងរដ្ឋាភិបាល ទាំងសហគ្រាសពាណិជ្ជកម្ម ទាំងប្រជាពលរដ្ឋ ៖

- ចំពោះប្រជាពលរដ្ឋគ្រប់រូប
    - យើងត្រូវយកថង់ ឬសម្ភារៈសម្រាប់ច្រកឥវ៉ាន់នៅពេលយើងទៅផ្សារទិញសម្ភារៈផ្សេងៗ
    - ចៀសវាងការជ្រើសរើសសម្ភារៈឬរបស់ដែលត្រូវបោះចោល
    - ជ្រើសរើសសម្ភារៈឬរបស់របរមិនមានការវេចខ្ចប់ច្រើន
    - ជ្រើសរើសសម្ភារៈ ឬរបស់ដែលអាចបញ្ជូនត្រឡប់ទៅឱ្យម្ចាស់ដើមឬងាយស្រួលក្នុងការកែច្នៃឡើងវិញ
    - ជួសជុលសម្ភារៈបាក់បែក ឬខូចឡើងវិញក្នុងករណីអាចធ្វើទៅបាន
    - ចូលរួមក្នុងការអនុវត្តន៍សកម្មភាពកែច្នៃសំណល់ជាមួយក្រុម ឬអាជ្ញាធរមូលដ្ឋានរបស់ខ្លួន

[41] គេហទំព័រhttps://urbanvoicecambodia.net/waste-management-in-phnom-penh/ដកស្រង់នៅថ្ងៃទី ២៤ មិថុនាឆ្នាំ២០២១

- ចូលរួមចំណែកជាមួយការប្រមូលសំណល់ អាចកែច្នៃបានដែលបានអនុវត្ត ដោយរដ្ឋាភិបាល ឬអាជ្ញាធរ។

➢ ចំពោះរដ្ឋាភិបាល

- បង្កើនការផ្តល់ព័ត៌មានជាសាធារណៈ និងកម្មវិធីនៃសកម្មភាពអប់រំប្រជាពលរដ្ឋ និងអ្នកជំនាញ
- អនុវត្តការប្រមូលសំណល់ដែលអាចកែច្នៃបាន ដូចជាក្រដាស ដប កំប៉ុងជាដើម
- រដ្ឋាភិបាលត្រូវលើកស្ទួយដល់ ការប្រើប្រាស់ផលិតផលកែច្នៃនៅក្នុងការិយាល័យរបស់ស្ថាប័នរដ្ឋ។

➢ ចំពោះសកម្មភាពពាណិជ្ជកម្ម

- ប្រើប្រាស់សម្ភារៈងាយស្រួលក្នុងការកែច្នៃ ឬដំណើរការផលិត និងបោះបង់ចោល
- កែសម្រួលចង្វាក់ផលិតកម្ម ដើម្បីកាត់បន្ថយផលិតផលដែលនឹងបង្កើតសំណល់
- ប្រើផលិតផលមានសញ្ញាសម្គាល់ ដែលផ្តល់នូវព័ត៌មានអំពីសម្ភារៈប្រើរួច អាចកែច្នៃបាន
- ណែនាំឱ្យមានការវេចខ្ចប់ឱ្យសមស្រប និងការកែច្នៃសម្ភារៈវេចខ្ចប់ និងបង្កើតប្រអប់ ឬកន្លែងដែលមានសុវត្ថិភាពសម្រាប់ ធ្វើការញែកសម្ភារៈអាចកែច្នៃបានចេញពីសំណល់ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការប្រមូល ឱ្យមានប្រសិទ្ធភាពនៅប្រភពដែលបានបែងចែកសំណល់ហើយ។[42]

### ២.៣.៥. ការប្រើប្រាស់ឡើងវិញតាមដែលអាចធ្វើបាន

សំរាមរបស់មនុស្សម្នាក់ ច្រើនតែមានប្រយោជន៍សម្រាប់មនុស្សម្នាក់ទៀត។ នៅទូទាំងពិភពលោក មនុស្ស សន្សំសំចៃប្រាក់ និងការពារបរិស្ថានដោយការច្នៃប្រឌិតមធ្យោបាយផ្សេងៗ ដើម្បីប្រើប្រាស់ឡើងវិញយ៉ាងមានសុវត្ថិភាពនូវសម្ភារៈដែលបានបោះចោល។ ការប្រើប្រាស់ឡើងវិញមានដូចជា៖

- ចំពោះកង់ឡានអ្នកអាចធ្វើជាស្បែងជើងសង្រែក ធុង និងជើងដាំរុក្ខជាតិ។
- ចំពោះសំបកកំប៉ុង អ្នកអាចយកទៅធ្វើអំពូលជើងដាំរុក្ខជាតិ និងប្រដាប់ដាក់ទៀន
- ចំពោះប្រអប់អាហាររលោងៗអ្នកអាចធ្វើជាថង់ដាក់ទំនិញពេលទៅផ្សារ
- ចំពោះសំបកដូង អ្នកអាចធ្វើពែង សម និងស្លាព្រា
- ចំពោះលោហៈសំណល់អ្នកអាចធ្វើចង្ក្រានអំពូល និងវត្ថុសិល្បៈ

[42] គេហទំព័រ [ការគ្រប់គ្រងសំណល់រឹង | កំណត់ត្រាសិលា (wordpress.com)] ដកស្រង់នៅថ្ងៃទី១២ មិថុនា ឆ្នាំ២០២១

- អ្នកអាចប្រើប្រាស់អាចម៍រណានៅក្នុងជីកំប៉ុស ក្នុងបង្គន់ស្ងួត ឬសង្កត់បង្ហាប់វាជាមួយលាមកសត្វ និងសារធាតុសរីរាង្គស្ងួតដទៃទៀត និងដុតជាឥន្ធនៈ។

យើងអាចប្រើប្រាស់សំណល់ដែលយើងបង្កើតឡើងដោយខ្លួនឯងបាន។ ជាក់ស្ដែង យើងអាចលាងសម្អាតដបប្លាស្ទិកដែលយើងបានប្រើប្រាស់រួចសម្រាប់ទុកប្រើថ្ងៃក្រោយទៀតបានច្រើនដងមុន និងបោះវាចោល ( លើកលែងសំបកដបថ្នាំពុល )។ សំបក ឬឡាំងក្រដាស និងថង់ប្លាស្ទិកខ្លះអាចប្រើប្រាស់បានជាច្រើនដងមុន និងបោះវាចោល។ ទោះជាយ៉ាងណាក៏ដោយសំណល់ខ្លះដូចជា ប្លាស្ទិក ដែលគ្របពីលើចំណីអាហារ ម្ជុល សឺរ៉ាំងចាក់ថ្នាំសំណល់ពីមន្ទីរពេទ្យមិនអាចកែច្នៃ ឬប្រើប្រាស់ឡើងវិញបានឡើយ ពីព្រោះប្រសិនបើយកសំណល់ទាំងនេះមកប្រើប្រាស់ឡើងវិញវាអាចនាំឱ្យមានការឆ្លងមេរោគដែលបណ្ដាលឱ្យមនុស្សឈឺ។ សំណល់ដែលមិនកែច្នៃ ឬប្រើប្រាស់ឡើងវិញបានត្រូវតែទុកដាក់ឱ្យបានត្រឹមត្រូវ និងដោយប្រុងប្រយ័ត្នដើម្បីការពារកុំឱ្យមានការបំពុលដល់បរិស្ថាន។ ខាងក្រោមនេះគឺជាបញ្ជីសំណល់ខ្លះៗដែលអាចយកទៅកែច្នៃបាន ឬប្រើប្រាស់ឡើងវិញបានដោយមនុស្សផ្សេងទៀត៖

- លោហៈធាតុគ្រប់ប្រភេទរួមទាំងដែកថែប ដែកធម្មតា ទង់ដែង និងអាលុយមីញ៉ូម
- សំណល់ប្រេងម៉ាស៊ីន
- ដបកែវ ឬដបប្លាស្ទិក
- វត្ថុធាតុធ្វើពីប្លាស្ទិកផ្សេងទៀត។[43]

## ២.៤.ការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល

### ២.៤.១.រដ្ឋបាលថ្នាក់ជាតិ

ក្រសួងមហាផ្ទៃនិងក្រសួងបរិស្ថាន ត្រូវសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការរៀបចំរៀបចំបង្កើតក្រុមការងារអន្តរក្រសួងមួយដើម្បីពិភាក្សានិងសម្របសម្រួលជាមួយ រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ទេរអនុវត្តន៍និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុកនិងប្រតិភូកម្មការអនុវត្តនិងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ។

ក្រុមការងារអន្តរក្រសួងនេះមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការផ្សព្វផ្សាយផែនការអនុក្រឹត្យ និងលិខិតបទដ្ឋាន និងឯកសារបច្ចេកទេសនានាពាក់ព័ន្ធនិងការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

---

[43] គេហទំព័រ ការគ្រប់គ្រងនិងការដាក់កាកសំណល់រួមគ្នាមិនបានល្អ - Hesperian Health Guides ដកស្រង់នៅថ្ងៃទី ១៤មិថុនា ឆ្នាំ ២០២១

- ចុះសិក្សាប្រមូលព័ត៌មាន និងរៀបចំផែនការ ដើម្បីសម្របសម្រួលដល់ការផ្ទេរ និងការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ធ្វើការពិនិត្យតាមដានវាយតម្លៃ និងរៀបចំសិក្ខាសាលា ដើម្បីឆ្លុះបញ្ចាំងនិងធ្វើការដកស្រង់បទពិសោធន៍ លើការអនុវត្តមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន
- រៀបចំរបាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមនានាអំពីការអនុវត្តអនុក្រឹត្យនេះជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល។[44]

## ២.៤.២. រដ្ឋបាលថ្នាក់ក្រោមជាតិ

បើយោងតាម មាត្រា៥ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង " ការអនុវត្តន៍ក្នុងការប្រមូលដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត ក្រុង " គឺជាការទទួលខុសត្រូវរបស់អាជ្ញាធរខេត្តនិងក្រុង។ ដូចច្នេះការបែងចែកសមត្ថកិច្ច និងតួនាទីមានដូចខាងក្រោម

### ក. រដ្ឋបាលរាជធានី

នៅក្នុងដែនសមត្ថកិច្ចនេះត្រូវមានតួនាទីដូចខាងក្រោម៖

- ផ្សព្វផ្សាយអំពីខ្លឹមសារនៃ អនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនិងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលខណ្ឌ សង្កាត់ មន្ទីរ និងអង្គការជំនាញពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងអ្នកពាក់ព័ន្ធនានាដើម្បីឱ្យបានយល់ជ្រាបពីតួនាទីភារកិច្ចរៀងៗខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ ១១៣ ។
- ពិនិត្យការអនុវត្ត កិច្ចសន្យាសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនកន្លងមកនិងធ្វើការពិគ្រោះយោបល់ជាមួយ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់សេវា ដើម្បីធ្វើការកែសម្រួលកិច្ចសន្យាដោយពិនិត្យលទ្ធភាព ក្នុងការផ្ទេរការអនុវត្តកិច្ចសន្យាទៅឱ្យ រដ្ឋបាលខណ្ឌឱ្យស្របទៅនិងតម្រូវការជាក់ស្តែងនិងខ្លឹមសារនៃអនុក្រឹត្យលេខ ១១៣។
- ពិគ្រោះយោបល់ជាមួយរដ្ឋបាលខណ្ឌ និងសង្កាត់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីពិនិត្យលទ្ធភាពក្នុងការធ្វើប្រតិភូកម្មទៅឱ្យ រដ្ឋបាលខណ្ឌ ឬសង្កាត់ នូវមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនមួយផ្នែក ឬទាំងស្រុង ដោយភ្ជាប់ជាមួយធនធានមធ្យោបាយ និងសម្ភារៈ។

[44] ដកស្រង់ចេញពី សារាចរអន្តរក្រសួង ស្តីពី ការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- រៀបចំផែនការ និងវិធានការណ៍គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយមានការសហការចូលរួមពីមន្ទីរ និងអង្គភាពពាក់ព័ន្ធ។
- រៀបចំធ្វើការចាត់ចែងឱ្យមាន ធុងសំរាមសាធារណៈ និងកំណត់កន្លែងសមស្របសម្រាប់ស្តុកសំរាមសំណល់រឹងទីប្រជុំជនបណ្តោះអាសន្នតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធិភាពក្នុងការប្រមូល និងដឹងជញ្ជូន។
- រៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- សហការជាមួយ ក្រសួងស្ថាប័នពាក់ព័ន្ធពិនិត្យស្ថានភាពទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានស្រាប់ និងសិក្សាស្វែងរកទីតាំងបម្រុងទុកសម្រាប់រៀបចំទីលានដោយផ្តោតលើទីតាំង ដែលអាចមានលទ្ធភាពសម្រាប់ ការប្រើប្រាស់រួមគ្នារវាងរាជធានីនិង ខេត្ត ដែលមានព្រំប្រទល់ជាប់គ្នា។[45]
- ធ្វើការណែនាំដល់ប្រជាពលរដ្ឋអំពីការសម្អាតអនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសម្អាតប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលបានរៀបចំនៅ ក្នុងមូលដ្ឋាន។
- អប់រំនិងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការលើកកម្ពស់ ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន។[46]

## ខ. រដ្ឋបាលខណ្ឌ សង្កាត់ក្នុងរាជធានី

នៅក្នុងដែនសមត្ថកិច្ចនេះត្រូវមានតួនាទីដូចខាងក្រោម៖

- សម្របសម្រួលកិច្ចដំណើរការ សេវាសម្អាត ប្រមូល ដឹកជញ្ជូននិងទុកដាក់សំរាម សំណល់រឹងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- អប់រំផ្សព្វផ្សាយ និងណែនាំដល់ប្រជាពលរដ្ឋឱ្យយកចិត្តទុកដាក់ក្នុង ការញែក វេចខ្ចប់ទុកដាក់ និងការបោះចោលសំរាម សំណល់រឹង ឱ្យបានត្រឹមត្រូវនៅតាមទីកន្លែងនិងពេលវេលាដែលកំណត់ស្របតាមកម្មវិធីប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង។

[45] ដកស្រង់ចេញពី សារាចរអន្តរក្រសួង ស្តីពី ការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

[46]មាត្រា ៩ នៃអនុក្រឹត្យលេខ ១១៣ អនក្រ. ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពី ការគ្រប់គ្រង់សំរាម សំណល់រឹងទីប្រជុំជន

- ត្រូវធ្វើការសម្របសម្រួលក្នុងការកំណត់ទីតាំងទុកដាក់សំរាម សំណល់រឹងបណ្តោះអាសន្នរួមទាំងធុងសំរាមសាធារណៈឱ្យបានសមស្របដោយមិនបង្កជាបញ្ហាប៉ះពាល់ ដល់ការធ្វើចរាចរណ៍ សុខុមាលភាពសាធារណៈ សោភ័ណភាព និងសណ្តាប់ធ្នាប់សង្គម។
- សហការជាមួយមន្ទីរបរិស្ថាន ជួយដាក់ស្លាកសញ្ញាហាមឃាត់ ការទុកដាក់ និងការបោះចោលសំរាម សំណល់រឹងគ្មានសណ្តាប់ធ្នាប់ នៅតាមទីតាំងសំខាន់ៗមួយចំនួននៅក្នុងរាជធានីភ្នំពេញ។
- ដឹកនាំកងកម្លាំងនគរបាលខណ្ឌ សង្កាត់ មន្ត្រីបរិស្ថានចុះទប់ស្កាត់ណែនាំនិងធ្វើការផាកពិន័យជាប្រាក់ ចំពោះអ្នកចោលសំរាម សំណល់រឹងគ្មានសណ្តាប់ធ្នាប់ និងអ្នកបញ្ចេញសំរាម សំណល់រឹងមកដាក់ក្រៅលំនៅដ្ឋាន ខុសទីតាំង និងម៉ោងពេលកំណត់។
- ចូលរួមធ្វើការសម្របសម្រួល ដោះស្រាយបញ្ហានានាពាក់ព័ន្ធ និងការងារសម្អាត ប្រមូលដឹកជញ្ជូននិងថ្លៃសេវាដឹកជញ្ជូនសំរាម សំណល់រឹងរបស់ប្រជាពលរដ្ឋ ម្ចាស់អាជីវកម្ម សេវាកម្ម មូលដ្ឋានបង្កើតសំណល់ ជាមួយក្រុមហ៊ុនផ្តល់សេវាកម្មសំរាម សំណល់រឹងនៅក្នុងមូលដ្ឋានរបស់ខ្លួន។
- ចូលរួមសហការពង្រឹងការអនុវត្តវិធានការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធ និងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។[47]

**គ រដ្ឋបាលក្រុង**

នៅក្នុងដែនសមត្ថកិច្ចនេះមានដូចខាងក្រោម៖

- ក្នុងករណីមិនទាន់មានសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ត្រូវរៀបចំឱ្យមានសេវាគ្រប់គ្រងនេះនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមខ្លឹមសារនៃអនុក្រឹត្យលេខ១៣៣។
- សហការពិនិត្យលើការអនុវត្តកិច្ចសន្យាកន្លងមក និងធ្វើការពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់សេវាដើម្បីកែសម្រួលកិច្ចសន្យាឱ្យស្របទៅនិងតម្រូវការជាក់ស្តែង និងខ្លឹមសារនៃអនុក្រឹត្យលេខ១១៣។
- សិក្សាឱ្យបានច្បាស់លាស់ពីស្ថានភាពនៃការបង្កើតសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួនមានជាអាទិ៍ ប្រភេទ ប្រភព និងបរិមាណសំណល់។
- រៀបចំលិខិតបទដ្ឋានចាំបាច់នានាសម្រាប់ណែនាំ និងជំរុញការអនុវត្តវិធានការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ណែនាំដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំសម្រាប់គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

[47] ដកស្រង់ចេញពី សេចក្តីណែនាំ ស្តីពី ការគ្រប់គ្រង កាកសំណល់រឹង នៅរាជធានីភ្នំពេញ

- រៀបចំផែនការ និងវិធានការណ៍គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដោយសហការជាមួយមន្ទីរ និងអង្គភាពជំនាញ រួមជាមួយការលើកកម្ពស់ ការកាត់បន្ថយបរិមាណសំណល់ដែលត្រូវបានបង្កើត និងត្រូវបានបោះបង់ចោល។[48]
- គាំទ្រ និងជំរុញការអប់រំ និងការផ្សព្វផ្សាយតាមគ្រប់រូបភាពដល់សាធារណជនអំពីសារប្រយោជន៍នៃការញែកសំរាម សំណល់រឹងទីប្រជុំជនអំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ ការកែច្នៃ និងលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន
- តាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តរបស់រដ្ឋបាលក្រុង ក្នុងការងារគ្រប់គ្រង សំរាម សំណល់រឹងទីប្រជុំជន។[49]

## ឃ. មន្ទីរបរិស្ថានរាជធានី

នៅក្នុងដែនសមត្ថកិច្ចនេះត្រូវមានដូចជាៈ

- ត្រូវត្រួតពិនិត្យវឌ្ឍនភាពក្រុមហ៊ុនប្រមូល និងដឹកជញ្ជូនសំរាមក្នុងការរៀបចំផែនការកម្មវិធី និងកាលវិភាគនានាដែលកំណត់ក្នុងសេចក្តីណែនាំ។
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងដំណើរការសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំអំពីស្ថានភាព និងដំណើរការគ្រប់គ្រងសំរាម
- ចូលរួមផ្តល់យោបល់បច្ចេកទេសលើសំណើ ឬគម្រោងសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ត្រូវរៀបចំផែនការត្រួតពិនិត្យការអនុវត្តសកម្មភាពរបស់ក្រុមហ៊ុនរួចធ្វើរបាយការណ៍ជូនរដ្ឋបាលរាជធានីភ្នំពេញ។
- ត្រូវអនុវត្តវិធានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានព្រមទាំងអនុវត្តវិធានការណ៍ផាកពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនិងសំរាម សំណល់រឹងទីប្រជុំជន។
- ផ្តល់កិច្ចសហការឱ្យបានជិតស្និតជាមួយ អាជ្ញាធរមូលដ្ឋានខណ្ឌ សង្កាត់ក្នុងការរៀបចំភ្នាក់ងារពិន័យ ព្រមធ្វើការអប់រំដល់ភ្នាក់ងារពិន័យអំពីយន្តការនិងនីតិវិធីនៃការអនុវត្តឱ្យមានប្រសិទ្ធិភាព។[50]

[48] ដកស្រង់ចេញពី សារាចរអន្តរក្រសួង ស្តីពី ការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

[49] មាត្រា ៧ នៃអនុក្រឹត្យលេខ ១១៣ អនក្រ. ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

[50] ដកស្រង់ចេញពី សេចក្តីណែនាំ ស្តីពី ការគ្រប់គ្រង កាកសំណល់រឹង នៅរាជធានីភ្នំពេញ

### ២.៤.៣. ការផាកពិន័យ

➢ បុគ្គលដែលបោះចោលសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ វាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌហាមឃាត់ការបោះចោលសំរាម សំណល់រឹង ទីប្រជុំជនដូចមានចែងក្នុងមាត្រា២០ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និង ទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ២០០០០ (ពីរម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូល សំអាតយកទៅដាក់ធុងសំរាមសាធារណៈ
- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន រៀល ចំពោះអ្នកលក់ដូរតាមផ្ទះ ភោជនីយដ្ឋាន ទីកំសាន្តនិងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវ
- ទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាលត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។[51]

➢ បុគ្គលដែលដុតសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានីឬខណ្ឌ ក្រុង ស្រុកហាមឃាត់ ដូចមានចែងក្នុងមាត្រា២០នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូលសំអាត
- ចំនួន ១០០.០០០ (មួយសែន) រៀល ចំពោះម្ចាស់លំនៅឋាន អ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលសំអាត
- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សា ភោជនីយដ្ឋាន ទីកំសាន្ត អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន

[51]មាត្រា ៤២ នៃអនុក្រឹត្យលេខ ១១៣ អនក្រ. ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្ដីពី ការគ្រប់គ្រង់សំរាម សំណល់រឹងទីប្រជុំជន

- ចំនួន ១.០០០០០០ (មួយលាន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។ ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។[52]

➢ បុគ្គលម្ចាស់ការដ្ឋានសំណង់អគារដែលធ្វើការទុកដាក់សំរាម សំណល់រឹងទីប្រជុំជនពីការងារសំណង់ ឬសម្ភារៈសំណង់មិនបានត្រឹមត្រូវតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬការទុកដាក់បង្កការប៉ះពាល់ដល់ សណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព ឬបរិស្ថាន ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះការដ្ឋានសំណង់លំនៅឋានៈ និងត្រូវទទួលខុស ត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល ចំពោះការដ្ឋានសំណង់អគារធំៗ បុរីលំនៅឋាន និង ត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាលត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។[53]

➢ បុគ្គលដែលធ្វើការទុកដាក់ វេចខ្ចប់ ឬប្រមូលនិងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន លាយឡំជាមួយសំណល់រឹងឧស្សាហកម្ម សំណល់វេជ្ជសាស្ត្រ ឬសំណល់គ្រោះថ្នាក់ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ៥០០.០០០ (ប្រាំសែន) រៀល សម្រាប់អាជីវកម្ម សិប្បកម្ម មន្ទីរពេទ្យ សម្ភព
- ចំនួន ៨០០០០០ (ប្រាំបីសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន
- ចំនួន ១០០០០០០ (មួយលាន) រៀល សម្រាប់ក្រុមហ៊ុនសេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន។

ក្នុងករណីមិនរាងចាលត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។[54]

[52] មាត្រា ៤៣ នៃអនុក្រឹត្យលេខ ១១៣ អនក្រ. ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
[53] មាត្រា ៤៦ នៃអនុក្រឹត្យលេខ ១១៣ អនក្រ. ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
[54] មាត្រា ៤៨ នៃអនុក្រឹត្យលេខ ១១៣ អនក្រ. ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

យោងទៅលើការបកស្រាយនៅអត្ថបទខាងលើ យើងសង្កេតឃើញថា នៅក្នុងពេលបច្ចុប្បន្ននេះបញ្ហាបរិស្ថាន គឺជាបញ្ហាដ៏ធំមួយនៅក្នុងសង្គម ជាពិសេសនៅក្នុងប្រទេសដែលកំពុងមាន ការអភិវឌ្ឍដូចជាប្រទេសកម្ពុជាជាដើម។ បើយោងទៅតាមការបកស្រាយខាងលើ ការគ្រប់គ្រងកាកសំណល់រឹងនៅក្នុងរាជធានីភ្នំពេញ គឺជាផ្នែកមួយដែលសំខាន់បំផុតចំពោះភារៈទាំងអស់ទាំងភារៈមានជីវិត និងភារៈគ្មានជីវិត។ ទន្ទឹមនឹងនោះផងដែរ ការគ្រប់គ្រងកាកសំណល់រឹងនៅក្នុងរាជធានីភ្នំពេញ គឺជាកត្តាមួយយ៉ាងសំខាន់នៅក្នុងការការពារនូវបរិស្ថានក៏ដូចជា មានការកែប្រែចំពោះការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នោះឱ្យមានការយល់ដឹងអំពីការរួបរួមគ្នា ថែរក្សាបរិស្ថាន ដើម្បីឱ្យទីក្រុងមានសោភ័ណភាព មានសណ្តាប់ធ្នាប់ និងមានភាពស្រស់បំព្រងល្អប្រសើរឡើងជាងមុន។

ដើម្បីជាការធានានូវការរៀបចំនូវសណ្តាប់ធ្នាប់នៅក្នុងទីក្រុង តាមរយៈការសិក្សាបានឱ្យដឹងថាបុព្វហេតុដែលនាំឱ្យមានការរៀបចំសណ្តាប់ធ្នាប់នៅក្នុងទីក្រុងកើងឡើង គឺដោយសារតែ ការកំណើនប្រជាជនបានកើនឡើង សេដ្ឋកិច្ចប្រជាជន សេដ្ឋកិច្ច ចរាចរណ៍ សន្តិសុខ និងសណ្តាប់ធ្នាប់ដែលត្រូវបានចោទជាបញ្ហាដែលបណ្តាលឱ្យមានការរៀបចំទីក្រុងនេះ។ ដោយនៅក្នុងនោះផងដែរ ការស្រាវជ្រាវនេះគឺមានការផ្តោតយ៉ាងសំខាន់ទៅលើការគ្រប់គ្រងនៅកាកសំណល់នៅក្នុងទីក្រុង ដែលជាបញ្ហាធ្វើឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងចំពោះសុខភាពព្រមទាំងការរស់នៅរបស់ប្រជាពលរដ្ឋនៅទីនោះយ៉ាងធ្ងន់ធ្ងរ។ តួយ៉ាងនៅក្នុងបញ្ហាទាំងអស់នេះយើងក៏មានភ្ជាប់ជាមួយ នឹងដំណោះស្រាយមួយដើម្បីឱ្យមានភាពសមស្របទៅ និងការបង្កើនឡើងនូវគុណភាពនៃបរិស្ថានផងដែរ។

សរុបមក ការគ្រប់គ្រងកាកសំណល់នៅក្នុងរាជធានីភ្នំពេញ គឺជាផ្នែកមួយយ៉ាងសំខាន់ចំពោះប្រជាពលរដ្ឋមានការសិក្សាស្វែងយល់បន្ថែមទៀតអំពីរបៀបបែងចែកនូវកាកសំណល់ ឱ្យបានដាច់ដោយឡែកពីគ្នា ការកាត់បន្ថយការប្រើប្រាស់នូវថង់ប្លាស្ទិក និងរបៀបវេចខ្ចប់កាកសំណល់ឱ្យបានត្រឹមត្រូវ និងមានសណ្តាប់ធ្នាប់ ល្អប្រសើរជាងមុន។

# អនុសាសន៍

# អនុសាសន៍

ផ្អែកទៅលើសេចក្តីសន្និដ្ឋានដូចដែលបានរៀបរាប់ខាងលើ យើងខ្ញុំសូមផ្តល់អនុសាសន៍មួយចំនួនដើម្បីជាយោបល់មួយក្នុងការជួយកាត់បន្ថយនូវការគ្រប់គ្រងកាកសំណល់ នៅក្នុងរាជធានីភ្នំពេញ៖

- មិនត្រូវចោលសំរាមផ្តេសផ្តាស់
- ជួយគ្នាថែរក្សាសម្អាតទីធ្លាសាធារណៈនិងគេហដ្ឋាន
- កាត់បន្ថយការប្រើប្រាស់នូវថង់ប្លាស្ទិក
- ប្រើប្រាស់សម្ភារៈមួយចំនួនជំនួសការប្រើប្រាស់ប្លាស្ទិកតាមដែលអាចធ្វើបាន
- ចូលរួមធ្វើអនាម័យតាមសហគមន៍ និងបំផុសការការពារបរិស្ថាន
- ជួយរក្សាអនាម័យទឹក ដីកាត់បន្ថយផ្សែងពុលផ្សេងៗ
- ធ្វើការផ្សព្វផ្សាយនូវចំណេះដឹងដែលទាក់ទង និងការញែកកាកសំណល់ទៅតាមប្រភេទនីមួយៗ
- បង្កើតរោងចក្រកែច្នៃកាកសំណល់
- ជំរុញនូវការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធិភាពខ្ពស់
- ទុកដាក់កាកសំណល់ឱ្យមានរបៀប សម្អាត និងធ្វើការដឹកចេញពីទីក្រុងអោយបានស្អាតល្អ
- ចាត់វិធានការណ៍ច្បាប់យ៉ាងតឹងរឹ ចំពោះអ្នកដែលធ្វើការបំពាននៅការបោះចោលកាកសំណល់នៅទីសាធារណៈកាត់បន្ថយការប្រើប្រាស់សារធាតុគីមីពុល។

# ឯកសារយោង

# ឯកសារយោង

## ១. លិខិតបទដ្ឋានគតិយុត្តិ

- អនុក្រឹត្យស្តីពីការគ្រប់គ្រង់សំរាម សំណល់រឹងទីប្រជុំជន, លេខ១១៣ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០១៥
- សារាចរអន្តរក្រសួង ស្តីពីការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ ១០៧០ ស.ជ.ណ.ប.ស្ល ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ២០១៥។
- សេចក្តីណែនាំស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ, លេខ០០២/១៩ សណន.ស ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០១៩
- អនុក្រឹត្យស្តីពី ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់, លេខ២៣៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០១៧

## ២. សៀវភៅ

- យុទ្ធសាស្រ្ត និងផែនការសកម្មភាព គ្រប់គ្រងសំណល់ សម្រាប់រាជធានីភ្នំពេញ ឆ្នាំ ២០១៨-២០៣៥ ចុះ ខែ តុលា ឆ្នាំ២០១៨
- នីតិរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩

## ៣. គេហទំព័រ

- https://www.khsearch.com/qna/4260
- មេរៀនបរិស្ថាន (epizy.com)
- https://www.khsearch.com/qna/1371
- https://www.khsearch.com/qna/9023
- ការគ្រប់គ្រងសំណល់រឹង | កំណត់ត្រាសិលា (wordpress.com)
- សំរាម ៖ ផលប៉ះពាល់ និង ការគ្រប់គ្រង – កំណត់ត្រាសិលា (wordpress.com)
- https://urbanvoicecambodia.net/waste-management-in-phnom-penh/
- ការគ្រប់គ្រងនិងការដាក់កាកសំណល់រួមគ្នាមិនបានល្អ - Hesperian Health Guides
- ការចោលកាកសំណល់ពុលដោយគ្មានសុវត្ថិភាព - Hesperian Health Guides
- សំរាមកំពុងក្លាយជាបញ្ហាក្តៅ | Radio Veritas Asia (rvasia.org)
- កម្មវិធីកាកសំណល់រឹង ក្នុងសហគមន៍ - Hesperian Health Guides
- https://www.rasmeinews.com/archives/371276

- ឥទ្ធិពលនៃសារធាតុពុលចេញពីផ្សែងសំរាម ចំពោះជីវិតមនុស្ស និងបរិស្ថាន | ភ្នំពេញ ប៉ុស្តិ៍ (postkhmer.com)
- https://urbanvoicecambodia.net/waste-management-in-phnom-penh/

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធទី១** អនុក្រឹត្យស្តីពីការគ្រប់គ្រង់សំរាម សំណល់រឹងទីប្រជុំជន, លេខ១១៣ អនក្រ.បក
- **ឧបសម្ព័ន្ធទី២** សារាចរអន្តរក្រសួង ស្តីពីការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ១០៧០ ស.ជ.ណ.ប.ស្ត
- **ឧបសម្ព័ន្ធទី៣** សេចក្តីណែនាំស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ, លេខ០០២/១៩ សណន.ស
- **ឧបសម្ព័ន្ធទី៤** រូបភាព

# ឧបសម្ព័ន្ធរូបភាព



រូបភាពទី១ ទាក់ទងទៅនិងបរិស្ថានធម្មជាតិ



រូបភាពទី២ ទាក់ទងទៅនិងបរិស្ថានសង្គម-វប្បធម៌





រូបភាពទី៣ កាកសំណល់សំណង់

រូបភាពទី៤ កាកសំណល់អេឡិចត្រូនិក





រូបភាពទី៥ កាកសំណល់ផ្ទះបាយ

រូបភាពទី៦ កាកសំណល់វេជ្ជសាស្ត្រ





រូបភាពទី៧ កាកសំណល់ឧស្សាហកម្ម

រូបភាពទី៨ ផលប៉ះពាល់នៃការដុតសំរាម



រូបភាពទី៩ ការទុកដាក់សំរាមមិនបានត្រឹមត្រូវ



រូបភាពទី១០ ផលប៉ះពាល់ចំពោះបរិស្ថាន



រូបភាពទី១១ ផលប៉ះពាល់របស់សំរាមចំពោះសង្គម



រូបភាពទី១២ ការបំពុលទឹក



រូបភាពទី១៣ ផលប៉ះពាល់របស់សំរាមចំពោះសុខភាព



រូបភាពទី១៤ ការប្រមូល និងការដឹកជញ្ជូន



រូបភាពទី១៥ ការញែកកាកសំណល់



រូបភាពទី១៦ការកែច្នៃសំណល់





រូបភាពទី១៧ ការកាត់បន្ថយបរិមាណសំណល់



រូបភាពទី១៨ សេវាប្រមូលសំណល់ និងការសម្អាត





ការទទួលខុសត្រូវរបស់ក្រុមហ៊ុនប្រមូលសំរាម

# ឧបសម្ព័ន្ធគតិយុត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ
- ផ្តល់ការណែនាំបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ដឹកនាំសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន ឬសាធារណៈ ក្នុងការកៀរគរធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារ គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការអប់រំក្នុងនិងក្រៅប្រព័ន្ធ និងការផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ (3R: Reduce, Reuse, Recycle) និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៦.-**

ក្រសួងមហាផ្ទៃ មានតួនាទីជំរុញដល់កិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- គាំទ្រនិងសហការជាមួយក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍសមត្ថភាព និងការចែករំលែកបទពិសោធន៍អំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល និងកៀរគរការគាំទ្រនានាទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ផ្តល់អន្តរាគមន៍ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៧.-**

រដ្ឋបាលខេត្តត្រូវផ្តល់ការគាំទ្រ និងការសម្របសម្រួល ព្រមទាំងជំរុញកិច្ចប្រតិបត្តិការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលអនុវត្តដោយរដ្ឋបាលក្រុង ស្រុក និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋានចាំបាច់នានាសម្រាប់ណែនាំនិងជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ណែនាំដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកា

ប្រចាំឆ្នាំសម្រាប់គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ជំរុញ និងគាំទ្រការបង្កើតសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន
- កៀរគរធនធាន មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលក្រុង ស្រុកលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងជំរុញការអប់រំ និងការផ្សព្វផ្សាយតាមគ្រប់រូបភាពដល់សាធារណជនអំពីសារប្រយោជន៍នៃការញែកសំរាម សំណល់រឹងទីប្រជុំជន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន
- សម្របសម្រួលដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំនិងប្រើប្រាស់រួមគ្នានូវសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តរបស់រដ្ឋបាលក្រុង ស្រុកក្នុងការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៨.-**

មន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្តលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋអំពីអនាម័យបរិស្ថានតាមរយៈការអប់រំ និងធ្វើការផ្សព្វផ្សាយអំពីការទុកដាក់ ការសម្អាត ការញែក ការកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការចូលរួមប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួមរៀបចំផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ចូលរួមផ្តល់យោបល់បច្ចេកទេសលើសំណើ ឬគម្រោងសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងដំណើរការសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងសកម្មភាពកែច្នៃសំរាម សំណល់រឹងប្រជុំជន
- ជំរុញការអនុវត្តវិធានការច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងចូលរួមការអនុវត្តវិធានការពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន និង
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំអំពីស្ថានភាព និងដំណើរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកមានតួនាទីក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- រៀបចំ និងអនុវត្តនូវវិធានការសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមរយៈការដាក់ចេញជាដីកា ឬលិខិតបទដ្ឋាននានា
- បង្កើត គ្រប់គ្រង និងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធ្វើការណែនាំដល់ប្រជាពលរដ្ឋអំពីការសម្អាតអនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលបានរៀបចំនៅក្នុងមូលដ្ឋាន និង
- អប់រំនិងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកនីមួយៗអាចស្នើសុំបង្កើតអង្គភាព ឬការិយាល័យជាក់លាក់ចំណុះរដ្ឋបាលរបស់ខ្លួនសម្រាប់ទទួលខុសត្រូវលើកិច្ចការនេះ ស្របតាមគោលការណ៍ និងនីតិវិធីជាធរមាន ដើម្បីធានាដល់ប្រសិទ្ធភាព និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១១.-**

រដ្ឋបាលរាជធានីត្រូវផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឬ/និងរដ្ឋបាលសង្កាត់។

រដ្ឋបាលក្រុង ស្រុកអាចធ្វើប្រតិភូកម្មមុខងារមួយផ្នែកក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១២.-**

រដ្ឋបាលខណ្ឌត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួល និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងរាជធានី និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តមុខងារដែលបានទទួលក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួម និងសហការអនុវត្តនូវកម្មវិធីនានានៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូលនិងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១៣.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួលប្រតិភូកម្ម និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមការធ្វើប្រតិភូកម្ម
- ចូលរួមអប់រំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីការប្រើប្រាស់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ច
- ចូលរួមផ្តល់យោបល់លើការរៀបចំកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការងារសេវាសម្អាតប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និង
- ចូលរួមសហការពង្រឹងការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១៤.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចដាក់ចេញលិខិតបទដ្ឋានសម្រាប់ណែនាំដល់ការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

## ជំពូកទី៣
## ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា១៥.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវអនុវត្តការញែក និងការវេចខ្ចប់សំរាម សំណល់រឹងដែលអាចប្រើប្រាស់ឡើងវិញ ឬកែច្នៃបានដាច់ដោយឡែកពីសំរាម សំណល់រឹងដែលត្រូវបោះចោលទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៦.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការវេចខ្ចប់ដោយថង់ ឬការដាក់នៅក្នុងធុងសំរាមផ្ទាល់ខ្លួននូវសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងលក្ខណៈហ្មត់ចត់ មិនឱ្យលេចធ្លាយ មិនឱ្យលេចជ្រាបទឹកស្អុយ ឬមិនឱ្យមានភាយក្លិនស្អុយក្នុងរយៈពេលនៃការទុកដាក់រង់ចាំការបញ្ចេញទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៧.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការរក្សាទុកនូវកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងរបស់ខ្លួននៅក្នុងរបង ឬបរិវេណនៃលំនៅឋាន អគារ ឬទីតាំងរបស់ខ្លួន និងត្រូវបញ្ចេញទៅតាមពេលម៉ោងដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការត្រួតពិនិត្យឱ្យបានម៉ឺងម៉ាត់លើការអនុវត្តការបញ្ចេញកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជនទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈរង់ចាំការប្រមូល និងដឹកជញ្ជូនទៅតាមពេលម៉ោងដែលបានកំណត់។

**មាត្រា១៨.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនដែលប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំដីកា ឬលិខិតបទដ្ឋាននានា ដើម្បីណែនាំអនុវត្តការសម្អាត ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានលក្ខណៈឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃទីប្រជុំជននីមួយៗ និងត្រូវធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងលើកកម្ពស់សោភ័ណភាព អនាម័យ និងបរិស្ថាននៅតាមទីប្រជុំជន ។

ដីកា ឬលិខិតបទដ្ឋានខាងលើនេះ ត្រូវរៀបចំឡើងដោយអនុលោមតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសជាធរមាន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវផ្សព្វផ្សាយដីកា ឬលិខិតបទដ្ឋាននានា ដូចមានចែងក្នុងកថាខណ្ឌខាងលើឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាឱ្យមានការចូលរួមអនុវត្តប្រកបដោយការទទួលខុសត្រូវ។

## ជំពូកទី៤
## វិធានការទូទៅលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា២០.-**

ត្រូវបានហាមឃាត់ជាដាច់ខាតនូវការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល តាមប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការទប់ស្កាត់ការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល ប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

**មាត្រា៤១.-**

បុគ្គលដែលបានប្រើប្រាស់សេវាគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន ហើយមិនព្រមបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន ឬសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលរៀបចំ ឬកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៨ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃតម្លៃសេវាសំរាម សំណល់រឹងដែលត្រូវបង់ក្នុងមួយខែ។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤២.-**

បុគ្គលដែលបោះចោលសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌហាមឃាត់ការបោះចោលសំរាម សំណល់រឹងទីប្រជុំជន ដូចមានចែងក្នុងមាត្រា២០ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូល សំអាតយកទៅដាក់ធុងសំរាមសាធារណៈ
- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមផ្ទះ ភោជនីយដ្ឋាន ទីកំសាន្ត និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៣.-**

បុគ្គលដែលដុតសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានីឬខណ្ឌ ក្រុង ស្រុកហាមឃាត់ ដូចមានចែងក្នុងមាត្រា២០នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូលសំអាត
- ចំនួន ១០០.០០០ (មួយសែន) រៀល ចំពោះម្ចាស់លំនៅឋាន អ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលសំអាត

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ ភោជនីយដ្ឋាន ទីកំសាន្ត អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៤.-**

បុគ្គលដែលគេចវេសមិនទទួលខុសត្រូវលើសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតនៅក្នុងពិធីនានារបស់ខ្លួនដែលប្រារព្ធនៅលើដងផ្លូវ ឬនៅលើទីសាធារណៈ ដូចមានចែងក្នុងមាត្រា២១នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់បន្ថែមទៅលើតម្លៃសេវាសំអាត ប្រមូលនិងដឹកជញ្ជូនដូចខាងក្រោម៖

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះពិធីមង្គលការ សម្ពោធហាង និងបុណ្យ លើកលែងពិធីបុណ្យសព
- ចំនួន ៦០០.០០០ (ប្រាំមួយសែន) រៀល ចំពោះពិធីប្រជុំ មិទ្ទិញ
- ចំនួន ២.០០០.០០០ (ពីរលាន) រៀល ចំពោះការប្រគុំតន្ត្រីសាធារណៈ

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៥.-**

បុគ្គលម្ចាស់ ឬអ្នកគ្រប់គ្រងទីផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម មណ្ឌលកំសាន្ត ដែលមិនបានរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណសម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន ដូចមានចែងក្នុងវាក្យខណ្ឌ២ មាត្រា២២នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួន៤០០.០០០(បួនសែន) រៀល។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៦.-**

បុគ្គលម្ចាស់ការដ្ឋានសំណង់អគារដែលធ្វើការទុកដាក់សំរាម សំណល់រឹងទីប្រជុំជនពីការងារសំណង់ ឬសម្ភារៈសំណង់មិនបានត្រឹមត្រូវតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬការទុកដាក់បង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព ឬបរិស្ថាន ដូចមានចែងក្នុងមាត្រា២៣នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះការដ្ឋានសំណង់លំនៅឋាន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន

- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល ចំពោះការដ្ឋានសំណង់អគារធំៗ បុរីលំនៅឋាន និង ត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៧.-**

បុគ្គលដែលធ្វើអាជីវកម្មបូមសំណល់កក់ពីប្រព័ន្ធលូ ឬពីអាងស៊ិបទិក ដោយមិនមានលិខិតអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬដឹកយកទៅបញ្ចេញចោលខុសទីកន្លែងដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ ដូចមានចែងក្នុងមាត្រា២៧នៃអនុក្រឹត្យនេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះអាជីវកម្មជាលក្ខណៈគ្រួសារ
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះអាជីវកម្មជាលក្ខណៈក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៨.-**

បុគ្គលដែលធ្វើការទុកដាក់ វេចខ្ចប់ ឬប្រមូលនិងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន លាយឡំជាមួយសំណល់រឹងឧស្សាហកម្ម សំណល់វេជ្ជសាស្ត្រ ឬសំណល់គ្រោះថ្នាក់ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ៥០០.០០០ (ប្រាំសែន) រៀល សម្រាប់អាជីវកម្ម សិប្បកម្ម មន្ទីរពេទ្យ សម្ភព
- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល សម្រាប់ក្រុមហ៊ុនសេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៩.-**

បុគ្គលដែលមិនបានបង់ប្រាក់ពិន័យអន្តរការណ៍នេះក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃដែលបានទទួលបង្កាន់ដៃបង់ប្រាក់ពិន័យ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាពីរដង បើលើសពី៦០(ហុកសិប)ថ្ងៃ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាបីដង។ បើផុតរយៈពេល៩០(កៅសិប)ថ្ងៃ រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំសំណុំឯកសារប្តឹងទៅសាលាដំបូងរាជធានី ខេត្ត។

**មាត្រា៥៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ខែ សីហា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្តេចក្រឡាហោម ស ខេង**

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សាយ សំអាល់**

**<u>កន្លែងទទួល</u>** ៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥៥*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន** | **ក្រសួងមហាផ្ទៃ**

លេខ: ១០៧០ ស.ជ.ណ ប.ស្ក

# សារាចរអន្តរក្រសួង

## ស្តីពី

## ការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាព សាធារណៈ និងបរិស្ថាន រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។ អនុក្រឹត្យនេះមានគោលដៅប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅរដ្ឋបាលរាជធានី ក្រុង និងស្រុក និងធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅរដ្ឋបាលខណ្ឌ ដែលជារបត់នៃការគ្រប់គ្រងថ្មីមួយស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

ដើម្បីធានាបាននូវការអនុវត្តអនុក្រឹត្យនេះ ប្រកបដោយភាពរលូន ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក៏ដូចជាសំដៅកាត់បន្ថយបញ្ហាប្រឈមនានាពាក់ព័ន្ធការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលកំពុងកើតមាននៅតាមបណ្តាទីប្រជុំជនរាជធានី ខេត្ត ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានសូមធ្វើការណែនាំការអនុវត្តមួយចំនួនដូចខាងក្រោម ៖

**១. ថ្នាក់ជាតិ៖**

ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន ត្រូវសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរៀបចំបង្កើតក្រុមការងារអន្តរក្រសួងមួយដើម្បីពិភាក្សា និងសម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ទេរការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងប្រតិភូកម្មការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឲ្យរដ្ឋបាលខណ្ឌ។

ក្រុមការងារអន្តរក្រសួងនេះមានភារកិច្ចដូចខាងក្រោម៖

- រៀបចំការផ្សព្វផ្សាយអនុក្រឹត្យ និងលិខិតបទដ្ឋាន និងឯកសារបច្ចេកទេសនានាពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ចុះសិក្សា ប្រមូលព័ត៌មាន និងរៀបចំផែនការដើម្បីសម្របសម្រួលដល់ការផ្ទេរ និងការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- ពិនិត្យតាមដាន វាយតម្លៃ និងរៀបចំសិក្ខាសាលាដើម្បីឆ្លុះបញ្ចាំង និងដកស្រង់បទពិសោធន៍លើការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- រៀបចំរបាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមនានាអំពីការអនុវត្តអនុក្រឹត្យនេះ ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល។

**២. រដ្ឋបាលរាជធានី ត្រូវ៖**

- ផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលខណ្ឌ សង្កាត់ មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងអ្នកពាក់ព័ន្ធនានា ដើម្បីឱ្យបានយល់ជ្រួតជ្រាបពីតួនាទី ភារកិច្ចរៀងៗខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣

- ពិគ្រោះយោបល់ជាមួយរដ្ឋបាលខណ្ឌ និងសង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីពិនិត្យលទ្ធភាពក្នុងការធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលខណ្ឌ ឬ/និងសង្កាត់នូវមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនមួយផ្នែក ឬទាំងស្រុង ដោយភ្ជាប់ជាមួយធនធាន មធ្យោបាយ និងសម្ភារ

- ពិនិត្យការអនុវត្តកិច្ចសន្យាសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនកន្លងមក និងធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់សេវា ដើម្បីធ្វើការកែសម្រួលកិច្ចសន្យា ដោយពិនិត្យលទ្ធភាពក្នុងការផ្ទេរការអនុវត្តកិច្ចសន្យាទៅឱ្យរដ្ឋបាលខណ្ឌឱ្យស្របទៅនឹងតម្រូវការជាក់ស្តែង និងខ្លឹមសារនៃអនុក្រឹត្យលេខ១១៣

- រៀបចំផែនការ និងវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយមានការសហការចូលរួមពីមន្ទីរ និងអង្គភាពពាក់ព័ន្ធ

- ចាត់ចែងឱ្យមានធុងសំរាមសាធារណៈ និងកំណត់កន្លែងសមស្របសម្រាប់ស្តុកសំរាម សំណល់រឹងទីប្រជុំជនបណ្តោះអាសន្នតាមការចាំបាច់ ដើម្បីជានាប្រសិទ្ធភាពក្នុងការប្រមូលនិងដឹកជញ្ជូន

- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធពិនិត្យស្ថានភាពទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានស្រាប់ និងសិក្សាស្វែងរកទីតាំងបម្រុងទុកសម្រាប់រៀបចំទីលាន ដោយផ្តោតលើទីតាំងដែលអាចមានលទ្ធភាពសម្រាប់ការប្រើប្រាស់រួមគ្នារវាងរាជធានី និងខេត្តដែលមានព្រំប្រទល់ជាប់គ្នា

- អនុវត្តតួនាទី និងភារកិច្ចផ្សេងទៀតដូចដូចមានចែងនៅក្នុងអនុក្រឹត្យលេខ១១៣។

**៣. រដ្ឋបាលខេត្ត ត្រូវ៖**

- ផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងអ្នកពាក់ព័ន្ធនានា ដើម្បីឱ្យបានយល់ជ្រួតជ្រាបពីតួនាទីភារកិច្ចរៀងៗខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣

- ប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយត្រូវពិនិត្យ និងបែងចែកធនធានមធ្យោបាយ និងសម្ភារដែលបាននិងកំពុងប្រើប្រាស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យ

រដ្ឋបាលក្រុង ស្រុក

- ពិនិត្យការអនុវត្តកិច្ចសន្យាសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលបាន និងកំពុងអនុវត្ត និងធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់សេវា ដើម្បីកែសម្រួលកិច្ចសន្យា និងផ្ទេរការចុះកិច្ចសន្យា និងការគ្រប់គ្រងការអនុវត្តកិច្ចសន្យាទៅឱ្យរដ្ឋបាលក្រុង ស្រុកឱ្យស្របទៅនឹងខ្លឹមសារនៃអនុក្រឹត្យលេខ១១៣

- ណែនាំ សម្របសម្រួល និងជំរុញដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំផែនការ និងវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយមានការសហការចូលរួមពីមន្ទីរ និងអង្គភាពពាក់ព័ន្ធ

- ជំរុញ និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុកក្នុងការពិនិត្យស្ថានភាពទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានស្រាប់ និងការសិក្សាស្វែងរកទីតាំងសម្រាប់រៀបចំទីលាន ដោយផ្តោតលើទីតាំងដែលអាចមានលទ្ធភាពសម្រាប់ការប្រើប្រាស់រួមគ្នារវាងក្រុង ស្រុកដែលមានព្រំប្រទល់ជាប់គ្នា

- តាមដាន ត្រួតពិនិត្យការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- អនុវត្តតួនាទី និងភារកិច្ចផ្សេងទៀតដូចមានចែងនៅក្នុងអនុក្រឹត្យលេខ១១៣។

**៤. រដ្ឋបាលខណ្ឌ សង្កាត់ក្នុងរាជធានី៖**

- រដ្ឋបាលខណ្ឌត្រូវផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលរបស់ខ្លួន រដ្ឋបាលសង្កាត់ អង្គភាពជំនាញពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងអ្នកពាក់ព័ន្ធនានា ដើម្បីឲ្យបានយល់ជ្រួតជ្រាបពីតួនាទី ភារកិច្ចរៀងៗខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣ និងមុខងារដែលទទួលបានពីការធ្វើប្រតិភូកម្មរបស់រដ្ឋបាលរាជធានី

- រដ្ឋបាលសង្កាត់ត្រូវបន្តផ្សព្វផ្សាយខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងដល់រដ្ឋបាលរបស់ខ្លួន អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋ ដើម្បីឱ្យបានយល់ជ្រួតជ្រាបពីតួនាទី ភារកិច្ចរៀងៗខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣

- រដ្ឋបាលខណ្ឌ និងរដ្ឋបាលសង្កាត់ ត្រូវអនុវត្តតួនាទី ភារកិច្ចផ្សេងទៀតដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣ និងមុខងារដែលទទួលបានពីការធ្វើប្រតិភូកម្មរបស់រដ្ឋបាលរាជធានី។

**៥. រដ្ឋបាលក្រុង ស្រុក ត្រូវ៖**

- ផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលរបស់ខ្លួន រដ្ឋបាលឃុំ សង្កាត់ អង្គភាពជំនាញពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងអ្នកពាក់ព័ន្ធនានា ដើម្បីឱ្យបានយល់ជ្រួតជ្រាបពីតួនាទី ភារកិច្ចរៀងៗខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣

- ពិនិត្យលទ្ធភាពក្នុងការធ្វើប្រតិភូកម្មមុខងារមួយផ្នែកនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលឃុំ សង្កាត់

- សហការពិនិត្យលើការអនុវត្តកិច្ចសន្យាកន្លងមក និងធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន

- ចូលរួមពិនិត្យយន្តការ និងកិច្ចសន្យាក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលមានស្រាប់ ដើម្បីឲ្យស្របតាមស្មារតីអនុក្រឹត្យលេខ១១៣

- ចូលរួម និងសហការក្នុងការសិក្សាអំពីស្ថានភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលកំពុងអនុវត្ត និងអំពីលទ្ធភាពអនុវត្តការញែកសំរាម សំណល់រឹងដែលអាចកែច្នៃ ឬ អាចទាញយកធនធានបាន និងការកាត់បន្ថយការបង្កើតសំណល់

- ចូលរួមសហការរៀបចំផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាផ្តល់យោបល់បច្ចេកទេសពាក់ព័ន្ធនឹងសំណើឬ គម្រោងសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- ចូលរួមសហការសិក្សា និងផ្តល់យោបល់លើការស្វែងរកទីតាំងសម្រាប់រៀបចំទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងសកម្មភាពកែច្នៃសំរាម សំណល់រឹងទីប្រជុំជន

- ជំរុញការអនុវត្តវិធានការច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- អនុវត្តតួនាទី ភារកិច្ចផ្សេងទៀត ដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣។

ទទួលបានសារាចរអន្តរក្រសួងនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន គ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរបរិស្ថានរាជធានី ខេត្តត្រូវសហការផ្សព្វផ្សាយ និងអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **ក្រសួងមហាផ្ទៃ** | **ក្រសួងបរិស្ថាន** |
| **សម្តេចក្រឡាហោម ស ខេង** | **សាយ សំអាល់** |

<u>កន្លែងទទួល៖</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- លេខាធិការដ្ឋាន គ.ជ.អ.ប
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**

លេខៈ ០៤/១៩ សណន-ស

# សេចក្តីណែនាំ

## ស្តីពី

## ការគ្រប់គ្រងសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ

សុខសន្តិភាពពេញផ្ទៃប្រទេស ធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ ប្រជាពលរដ្ឋមានជីវភាពកាន់តែធូរធារឡើងៗ ហើយសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញក៏មានការកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃធ្វើឱ្យបរិមាណសំរាម សំណល់រឹងមានការកើនឡើងជាលំដាប់ ប៉ុន្តែការគ្រប់គ្រងសំរាមនៅមិនទាន់សមស្របតាមលិខិតបទដ្ឋានគតិយុត្ត និងលក្ខណៈបច្ចេកទេសនៅឡើយ ដែលតម្រូវឱ្យរដ្ឋបាលរាជធានីភ្នំពេញ ត្រូវយកចិត្តទុកដាក់គ្រប់គ្រងឱ្យបានហ្មត់ចត់។

កន្លងមក រដ្ឋបាលរាជធានីភ្នំពេញបានខិតខំប្រឹងប្រែងប្រើគ្រប់មធ្យោបាយទាំងសម្ភារ និងស្មារតី និងបានសហការជាមួយក្រុមហ៊ុន សម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញ ប៉ុន្តែការងារនេះនៅពុំទាន់បានឆ្លើយតបតាមគោលបំណង និងសេចក្តីត្រូវការនៃភាពស្អាតរបស់ទីក្រុងនៅឡើយ ដែលតម្រូវឱ្យប្រជាពលរដ្ឋ អ្នកបង្កើតសំរាម សំណល់រឹង និងក្រុមហ៊ុនសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ព្រមទាំងអ្នកពាក់ព័ន្ធនានាចូលរួមសហការទទួលខុសត្រូវអនុវត្តឱ្យបានព្រមៗគ្នា ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ដូច្នេះ ដើម្បីឱ្យរាជធានីភ្នំពេញ មានសោភ័ណភាព សណ្តាប់ធ្នាប់ អនាម័យ និងបរិស្ថានស្អាតជានិច្ច ក្លាយជាទីក្រុងបៃតង ដែលជាទីកន្លែងផ្តល់នូវសុខុមាលភាពរស់នៅរបស់ប្រជាពលរដ្ឋ ភ្ញៀវទេសចរណ៍ជាតិ អន្តរជាតិ និងយោងតាមច្បាប់ស្តីពី "កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ" ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ និងអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពី "ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន" រដ្ឋបាលរាជធានីភ្នំពេញ សូមដាក់ចេញនូវសេចក្តីណែនាំដូចខាងក្រោម៖

**១. ចំពោះម្ចាស់លំនៅឋាន ទីតាំងអាជីវកម្ម សេវាកម្ម ភោជនីយដ្ឋាន ទីផ្សារ ទីកន្លែងកំសាន្ត ម្ចាស់ប្រភពបង្កើតសំណល់នានា និងប្រជាពលរដ្ឋ មានភារកិច្ចដូចខាងក្រោម៖**

- ត្រូវធ្វើការញែកសំរាមទៅតាមប្រភេទដាក់ដោយឡែកពីគ្នា រវាងសំណល់ផ្ទះបាយ (សំរាមសើម) និងសំរាមអាចកែច្នៃបាន (សំរាមស្ងួត) ដោយត្រូវធ្វើការវេចខ្ចប់ដាក់ក្នុងថង់ ឬធុងសំរាមផ្សេងពីគ្នា មិនឱ្យមានការលេចធ្លាយ ឬជ្រាបទឹក និងក្លិនស្អុយ រួចយកទៅដាក់នៅតាមមុខលំនៅឋាន ឬតាមទីតាំងដែលបានកំណត់ដោយរដ្ឋបាលខណ្ឌ សង្កាត់ ឱ្យបានត្រឹមត្រូវ និងមានសណ្តាប់ធ្នាប់ល្អ
- សំរាមដែលបានវេចខ្ចប់ហើយ ត្រូវបញ្ចេញឱ្យបានទៀងទាត់ទៅតាមកម្មវិធីប្រមូល និងដឹកជញ្ជូនដែលបានកំណត់។ ក្នុងករណីយកសំរាមមកមិនទាន់រថយន្តដឹកសំរាម គឺមិនត្រូវទុកសំរាមចោលមុខលំនៅឋាន លើចិញ្ចើមផ្លូវ ឬទ្រូងផ្លូវឡើយ ត្រូវយកសំរាមទាំងនោះទៅរក្សាទុកក្នុងទីតាំងរបស់ខ្លួនជាបណ្តោះអាសន្ន រង់ចាំការបញ្ចេញនៅវេនលើកក្រោយទៀត

៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២៤ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

- ចំពោះការប្រារព្ធពិធីផ្សេងៗ ឬការប្រគុំតន្ត្រីនៅតាមទីសាធារណៈ ម្ចាស់ពិធីត្រូវរៀបចំឱ្យមានធុងសំរាម និងវេចខ្ចប់ ទុកដាក់សំរាម សំណល់រឹងក្នុងធុងឱ្យមានសណ្តាប់ធ្នាប់ មានអនាម័យ និងមានសោភ័ណភាពល្អ
- ហាមដាច់ខាតការបោះចោល ឬការដុតសំរាម សំណល់រឹង នៅតាមដងផ្លូវ ទីសាធារណៈ ទីវាលតាមប្រព័ន្ធទឹកលូ ប្រឡាយ ឬប្រភពទឹកសាធារណៈ ក្នុងដីឡូត៍ទំនេរ ឬក្នុងដីកម្មសិទ្ធិឯកជន។

**២. ចំពោះម្ចាស់ទីតាំងរោងចក្រ សហគ្រាស សិប្បកម្ម ការដ្ឋានសាងសង់ មានភារកិច្ចដូចខាងក្រោម៖**

- ត្រូវធ្វើការញែក និងបែងចែកសំណល់អាចកែច្នៃ ឬប្រើប្រាស់ឡើងវិញបាន ដាច់ដោយឡែកពីសំរាម សំណល់រឹងនិងសំណល់គ្រោះថ្នាក់ ដែលត្រូវបោះចោល និងប្រមូលដឹកជញ្ជូនដោយក្រុមហ៊ុនឯកជន
- ត្រូវរៀបចំឱ្យមានទីកន្លែងទុកដាក់សំរាម សំណល់រឹង សំណល់គ្រោះថ្នាក់ដែលបានញែករួច ទៅតាមប្រភេទនីមួយៗ ដើម្បីធានាឱ្យមានអនាម័យ និងសោភ័ណភាពល្អស្អាត ទាំងខាងក្នុង និងជុំវិញទីតាំងរបស់ខ្លួន
- សំណល់ការដ្ឋានសំណង់មានដូចជា កំទេចកំទីដី ថ្ម ឥដ្ឋ ក្បឿង បាយអ ខ្សាច់... មិនអាចដឹកយកទៅចាក់បំពេញទីកន្លែងណាមួយផ្សេងទៀតបានទេ បើគ្មានការអនុញ្ញាតពីរដ្ឋបាលមូលដ្ឋានជាមុន
- ចំពោះសំណល់ឧស្សាហកម្ម សិប្បកម្ម ការដ្ឋានសំណង់ ជាប្រភេទគ្រោះថ្នាក់មានដូចជា កំទេចក្រណាត់ អេប៉ុង ភក់ កៅស៊ូ កញ្ចក់ សេរ៉ាមិច ម្នាងសិលា ថ្នាំលាប។ល។ ត្រូវប្រមូល និងដឹកជញ្ជូនយកទៅចាក់នៅទីលានចាក់សំណល់ឧស្សាហកម្ម
- ហាមដាច់ខាតនូវការបោះចោល ឬការដុតសំរាម សំណល់រឹង នៅតាមដងផ្លូវ ទីសាធារណៈ ទីវាលតាមប្រព័ន្ធទឹកលូ-ប្រឡាយ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជននានា។

**៣. ចំពោះក្រុមហ៊ុនផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង មានភារកិច្ចដូចខាងក្រោម៖**

- ទទួលខុសត្រូវលើការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ពីតាមលំនៅឋាន ទីតាំងអាជីវកម្ម សេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស ទីផ្សារ ទីកន្លែងកំសាន្ត អង្គភាព គ្រឹះស្ថានសាធារណៈ និងឯកជននានា នៅក្នុងរាជធានីភ្នំពេញឱ្យបានស្អាតជាប្រចាំ
- ត្រូវរៀបចំ និងធ្វើបច្ចុប្បន្នភាពកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ឱ្យបានច្បាស់លាស់ និងសមស្របតាមស្ថានភាពភូមិសាស្ត្រ ដោយមានការពិគ្រោះយោបល់ និងឯកភាពពីអាជ្ញាធរសង្កាត់ ខណ្ឌ និងរដ្ឋបាលរាជធានីភ្នំពេញ
- ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធ ធ្វើការផ្សព្វផ្សាយ និងផ្តល់កម្មវិធីដឹកជញ្ជូនសំរាម សំណល់រឹង ដល់អាជ្ញាធរខណ្ឌ សង្កាត់ ភូមិ ប្រជាពលរដ្ឋគ្រប់លំនៅឋាន និងគ្រប់ម្ចាស់ទីតាំងអាជីវកម្ម សេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស អង្គភាព គ្រឹះស្ថានសាធារណៈ និងឯកជននានានៅក្នុងរាជធានីភ្នំពេញឱ្យបានដឹង ដើម្បីងាយស្រួលក្នុងការបញ្ចេញសំណល់ឱ្យបានស្របគ្នានឹងម៉ោងដឹកជញ្ជូន
- ត្រូវធានាការប្រមូលដឹកជញ្ជូនសំរាម សំណល់រឹងទៅកាន់ទីលានទុកដាក់សំរាម សំណល់រឹង កុំឱ្យជ្រុះរាយប៉ាយលើផ្លូវ កុំឱ្យហូរស្រក់ទឹកសំណល់ធ្លាក់មកលើថ្នល់ផ្លូវ និងត្រូវបោសសម្អាតកន្លែងដែលប្រមូលនោះឱ្យបានស្អាតល្អ
- ត្រូវធានាបោសសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង នៅតាមដងផ្លូវនីមួយៗឱ្យបាន

ស្អាត និងគោរពទៅតាមម៉ោងពេលនៃកម្មវិធីដែលបានកំណត់។ ក្នុងករណីយឺតយ៉ាវមិនបានអនុវត្ត តាមកម្មវិធីម៉ោងពេលកំណត់ នឹងត្រូវទទួលការព្រមានពីអាជ្ញាធរមានសមត្ថកិច្ច និងទណ្ឌកម្មផ្សេងៗ តាមច្បាប់ជាធរមាន

- ត្រូវរៀបចំឱ្យមានរថយន្តដឹកជញ្ជូន ដែលមានស្លាកសញ្ញាសម្គាល់រថយន្តដឹកសំរាមអាចកែច្នៃបាន (សំរាមស្ងួត) និងសំរាមផ្ទះបាយ (សំរាមសើម) ដោយភ្ជាប់ជាមួយនូវតារាងផែនការ និងកាលវិភាគ រថយន្តចេញចូលដឹកជញ្ជូនតាមប្រភេទនីមួយៗឱ្យដាច់ចេញពីគ្នា និងច្បាស់លាស់
- ត្រូវផ្សព្វផ្សាយកម្មវិធី និងកាលវិភាគប្រមូលសំរាម សំណល់កែច្នៃ សំណល់គ្រោះថ្នាក់ ឱ្យដល់ដៃ ប្រជាពលរដ្ឋនៅមូលដ្ឋាន ដោយសហការជាមួយរដ្ឋបាលខណ្ឌ សង្កាត់មានសមត្ថកិច្ច
- ត្រូវរៀបចំដាក់ធុងសំរាមនៅតាមទីធ្លាសាធារណៈ សួនច្បារ និងតាមផ្លូវសាធារណៈសំខាន់ៗឱ្យទៅ តាមប្រភេទសំរាម និងសំណល់រឹងនីមួយៗ ។

**៤. ការផ្ដល់សេវាប្រមូល ដឹកជញ្ជូន និងទុកដាក់សំរាម សំណល់រឹង និងសំណល់គ្រោះថ្នាក់៖**

- ម្ចាស់ទីតាំងនីមួយៗ ត្រូវទទួលយកសេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង និងសំណល់ គ្រោះថ្នាក់ ជាមួយក្រុមហ៊ុន ឬអង្គភាព ដែលទទួលបានអាជ្ញាប័ណ្ណប្រមូល និងដឹកជញ្ជូនសំណល់ ទាំងនេះ
- ម្ចាស់ទីតាំងទាំងអស់ដែលប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់គ្រោះថ្នាក់ ត្រូវ បង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទុកដាក់សំណល់ទាំងនោះ ទៅតាមតម្លៃដែលបាន កំណត់ដោយរដ្ឋបាលរាជធានីភ្នំពេញ និងក្រសួងស្ថាប័នពាក់ព័ន្ធ។

**៥. រដ្ឋបាលខណ្ឌ សង្កាត់ មានភារកិច្ចដូចខាងក្រោម៖**

- សម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងទុកដាក់សំរាម សំណល់រឹងនៅ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- អប់រំផ្សព្វផ្សាយ និងណែនាំដល់ប្រជាពលរដ្ឋឱ្យយកចិត្តទុកដាក់ក្នុងការញែក វេចខ្ចប់ ទុកដាក់ និង ការបោះចោលសំរាម សំណល់រឹងឱ្យបានត្រឹមត្រូវនៅតាមទីកន្លែង និងពេលវេលាដែលបានកំណត់ ស្របតាមកម្មវិធីប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង
- ត្រូវសម្របសម្រួលក្នុងការកំណត់ទីតាំងទុកដាក់សំរាម សំណល់រឹងបណ្ដោះអាសន្ន រួមទាំងធុង សំរាមសាធារណៈឱ្យបានសមស្រប ដោយមិនបង្កបញ្ហាប៉ះពាល់ដល់ការធ្វើចរាចរណ៍ សុខុមាលភាព សាធារណៈ សោភ័ណភាព និងសណ្ដាប់ធ្នាប់សង្គម
- សហការជាមួយមន្ទីរបរិស្ថាន ជួយដាក់ស្លាកសញ្ញាហាមឃាត់ ការទុកដាក់ និងការបោះចោលសំរាម សំណល់រឹងគ្មានសណ្ដាប់ធ្នាប់ នៅតាមទីតាំងសំខាន់ៗមួយចំនួននៅក្នុងរាជធានីភ្នំពេញ
- ត្រូវធានាថាគ្មានសំរាម សំណល់រឹងនៅសេសសល់ក្នុងមូលដ្ឋានរបស់ខ្លួន ដោយត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងជំរុញការងារប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងរបស់ក្រុមហ៊ុនផ្ដល់សេវាឱ្យ អនុវត្តបានទៀងទាត់តាមកម្មវិធី។ ក្នុងករណីក្រុមហ៊ុនផ្ដល់សេវា មិនបានគោរពតាមកម្មវិធីដឹកជញ្ជូន របស់ខ្លួន រាប់ទាំងការដឹកជញ្ជូនដែលធ្វើឱ្យជ្រុះសំរាម ហូរទឹកសំរាមលើដងផ្លូវ និងមានសំរាមសល់ គរចោលច្រើន ត្រូវធ្វើសេចក្ដីរាយការណ៍មករដ្ឋបាលរាជធានីភ្នំពេញភ្លាមអំពីទីតាំងដែលក្រុមហ៊ុន មិនបានអនុវត្តនោះ ដើម្បីមានវិធានការ

- ដឹកនាំកងកំលាំងនគរបាលខណ្ឌ សង្កាត់ ភ្នាក់ងារអនាម័យ មន្ត្រីបរិស្ថាន ចុះទប់ស្កាត់ ណែនាំ និងពិន័យជាប្រាក់ចំពោះអ្នកចោលសំរាម សំណល់រឹងគ្មានសណ្តាប់ធ្នាប់ និងអ្នកបញ្ចេញសំរាម សំណល់រឹងមកដាក់ក្រៅលំនៅឋាន ខុសទីតាំង និងម៉ោងពេលកំណត់
- ចូលរួមសម្របសម្រួលដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការងារសម្អាត ប្រមូល ដឹកជញ្ជូន និងថ្លៃសេវាដឹកជញ្ជូនសំរាម សំណល់រឹង របស់ប្រជាពលរដ្ឋ ម្ចាស់អាជីវកម្ម សេវាកម្ម មូលដ្ឋានបង្កើតសំណល់ ជាមួយក្រុមហ៊ុនផ្តល់សេវាកម្មសំរាម សំណល់រឹង នៅក្នុងមូលដ្ឋានរបស់ខ្លួន
- ចូលរួមសហការពង្រឹងការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**៦. មន្ទីរបរិស្ថានរាជធានីភ្នំពេញ មានភារកិច្ចដូចខាងក្រោម៖**

- ត្រូវត្រួតពិនិត្យវឌ្ឍនភាពក្រុមហ៊ុនប្រមូល និងដឹកជញ្ជូនសំរាម ក្នុងការរៀបចំផែនការ កម្មវិធី និងកាលវិភាគនានា ដែលកំណត់ក្នុងសេចក្តីណែនាំនេះ
- ត្រូវរៀបចំផែនការត្រួតពិនិត្យការអនុវត្តសកម្មភាពរបស់ក្រុមហ៊ុន រួចធ្វើរបាយការណ៍ជូនរដ្ឋបាលរាជធានីភ្នំពេញ
- លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋអំពីអនាម័យបរិស្ថាន តាមរយៈការអប់រំ ការផ្សព្វផ្សាយអំពីការទុកដាក់ ការសម្អាត ការញែក ការកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ ការកែច្នៃ និងអំពីការចូលរួមប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ណែនាំមន្ត្រីទទួលបន្ទុកការងារបរិស្ថានប្រចាំខណ្ឌនីមួយៗ ឱ្យសហការជាមួយអាជ្ញាធរខណ្ឌ សង្កាត់ ចុះពិនិត្យស្ថានភាពការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងនៅក្នុងខណ្ឌ សង្កាត់នីមួយៗឱ្យបានជាប្រចាំ និងរាយការណ៍មករដ្ឋបាលខណ្ឌ ដើម្បីរកវិធីដោះស្រាយ
- ត្រូវអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងអនុវត្តវិធានការផាកពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន
- ផ្តល់កិច្ចសហការឱ្យបានជិតស្និទ្ធិជាមួយអាជ្ញាធរមូលដ្ឋានខណ្ឌ សង្កាត់ ក្នុងការរៀបចំភ្នាក់ងារពិន័យ ព្រមទាំងធ្វើការអប់រំដល់ភ្នាក់ងារពិន័យអំពីយន្តការ និងនីតិវិធីនៃការចុះអនុវត្តឱ្យមានប្រសិទ្ធភាព។

**៧. យន្តការសម្រាប់អនុវត្តវិធានការពិន័យអន្តរការណ៍**

ក- ក្នុងករណីមិនអនុវត្តតាមការណែនាំ ឬក៏ប្រព្រឹត្តល្មើសនឹងចំណុចណាមួយខាងលើ ម្ចាស់ទីតាំង និងក្រុមហ៊ុនផ្តល់សេវាកម្មទាំងអស់នៅក្នុងចំណុច ១, ២ និង ៣ នៃសេចក្តីណែនាំនេះ នឹងត្រូវទទួលការពិន័យអន្តរការណ៍ដូចខាងក្រោម៖

- ពិន័យជាប្រាក់ចាប់ពី ១០.០០០រៀល ដល់ ២.០០០.០០០រៀល (ចាប់ពីមួយម៉ឺនរៀល ដល់ពីរលានរៀល) ដូចមានចែងក្នុងមាត្រា ៣៩-៤៩ នៃអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពី "ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន"
- ពិន័យជាប្រាក់ចាប់ពី ១.០០០.០០០រៀល ដល់ ៥០.០០០.០០០រៀល (ចាប់ពីមួយលានរៀល ដល់ហាសិបលានរៀល) ឡើងទៅ នឹងត្រូវបិទអាជីវកម្ម ឬផ្អាកការដ្ឋានសាងសង់ជាបណ្តោះអាសន្ន ក្នុងករណីធ្ងន់ធ្ងរ ដែលមន្ត្រីជំនាញពិនិត្យឃើញថាមានការបង្កផលប៉ះពាល់ដល់បរិស្ថាន និងសង្គម ដូចមានចែងនៅក្នុងមាត្រា២០-២២ នៃច្បាប់ស្តីពី "កិច្ចការពារបរិស្ថាន និងការ

គ្រប់គ្រងធនធានធម្មជាតិ" ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ន.ស/រ.ក.ម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦

- ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន
- ចំពោះបុគ្គលណា ដែលមិនបានបង់ប្រាក់ពិន័យអន្តរការណ៍នេះនៅក្នុងរយៈពេល ៣០ថ្ងៃ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាពីរដង បើលើសពី ៦០ថ្ងៃ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាបីដង។ បើផុតរយៈពេល ៩០ថ្ងៃ ត្រូវរៀបចំឯកសារប្តឹងទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន។

ខ- មន្ទីរបរិស្ថានរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌ រដ្ឋបាលសង្កាត់ ភ្នាក់ងារអនាម័យ និងស្ថាប័នមានសមត្ថកិច្ចនានា ជាអ្នកអនុវត្តវិធានការពិន័យអន្តរការណ៍ខាងលើ ចំពោះម្ចាស់ទីតាំង ឬបុគ្គលណាដែលបានអនុវត្តខុសនឹងសេចក្តីណែនាំនេះ។

ទទួលបានសេចក្តីណែនាំនេះ នាយករដ្ឋបាលសាលារាជធានីភ្នំពេញ ប្រធានមន្ទីរបរិស្ថានរាជធានីភ្នំពេញ អភិបាលខណ្ឌទាំង១២ ប្រធានមន្ទីរ-អង្គភាពជំនាញពាក់ព័ន្ធ និងឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ដែលជាប្រជាពលរដ្ឋ ម្ចាស់ទីតាំង ឬអ្នកទទួលខុសត្រូវ (ក្នុងចំណុច ១ និង ២) ប្រធានក្រុមហ៊ុនផ្តល់សេវាកម្មសំរាម សំណល់រឹង (ក្នុងចំណុច៣) នៅក្នុងរាជធានីភ្នំពេញទាំងអស់ ត្រូវចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យបានម៉ឺងម៉ាត់ ប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៣រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០១៩
**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួន ស្រេង**

**<u>កន្លែងទទួល៖</u>**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងបរិស្ថាន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

"ដើម្បីជូនជ្រាប"
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ

"ដើម្បីសហការ"
- រដ្ឋបាលខណ្ឌទាំង១២
- មន្ទីរ-អង្គភាពជំនាញចំណុះរដ្ឋបាលរាជធានីភ្នំពេញ
- ក្នុងចំណុច ១, ២ និង ៣

"ដើម្បីអនុវត្ត"
- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ

"ដើម្បីជួយផ្សព្វផ្សាយ"
- កាលប្បវត្តិ ឯកសារ